

អំណានអក្សរសិល្ប៍នឹងបង្កើតឱ្យមានទម្លាប់អាន និងការសិក្សាពេញមួយជីវិត និងជួយសិស្សឱ្យចេះស្រមើស្រមៃពីគំនិតផ្សេងៗ ចេះវិភាគ និងចេះបកស្រាយរកហេតុផល។ ការសិក្សាអក្សរសិល្ប៍មិនត្រឹមតែជួយឱ្យសិស្សទទួលបានជោគជ័យក្នុងការសិក្សារៀនសូត្រ និងបំពេញវិជ្ជាជីវៈក្នុងយុគសម័យបច្ចេកវិទ្យាឌីជីថលប៉ុណ្ណោះទេ តែថែមទាំងជួយថែរក្សាអក្សរសិល្ប៍ខ្មែរឱ្យស្ថិតស្ថេរគង់វង្ស និងអភិវឌ្ឍអក្សរសិល្ប៍ខ្មែរឱ្យឆ្លើយតបទៅនឹងតម្រូវការសតវត្សទី២១ថែមទៀតផង។

ISBN: 978 99243 40 60 7
9 789924 340607

វិភាគទាននៃការសិក្សាអក្សរសិល្ប៍ខ្មែរក្នុងការលើកកម្ពស់អំណាននៅកម្ពុជា

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

# វិភាគទាននៃ
# ការសិក្សាអក្សរសិល្ប៍ខ្មែរ
## ក្នុងការលើកកម្ពស់អំណាននៅកម្ពុជា



**ដោយ បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

សហការជាមួយគ្រឹះស្ថានបោះពុម្ពផ្សាយស៊ីប៉ា
Sipar
២០១៩

### វិភាគទាននៃ

# ការសិក្សាអក្សរសិល្ប៍ខ្មែរ

### ក្នុងការលើកកម្ពស់អំណាននៅកម្ពុជា

# វិភាគទាននៃ
# ការសិក្សាអក្សរសិល្ប៍ខ្មែរ
## ក្នុងការលើកកម្ពស់អំណាននៅកម្ពុជា

ដោយ បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

២០១៩

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*រចនាទំព័រ និងសម្រួលអត្ថបទដោយអង្គការSipar*
© *ហង់ជួន ណារ៉ុន*
*រក្សាសិទ្ធិគ្រប់យ៉ាង*

*បោះពុម្ពនៅកម្ពុជាដោយរោងពុម្ព អេស អេច*

# មាតិកា


*អារម្ភកថា* ...................................................................................ix

## ផ្នែកទី១
## អំណានក្រោយរបបប្រល័យពូជសាសន៍ខ្មែរក្រហម ៖ ស្ទ័យសិក្សាអក្សរសិល្ប៍ខេមរនិយម

**I. *អំណានក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩*** .................................... ១

*១.១ ការដើរប្រមូលសៀវភៅ និងសម្អាតសាលារៀន* ................ ១

*១.២ ការធ្វើស្ទ័យសិក្សាអក្សរសិល្ប៍ខ្មែរក្រោយថ្ងៃរំដោះ* ........... ២

**II. *ទិដ្ឋភាពទូទៅនៃអក្សរសិល្ប៍ខេមរនិយម*** ....................................... ៥

*២.១ ចរន្តសំខាន់ៗនៃចលនាអក្សរសិល្ប៍ខេមរនិយម* ............... ៥

*២.២ ការសិក្សាសង្គមខ្មែរតាមរយៈអក្សរសិល្ប៍ខេមរនិយម* ...... ៧

*២.២.១ អត្ថរូបនៃអក្សរសិល្ប៍ខេមរនិយម* ............................... ៧

*២.២.១.១ ប្រភពរឿងនិងអ្នកនិពន្ធ* ........................................... ៧

*២.២.១.២ ចរន្តអក្សរសិល្ប៍ប្រាកដនិយម និងរវើរវាយនិយម* ..... ៩

*២.២.១.២ សិល្ប៍វិធីតែងនិពន្ធ* ................................................ ១១

*២.២.២ អត្ថន័យនៃអក្សរសិល្ប៍ខេមរនិយម* ........................... ១២

*២.២.៣ អត្ថរសនៃអក្សរសិល្ប៍ខេមរនិយម* ........................... ១៣




fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ផ្នែកទី២
## ឥណ្ឌាភាវូបនីយកម្មកម្ពុជាតាមរយៈអក្សរសិល្ប៍ព្រាហ្មណ៍និយម


**I. *ទិដ្ឋភាពទូទៅនៃឥណ្ឌាភាវូបនីយកម្ម*** ........ ១៨

*១.១ វប្បធម៌ខ្មែរមុនការហូរចូលនៃវប្បធម៌ឥណ្ឌា* ........ ១៨

*១.២ តួនាទីពាណិជ្ជកម្ម និងសាសនានៅក្នុង ឥណ្ឌាភាវូបនីយកម្ម* ........ ២១

**II. *វិភាគទានអក្សរសិល្ប៍ព្រាហ្មណ៍និយមក្នុងឥណ្ឌាភាវូបនីយកម្ម*** ... ២៤

*២.១ ឥទ្ធិពលអក្សរសិល្ប៍ឥណ្ឌាទៅលើចម្ងាក់បុរាណខ្មែរ* ...... ២៤

*២.២ ឥទ្ធិពលអក្សរសិល្ប៍ឥណ្ឌាទៅលើអក្សរសិល្ប៍ ព្រាហ្មណ៍និយមខ្មែរ* ........ ២៧

*២.២.១ អត្តរូបនៃអក្សរសិល្ប៍ព្រាហ្មណ៍និយមខ្មែរ* ........ ២៨

*២.២.២ អត្ថន័យនៃរឿងរាមកេរ្តិ៍* ........ ៣០

*២.២.២.១ សង្ខេបរឿងរាមកេរ្តិ៍* ........ ៣០

*២.២.២.២ ទ្រឹស្តីព្រាហ្មណ៍និយម* ........ ៣៨

*២.២.២.៣ ទស្សនៈសំខាន់ៗក្នុងរឿងរាមកេរ្តិ៍* ........ ៣៨

*២.២.៣ អត្ថរសនៃរឿងរាមកេរ្តិ៍* ........ ៤១

**III. *សេចក្តីសន្និដ្ឋាន*** ........ ៤៦




fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ផ្នែកទី៣
## ការវិវត្តអក្សរសិល្ប៍ពុទ្ធនិយមនៅសម័យក្រោយអង្គរ

**I. *ទិដ្ឋភាពទូទៅនៃអក្សរសិល្ប៍ខ្មែរសម័យក្រោយអង្គរ*** .................... ៤៧

១.១ អក្សរសិល្ប៍ខ្មែរសម័យលង្វែក ........................................ ៤៧

១.២ អក្សរសិល្ប៍ខ្មែរសម័យឧដុង្គ ........................................ ៤៨

**II. *អត្តរូបនៃអក្សរសិល្ប៍ពុទ្ធនិយមខ្មែរ*** .............................................. ៥២

២.១ ប្រភពនៃអក្សរសិល្ប៍ពុទ្ធនិយម ........................................ ៥២

២.២ អ្នកនិពន្ធពីស.វ.ទី១៧ដល់១៩ ........................................ ៥៤

**III. *អត្តន័យនៃអក្សរសិល្ប៍ពុទ្ធនិយមខ្មែរ*** ........................................ ៦០

**IV. *អត្ថរសនៃអក្សរសិល្ប៍ពុទ្ធនិយមខ្មែរ*** ........................................ ៦៣

៤.១ ទិដ្ឋភាពអក្សរសាស្ត្រនៃការវិវត្តអក្សរសិល្ប៍
កំណាព្យខ្មែរ ........................................................................ ៦៤

៤.២ ការប្រើប្រាស់សំនួនវោហារក្នុងអក្សរសិល្ប៍
កំណាព្យខ្មែរ ........................................................................ ៧១

៤.៣ គំនិតនៅក្នុងអក្សរសិល្ប៍កំណាព្យខ្មែរ ........................ ៧៣

៤.៤ សោភ័ណខាងផ្នែកប្រៀបធៀបក្នុងស្នាដៃអក្សរសិល្ប៍
កំណាព្យ ............................................................................ ៧៥

**V. *សេចក្តីសន្និដ្ឋាន*** .............................................................................. ៧៩

***ឯកសារពិគ្រោះ*** ................................................................................ ៨៣



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# អារម្ភកថា

គោលដៅនៃការរៀបចំបាឋកថានេះ គឺដើម្បីចូលរួមចំណែកដ៏តិចតួចស្តួចស្តើង ក្នុងការសិក្សានិងវិភាគស្នាដៃអក្សរសិល្ប៍ខ្មែរ ក្នុងគោលដៅលើកកម្ពស់អំណានជាខេមរភាសា។ អំណាន គឺជាមូលដ្ឋានគ្រឹះនៃការក្រេបយកចំណេះវិជ្ជាដែលជាទ្រព្យមហាសាលសម្រាប់ជនានុជនទាំងប្រុសស្រី។ នៅក្នុងយុគសម័យបច្ចេកវិទ្យាឌីជីថល ការអានសៀវភៅគ្រាន់តែជាប្រភពមួយក្នុងចំណោមប្រភពផ្សេងៗទៀត សម្រាប់ចាប់យកចំណេះវិជ្ជាថ្មីៗ របៀបរៀនមានការប្រែប្រួលយ៉ាងខ្លាំង ហើយនិយមន័យនៃចំណេះដឹងក៏មានការផ្លាស់ប្តូរផងដែរ។ យុវជនសម័យថ្មីរៀនតាមរយៈការអាន តាមរយៈការមើលតាម YouTube ការស្តាប់សំឡេង ការមើលរូប និងការសរសេរជាដើម។ យុវជនត្រូវការជំនាញខាងផ្នែកបច្ចេកវិទ្យា ដើម្បីពង្រឹងសមត្ថភាពប្រកួតប្រជែងរបស់ពួកគេនៅក្នុងយុគសម័យឌីជីថល និងមនុស្សយន្ត។ តាមការវិភាគរបស់វិទ្យាស្ថានសាកល ម៉ាកគីនហ្សី ដែលបានសិក្សាលើវិជ្ជាជីវៈចំនួន៧៥០ សកម្មភាពការងារចំនួន៥០%អាចនឹងត្រូវធ្វើស្វ័យប្រវត្តិការូបនីយកម្ម (Automation)។ ប្រការនេះមានន័យថា មនុស្សត្រូវធ្វើការជាមួយគ្រឿងយន្តក្នុងគ្រប់វិស័យនៃការងារ ដែលទាមទារឱ្យអ្នកអប់រំត្រូវពិចារណាពីជំនាញដែលយុវជនយើងត្រូវការនាពេលអនាគត។

យើងដឹងហើយថា អក្ខរកម្មក្នុងយុគសម័យឌីជីថលមានការប្រែប្រួលដោយត្រូវមានសមាសភាគដូចតទៅ ៖

I. 3Rs (និយមន័យដើម) ដូចជា (១) អំណាន (Reading) (២) សំណេរ (W-Riting) និង (៣) លេខនព្វន្ត (A-Rithmetics) ហើយបូកនឹង

II. 8Cs (អក្ខរកម្មក្នុងស.វ.ទី២១) (១) បំណិនត្រិះរិះ និងដោះស្រាយបញ្ហា (Critical thinking and problem solving) (២) ច្នៃប្រឌិតនិង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នវានុវត្តន៍ (*Creativity and innovation*) (៣) ការយល់ពីវប្បធម៌ប្រទេសផ្សេងៗ (*Cross-cultural understanding*) (៤) បំណិនសហការ ធ្វើការជាក្រុម និងភាពជាអ្នកដឹកនាំ (*Collaboration, teamwork & leadership*) (៥) បំណិនគមនាគមន៍ព័ត៌មាន និងអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ (*Communications, information & media literacy*) (៦) អក្ខរកម្មកុំព្យូទ័រ និងបច្ចេកវិទ្យាព័ត៌មាន (*Computing & ICT literacy*) (៧) បំណិនអាជីព និងរៀន (*Career & learning skills*) (៨) បំណិន ខាងផ្នែកផ្លាស់ប្តូរ (*Change*)

III. *2Ls*៖ (១) បំណិនក្នុងការរៀន (*Learning Skills*)៖ រៀនបំភ្លេចចំណេះដឹងចាស់និងរៀនឡើងវិញ និង (២) ភាពជាអ្នកដឹកនាំ (*Leadership*)

ដូច្នេះ អ្នកអប់រំត្រូវគិតគូរឡើងវិញពីកម្មវិធីសិក្សាថ្មី និងវិធីសាស្ត្របង្រៀន។ កម្មវិធីសិក្សាមិនត្រូវផ្តោតតែលើចំណេះដឹងខ្លឹមសារមេរៀន និងបំណិនប៉ុណ្ណោះទេ តែត្រូវផ្តោតទៅលើបញ្ញត្តិ ដើម្បីអាចឱ្យសិស្សចេះវិភាគ និងអាចយកចំណេះដឹងដែលទទួលបាន ទៅប្រើក្នុងគ្រប់កាលៈទេសៈទាំងអស់។ ពោលគឺត្រូវលើកកម្ពស់ការអនុវត្តកម្មវិធីសិក្សាផ្តោតលើបញ្ញត្តិ ដែលជាកម្មវិធីសិក្សាមានសមាសភាគបី (*Three-dimentional curriculum*) ក្នុងគោលដៅបង្ហាត់បង្រៀន ដោយផ្សារភ្ជាប់ព្រឹត្តិការណ៍ ខ្លឹមសារមេរៀន (*disciplinary content*) និងបំណិននៅក្នុងមុខវិជ្ជា ទៅនឹងបញ្ញត្តិតាមមុខវិជ្ជា និងបង្កើតជាទស្សនៈរួម (*generalizations*)។

ដើម្បីអនុវត្តកម្មវិធីសិក្សាផ្តោតលើបញ្ញត្តិ អ្នកអប់រំត្រូវអនុវត្តវិធីសាស្ត្របង្រៀនថ្មីដែលផ្តោតលើការត្រិះរិះពិចារណា (*Inquiry-based learning*)។ ប្រការនេះទាមទារឱ្យសិស្សត្រូវអានច្រើន និងត្រូវមានការស្រមើស្រមៃ (*Imagination*) នវានុវត្តន៍ ពិចារណានិងស្រាវជ្រាវដោយខ្លួនឯង។ ក្នុងន័យនេះ អំណានអក្សរសិល្ប៍នឹងបង្កើតឱ្យមានទម្លាប់អាន និងការសិក្សាពេញមួយជីវិត និងជួយសិស្សឱ្យចេះស្រមើស្រមៃពីគំនិតផ្សេងៗ ចេះវិភាគ និងចេះបកស្រាយរកហេតុផល។

*ការសិក្សាអក្សរសិល្ប៍មិនត្រឹមតែជួយឱ្យសិស្សទទួលបានជោគជ័យក្នុងការសិក្សារៀនសូត្រ និងបំពេញវិជ្ជាជីវៈ ក្នុងយុគសម័យបច្ចេកវិទ្យាឌីជីថលប៉ុណ្ណោះទេ តែថែមទាំងជួយថែរក្សាអក្សរសិល្ប៍ខ្មែរឱ្យស្ថិតស្ថេរគង់វង្ស និងអភិវឌ្ឍអក្សរសិល្ប៍ខ្មែរឱ្យឆ្លើយតបទៅនឹងតម្រូវការសតវត្សទី២១ថែមទៀតផង។*

*ថ្ងៃចន្ទ ៦កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២*
*ភ្នំពេញ ថ្ងៃទី១១ ខែមីនា ឆ្នាំ ២០១៩*
*បណ្ឌិតសភាចារ្យ* ***ហង់ជួន ណារ៉ុន***



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ផ្នែកទី១
# អំណានក្រោយរបបប្រល័យពូជសាសន៍ខ្មែរក្រហម ៖ ស្វ័យសិក្សាអក្សរសិល្ប៍ខេមរនិយម

## I. អំណានក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩

### ១.១ ការដើរប្រមូលសៀវភៅ និងសម្អាតសាលារៀន

*ក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩ ខ្ញុំបានត្រឡប់មកភ្នំពេញវិញ នៅក្នុងខែមីនា ឆ្នាំ១៩៧៩ និងបានចូលបម្រើការងារនៅក្នុងក្រុមយុវជន ក្រសួងអប់រំ យុវជន និងកីឡា ដែលមានភារកិច្ចដើរសម្អាតសាលារៀន ក្នុងគោលដៅរៀបចំដំណើរការសិក្សាឡើងវិញ ក្នុងគ្រប់កម្រិតនៃភូមិសិក្សាទាំងអស់។ ក្រុមយើងបានសម្អាតសាលាកម្រិតសិក្សាទី១កុមារីសម្រាប់បើកបវេសនកាលដំបូងនៅខែកញ្ញា ឆ្នាំ១៩៧៩ ហើយបន្ទាប់មកទៀត បានសម្អាតសាលាកម្រិតសិក្សាទី២កម្ពុជបុត្រ និងសាលាកម្រិតសិក្សាទី៣ ភ្នំដូនពេញ (វិទ្យាល័យព្រះសីសុវត្ថិ បច្ចុប្បន្ន)។*

*ពេលទំនេរពីការងារខ្ញុំបានដើររើសសៀវភៅ នៅតាមបណ្ណាល័យដែលពួកខ្មែរក្រហមគរទុកចោលជាគំនរធំៗ និងបានដើររើសសៀវភៅតាមផ្ទះ ដែលគេបោះបង់ចោលនៅពេលនោះ។ ចៃដន្យ ខ្ញុំរើសបានសៀវភៅមួយចំនួន ដែលសរសេរដោយលោក រ៉ាន់ឌី កាអុន មុនឆ្នាំ១៩៧៥។ ខ្ញុំក៏បានចូលទៅរើសសៀវភៅនៅក្នុងបណ្ណាល័យនៃមហាវិទ្យាល័យគរុកោសល្យ*

ដែលនៅពេលនោះត្រូវបានពួកខ្មែរក្រហមប្រើប្រាស់ជាឃ្លាំងម៉ូតូចាស់ៗ ហើយរើសបានសៀវភៅមួយចំនួនជាភាសាអង់គ្លេស។ តែចំណេះដឹងភាសាអង់គ្លេស និងភាសាបារាំងរបស់ខ្ញុំនៅតិចតួចស្តួចស្តើងណាស់ ទើបខ្ញុំបានដាក់ចិត្តថា ខ្ញុំនឹងខិតខំរៀនភាសាទាំងពីរនេះ ជាពិសេសភាសាបារាំង ដែលខ្ញុំមិនបានរៀនជាប់លាប់នៅកម្រិតបឋមសិក្សា។

ខ្ញុំមិនបានស្គាល់លោក វ៉ាន់ឌី កាអុន ដោយផ្ទាល់ទេ ដោយគ្រាន់តែដឹងថា លោកកើតនៅឆ្នាំ១៩៤២ នៅទីក្រុងភ្នំពេញ។ លោកធ្លាប់ជានិស្សិតរៀននៅប្រទេសបារាំង។ បន្ទាប់ពីថ្ងៃរំដោះ លោកបានចូលមកធ្វើការនៅគណៈឃោសនាអប់រំមជ្ឈិម ដែលមានភារកិច្ចធ្វើការស្រាវជ្រាវប្រវត្តិបក្សប្រជាជនកម្ពុជា និងផ្សព្វផ្សាយគោលនយោបាយរបស់គណៈបក្ស។ លោកក៏មានភារកិច្ចបង្រៀននយោបាយដល់កម្មាភិបាលថ្នាក់កណ្តាលផងដែរ។ ក្រោយមក លោក វ៉ាន់ឌី កាអុន បានបង្កើត និងដឹកនាំវិទ្យាស្ថានស្រាវជ្រាវសង្គមនៅក្នុងគណៈឃោសនាអប់រំមជ្ឈិមផងដែរ។ ពេលខ្លះ ខ្ញុំធ្លាប់ឃើញលោកមកប្រជុំនៅក្រសួងសិក្សាធិការជាតិ ដើម្បីពិភាក្សាលើគោលនយោ-បាយសិក្សាធិការ។ លោកមាននិន្នាការនយោបាយប្រឆាំងរាជានិយម។ នៅឆ្នាំ១៩៨៩ ពេលដែលសម្តេច ហ៊ុន សែនចាប់ផ្តើមចរចាជាមួយសម្តេចសីហនុ លោកបានរត់ទៅប្រទេសបារាំង ហើយធ្វើការចិញ្ចឹមគ្រួសារយ៉ាងលំបាក មុននឹងក្លាយជាអ្នកកាសែតនៅវិទ្យុបារាំងអន្តរជាតិនៅឆ្នាំ១៩៩៣។ នៅឆ្នាំ១៩៩៤ លោកបានបញ្ចប់និក្ខេបបទបណ្ឌិតប្រវត្តិសាស្ត្រនៅទីក្រុង Nice។ លោកបានធ្វើការនៅវិទ្យុបារាំងអន្តរជាតិរហូតចូលនិវត្តន៍នៅឆ្នាំ២០០៧។

## ១.២ ការធ្វើស្វ័យសិក្សាអក្សរសិល្ប៍ខ្មែរក្រោយថ្ងៃរំដោះ

បញ្ញវន្តខ្មែរជាង៨០%បានទទួលមរណភាពក្នុងរបបប្រល័យពូជសាសន៍ប៉ុលពត។ បញ្ញវន្តដែលសល់ពីស្លាប់មួយចំនួនបានសម្រេចចិត្ត



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កៀសខ្លួនទៅព្រំដែនថៃ ដើម្បីស្វែងរកសិទ្ធិជ្រកកោននៅប្រទេសទី៣ទៀត។

ខ្ញុំនៅពេលនោះអាយុ១៧ឆ្នាំ ដែលជាវ័យមួយចង់ចេះចង់ដឹង ចង់អាន និងចង់សិក្សាបន្តឱ្យបានវែងឆ្ងាយ។ យើងមានការស្រេកឃ្លានចំណេះវិជ្ជា ដោយសារនៅក្នុងរបបប៉ុលពត ពួកគេមិនត្រឹមតែបង្អត់មិនឱ្យយើងបរិភោគអាហារឱ្យបានគ្រប់គ្រាន់ប៉ុណ្ណោះទេ ពួកគេថែមទាំងបង្អត់អាហារផ្លូវគំនិតថែមទៀត។ ក្នុងវ័យជំទង់នេះ ខ្ញុំនៅមិនទាន់យល់អស់នូវអ្វីដែលកើតឡើងក្នុងសម័យប៉ុលពត និងបញ្ហានយោបាយនៅក្នុងទសវត្សឆ្នាំ១៩៨០ នៅឡើយទេ។ ដូច្នេះ ខ្ញុំបានដាក់ចេញនូវគោលដៅដ៏ច្បាស់លាស់មួយ គឺ រៀន រៀន និងរៀន។

មុនពេលចូលរៀនថ្នាក់ទី៨ នៅសាលាកម្រិតសិក្សាទី៣ ភ្នំដូនពេញ ខ្ញុំចាប់ផ្ដើមអានដោយខ្លួនឯង។ ដោយខ្ញុំមិនចេះភាសាបរទេស ខ្ញុំចាប់ផ្ដើមធ្វើស្វ័យសិក្សា ដើម្បីរំឭកភាសាអង់គ្លេស ដែលខ្ញុំធ្លាប់រៀនដល់ថ្នាក់ទី២ ទំនើប (សមមូលនឹងថ្នាក់ទី៧បច្ចុប្បន្ន) ហើយអានសៀវភៅរបស់លោក វ៉ាន់ឌី កាអុន ដែលខ្ញុំប្រមូលបាន។ អំណានដំបូងនេះបានផ្ដល់ឱ្យខ្ញុំនូវឱកាសក្នុងការពង្រឹងចំណេះដឹងភាសាខ្មែរឡើងវិញ។ នៅមុនឆ្នាំ១៩៧៥ សិស្ស និងនិស្សិតសម័យសាធារណរដ្ឋខ្មែរចូលចិត្តអានសៀវភៅរឿង ដែលបកប្រែពីអត្ថបទអក្សរសិល្ប៍ក្បាច់គុណបុរាណចិន តែងនិពន្ធដោយអ្នកនិពន្ធហុងកុងដ៏ល្បីល្បាញម្នាក់ឈ្មោះ ជិន យ៉ុង (១៩២៤-២០១៨)។ អ្នកនិពន្ធរៀបចំតាក់តែងប្រកបដោយទេព្យកោសល្យ ហើយអ្នកបកប្រែសរសេរភាសាខ្មែរ ប្រកបដោយសំនួនវោហារសាស្ត្រដ៏ទាក់ទាញ ធ្វើឱ្យអ្នកអានតាមដានសាច់រឿងអត់បាយ អត់ទឹក ថែមទាំងអត់ទទួលទានដំណេកទៀតផង ដើម្បីកុំឱ្យដាច់សាច់រឿង។ ប្រការនេះហើយ រួមផ្សំនឹងការអនុវត្តនូវគោលនយោបាយអប់រំ ដែលផ្ដល់ពិន្ទុលើភាសាខ្មែរគុណនឹង៣ ស្មើនឹងគណិតវិទ្យានៅពេលប្រឡង ទើបអំណានត្រូវបានលើកកម្ពស់ខ្លាំងណាស់ ហើយសិស្សដែលពូកែភាសាជាតិទើបអាចទទួលពិន្ទុល្អក្នុងពេលប្រឡង។

ការអានសៀវភៅរបស់លោក វ៉ាន់ឌី កាអុន និងសៀវភៅផ្សេងៗទៀត ដែលខ្ញុំរើសបានក្រោយថ្ងៃរំដោះ ៧ មករា ធ្វើឱ្យខ្ញុំក្លាយទៅជាសិស្សពូកែភាសាខ្មែរ។ ពួកយើងដែលរងគ្រោះសម័យខ្មែរក្រហមពិតជាមានការស្រេកឃ្លានចំណេះវិជ្ជា ដែលជាប្រភពមិនចេះរីងស្ងួតនៃការអភិវឌ្ឍសមត្ថភាពផ្ទាល់ខ្លួនរបស់យុវវ័យ។ ក្រោយមានវិបល្លាសសង្គមម្ដងៗ គេតែងតែឃើញចលនាងើបឡើងវិញរបស់ជាតិក្នុងគ្រប់វិស័យ ដូចជាការរីកដុះដាលនៃអក្សរសិល្ប៍ខេមរនិយមក្នុងសម័យឯករាជ្យដូច្នេះដែរ។ ប្រទេសកម្ពុជានៅចុងសតវត្សទី១៩ និងដើមសតវត្សទី២០ពិតជាមានសំណាង ដោយសារតែការខិតខំប្រឹងប្រែងអស់រយៈពេលជិតមួយសតវត្ស យើងអាចកសាងខឿនអប់រំជាតិ និងអត្តសញ្ញាណជាតិបានឡើងវិញ ដោយមានការជួយជ្រោមជ្រែងពីអ្នកប្រាជ្ញបារាំងផងដែរ។ ជាពិសេស ការបណ្ដុះបណ្ដាលធនធានមនុស្សក្នុងសម័យសង្គមរាស្ត្រនិយម បានជួយឱ្យប្រទេសកម្ពុជាស្មើមុខស្មើមាត់ឡើងវិញនៅជ្រោយឥណ្ឌូចិន ដែលគេឯងស្ងប់ស្ងែងថាជាកោះសន្តិភាពព័ទ្ធជុំវិញដោយភ្លើងសង្គ្រាមវៀតណាម។

យុវជនត្រូវមានទឹកចិត្តក្លៀវក្លាក្នុងការបណ្ដុះទម្លាប់អាន ដើម្បីពង្រឹងសមត្ថភាព និងបន្តវេនបញ្ញវន្តជំនាន់មុន ដើម្បីទុកមត៌កដល់អ្នកជំនាន់ក្រោយ ដូចដូនតាយើងសម័យអង្គរ និងកវីនិពន្ធសម័យក្រោយអង្គរដូច្នេះដែរ។ ដូច្នេះហើយ ទើបក្នុងវ័យសិក្សានៅកម្រិតឧត្តមសិក្សា ខ្ញុំតែងតែអានជារៀងរាល់ថ្ងៃនូវអត្ថបទសារព័ត៌មាន និងសៀវភៅតាមមុខវិជ្ជាជំនាញ ហើយបានដាក់ចេញនូវគោលដៅថា ខ្ញុំត្រូវតែខិតខំរៀនសូត្រ ដើម្បីចូលរួមចំណែកក្នុងការកសាងប្រទេសជាតិ ជាពិសេសវិស័យអប់រំកម្ពុជាឡើងវិញ តាមរយៈការបំពេញការងារប្រកបដោយមនសិការជាតិ និងការសរសេរសៀវភៅនៅពេលទំនេរពីការងារ។ សាកលភាវូបនីយកម្ម និងការរីកសាយភាយភាសាអង់គ្លេសបានបង្កើតនូវបញ្ហាប្រឈមយ៉ាងខ្លាំង សម្រាប់អ្នកនិពន្ធជាភាសាជាតិដែលរដ្ឋត្រូវមានគោលនយោបាយគាំទ្រ និងគាំពារ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*ជាពិសេសនៅក្នុងការបោះផ្សាយស្នាដៃ។ ជាការពិត ការស្រាវជ្រាវបាន បង្ហាញឱ្យឃើញថា ប្រសិនបើអ្នកមិនចេះភាសាជាតិឱ្យស្ទាត់ទេ អ្នកក៏មិន អាចចេះភាសាបរទេសឱ្យស្ទាត់បានដែរ!*

## II. ទិដ្ឋភាពទូទៅនៃអក្សរសិល្ប៍ខេមរនិយម

### ២.១ ចរន្តសំខាន់ៗនៃចលនាអក្សរសិល្ប៍ខេមរនិយម

*លោក វ៉ាន់ឌី កាអុន បានចែកចលនាអក្សរសិល្ប៍ខេមរនិយមជា ចរន្តដូចតទៅ ៖*

***ប្រាកដនិយម*** *៖ អក្សរសិល្ប៍ប្រាកដនិយម (Réalisme) គឺជាចរន្ត អក្សរសិល្ប៍ដែលមានលក្ខណៈស្របតាមធម្មជាតិ និងដែលយោងទៅតាម ច្បាប់ធម្មជាតិ។ អក្សរសិល្ប៍ប្រាកដនិយមពិពណ៌នា និងលាតត្រដាងការ ពិតនៃលក្ខណៈពិតប្រាកដនៃជីវិតមនុស្សលោក បង្ហាញការពិតក្នុងសង្គម និងលាតត្រដាងដោយត្រង់ៗ និយាយចំៗ អធិប្បាយរៀបរាប់អំពីចរិយា មាយាទនៃតួអង្គ ដែលអ្នកនិពន្ធធ្លាប់សង្កេតឃើញក្នុងសង្គម។ អក្សរសិល្ប៍ រឿង«សុភាទន្សាយ» ចូលក្នុងប្រភេទប្រាកដនិយម ដោយសារទន្សាយមិន ជឿតាមការអង្វររបស់ក្រពើឱ្យស្រាយចំណងក្រពើឡើយ ដោយសារ ទន្សាយមិនជឿថា ក្រពើនឹងតបស្នងសងគុណទន្សាយវិញ ដូចពាក្យចាស់ លោកថា «ធ្វើល្អបានល្អ»នោះឡើយ។ ជាតិជាសត្វ ដែលបរិភោគសាច់ ក្រពើនឹងលេបត្របាក់ទន្សាយ តាមច្បាប់ធម្មជាតិជាក់ជាមិនខាន។ ទស្សនៈ ប្រាកដនិយមក៏បង្ហាញផងដែរពីភាពជាក់ស្តែងខ្លះដូចជា«ខ្ជួនទាបកុំតោង ដៃខ្លីកុំឈោងស្រវាឱបភ្នំ»។*

***អណ្តែតអណ្តូងនិយម*** *៖ អក្សរសិល្ប៍អណ្តែតអណ្តូងនិយម (Romantisme) គឺជាចរន្តអក្សរសិល្ប៍ ដែលមានលក្ខណៈផ្ទុយពីការពិត ដែលមាន តែនៅក្នុងការស្រមើស្រមៃ និងការរវើរវាយរបស់អ្នកនិពន្ធ ហើយដែល មានតែក្នុងគំនិត(Idéal)តែប៉ុណ្ណោះ។ រឿងអណ្តែតអណ្តូងនិយមបង្ហាញ*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ថា នៅក្នុងលោកនេះគ្មានអ្វីដែលធំជាងស្នេហាឡើយ ហើយតួអង្គខិតខំស្វែងរកស្នេហា ដែលបរិសុទ្ធ។ នៅពេលខ្លះដំណើរសាច់រឿងនៃអក្សរសិល្ប៍អណ្តែតអណ្តូងនិយមវាប្រាសចាកពីច្បាប់ធម្មជាតិ។ អណ្តែតអណ្តូងនិយមខ្លះមានលក្ខណៈឧត្តមគតិនិយម គឺថាអ្វីៗសុទ្ធសឹងតែល្អចំពោះមនុស្សលោកទាំងអស់។

**ជីវិតនិយម** ៖ អក្សរសិល្ប៍ជីវិតនិយមមានគោលដៅអប់រំឱ្យស្រឡាញ់ជីវិត ឱ្យចេះតស៊ូយ៉ាងអង់អាចក្លាហាន ដោយមិនឱ្យតម្លៃខ្លាំងពេកលើប្រព័ន្ធគំនិត។ តួអង្គសុខចិត្តក្រេបយកសុភមង្គល ថ្វីត្បិតតែវាជាសុភមង្គលបន្តិចបន្តួចក៏ដោយ។ ទស្សនវិជ្ជាជីវិតនិយម គឺជាទស្សនវិជ្ជាសុទិដ្ឋិនិយម ហើយមិនបង្រៀនមនុស្ស ឱ្យលះបង់ជីវិតលោកិយសច្ចៈ ដើម្បីស្វែងរកសេចក្តីសុខក្នុងបរលោកឡើយ។ រឿងសុភាទន្សាយ អាចចាត់ទុកថា ជាអក្សរសិល្ប៍ជីវិតនិយម ដោយទន្សាយប្រើប្រាស់តែប្រាជ្ញា ដែលខ្លួនមាន ដើម្បីដោះ-ស្រាយបញ្ហា។ ទន្សាយត្រូវរកគ្រប់កលល្បិច ដើម្បីប្រយុទ្ធតទល់នឹងអ្នកខ្លាំង។ សុភាទន្សាយជាតួអង្គមានសច្ចធម៌ ស្រឡាញ់យុត្តិធម៌ ចេះជួយយកអាសាអ្នកទន់ខ្សោយ និងអ្នកស្លូតត្រង់ប្រៀបបីដូចជាស្ថាប័នតុលាការដូច្នេះដែរ។

**វិចារណនិយម** ៖ អក្សរសិល្ប៍វិចារណនិយមទាត់ចោលនូវជំនឿ និងបុរេវិនិច្ឆ័យ ដែលគ្មានវិចារណញ្ញាណជាមូលដ្ឋាន ហើយយកប្រាជ្ញា និងតម្រិះវិជ្ជាធ្វើជាមធ្យោបាយ ដើម្បីដោះស្រាយបញ្ហា។ រឿងធនញ្ជ័យ គឺជាវណ្ណកម្មអក្សរសិល្ប៍ ដែលឈរលើមូលដ្ឋាននៃតក្កវិជ្ជា និងការពិចារណា។ ធនញ្ជ័យបានយកចំណេះប្រាជ្ញារបស់ខ្លួនជាដើមទុន ដើម្បីប្រយុទ្ធនឹងសណ្តាប់ធ្នាប់សង្គមសក្តិភូមិ ក្នុងអំឡុងសតវត្សទី១៨ និង១៩។ ក្នុងរឿងធនញ្ជ័យ អ្នកនិពន្ធចង់បង្ហាត់បង្ហាញពីរបៀបដោះស្រាយបញ្ហា ដោយត្រូវប្រើប្រាស់ប្រាជ្ញា និងតក្កវិទ្យា ដើម្បីទប់ទល់នឹងកលល្បិចគ្រប់បែបយ៉ាង។ វណ្ណកម្មនេះបើមើលដំបូងហាក់បីដូចជារឿងកំប្លែង តែបង្កប់នូវវិធីត្រិះរិះ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ពិចារណាយ៉ាងជ្រាលជ្រៅ ដែលយើងអាចឱ្យនិយមន័យថា គឺជាចរន្តអក្សរសិល្ប៍វិចារណនិយម ក្នុងចលនាអក្សរសិល្ប៍ខេមរនិយម។

**២.២ ការសិក្សាសង្គមខ្មែរតាមរយៈអក្សរសិល្ប៍ខេមរនិយម**

**២.២.១ អត្ថរូបនៃអក្សរសិល្ប៍ខេមរនិយម**

**២.២.១.១ ប្រភពរឿងនិងអ្នកនិពន្ធ**

ក្នុងការសិក្សាអក្សរសិល្ប៍ ខ្ញុំជ្រើសរើសវណ្ណកម្មចំនួនពីរ ដែលក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចូលក្នុងកម្មវិធីសិក្សា គឺរឿង«កូឡាបប៉ៃលិន» និងរឿង«ផ្កាស្រពោន»។ មូលហេតុអ្វីបានជាក្រសួងអប់រំចាត់ទុករឿងទាំងពីរនេះជាវណ្ណកម្មដែលមានលក្ខណៈសម្បូណ៌បែប គ្រប់លក្ខណៈនៃអក្សរសិល្ប៍តំណាងឱ្យចលនាខេមរនិយម (*les classiuqes khmères*)? មូលហេតុអ្វីបានជាស្នាដៃផ្សេងទៀតអាចមិនទាន់ឈានដល់កម្រិតខាងលើ? ខ្ញុំសូមអនុញ្ញាតបកស្រាយដូចតទៅ៖

ស្នាដៃអក្សរសិល្ប៍ពីរសម័យក្រោយអាណាព្យាបាលបារាំង ដែលយើងអាចចាត់ទុកថា ជាស្នាដៃអក្សរសិល្ប៍«ប្រាកដនិយម»នៃចលនាខេមរនិយម គឺរឿង«កូឡាបប៉ៃលិន» ដែលជាវណ្ណកម្មនិពន្ធដោយលោក ញ៉ុក ថែម បោះពុម្ពផ្សាយក្នុងឆ្នាំ១៩៦០ និងរឿង«ផ្កាស្រពោន» ដែលយើងអាចចាត់ទុកថា ជាស្នាដៃអក្សរសិល្ប៍«អណ្តែតអណ្តូងនិយម»នៃចលនាខេមរនិយម ដែលជាវណ្ណកម្មនិពន្ធរបស់លោក នូ ហាច និងបោះពុម្ពផ្សាយក្នុងឆ្នាំ១៩៦០ដូចគ្នាដែរ។

(១) លោក ញ៉ុក ថែម កើតនៅឆ្នាំ១៩០៣ នៅឃុំស្វាយប៉ោ ស្រុកសង្កែ ខេត្តបាត់ដំបង។ កាលពីកុមារភាពលោករៀននៅវត្តពោធិវាល ស្រុកសង្កែ ដោយរៀនទាំងអក្សរជាតិ និងបានសិក្សាធម៌វិន័យ ហើយបន្ទាប់មកបានបួសជាសាមណេរ ដោយរៀនធម៌វិន័យ និងភាសាបាលីផងដែរ។ នៅឆ្នាំ១៩១៩ នៅពេលមានអាយុ១៥ឆ្នាំ លោកបានទៅបន្តវិជ្ជានៅបាងកក

ហើយបានរៀនជាប់សញ្ញាបត្រធម្មវិន័យថ្នាក់ត្រីនៅឆ្នាំ១៩២១ និងថ្នាក់ទោនៅឆ្នាំ១៩២៤។ ខាងផ្នែកភាសាបាលី លោកបានជាប់សញ្ញាបត្រខ្ពស់បំផុតនៅឆ្នាំ១៩២៩ ហើយនៅឆ្នាំ១៩៣០ លោក ញ៉ុក ថែម បានត្រឡប់មកភ្នំពេញវិញ ហើយបានចូលធ្វើជាសមាជិកគណៈកម្មការប្រែព្រះត្រៃបិដកនៅពុទ្ធសាសនបណ្ឌិត្យ។ នៅឆ្នាំ១៩៣៨ លោកធ្វើការនៅក្នុងព្រះរាជបណ្ណាល័យជាតិ។ ក្នុងឆ្នាំ១៩៥០ លោកបានចូលធ្វើការជាសាស្ត្រាចារ្យខ្មែរនៅវិទ្យាល័យព្រះស៊ីសុវត្ថិ បន្ទាប់មកធ្វើជាសាស្ត្រាចារ្យនៅវិទ្យាល័យព្រះមុនីវង្ស នៅវិទ្យាស្ថានគរុកោសល្យ និងនៅសាលាភូមិន្ទរដ្ឋបាល។

(២) លោក នូ ហាច កើតនៅឆ្នាំ១៩១៦ នៅឃុំកំពង់ព្រះ ស្រុកសង្កែ ខេត្តបាត់ដំបង។ កាលពីកុមារភាព លោកសិក្សានៅសាលាបឋមសិក្សាវត្តកំពង់ព្រះ ដែលមានគ្រូជាព្រះសង្ឃនៅសាលានេះ ហើយដែលលោកចេះអានសាស្ត្រាស្លឹករឹតយ៉ាងស្ទាត់ជំនាញ។ ឆ្នាំ១៩៣២ លោកបានប្រឡងជាប់ចូលរៀននៅវិទ្យាល័យព្រះស៊ីសុវត្ថិ ហើយលោកតស៊ូរៀនសូត្ររហូតបានទទួលសញ្ញាបត្រកម្រិតមធ្យមសិក្សា។ ហើយលោកចាប់ផ្តើមអាជីពរបស់លោកជាមេធាវីយុត្តិធម៌មួយរូប ដែលបំពេញការងារនៅក្នុងខេត្តសៀមរាប។ បន្ទាប់មក លោក នូ ហាច បានចូលបម្រើការងារនៅក្រសួងឃោសនាការទទួលបន្ទុកខាងការផ្សាយកាសែតកម្ពុជានៅឆ្នាំ១៩៤៧។ នៅឆ្នាំ១៩៥២ បានទៅធ្វើការនៅក្រសួង ការបរទេស ប្រធានផ្នែកកិច្ចការនយោបាយការបរទេស (Directeur en Direction des Affaires Politiques)។ ក្នុងការងារនេះ លោកត្រូវបានតែងតាំងឱ្យទៅបំពេញបេសកកម្មនៅបរទេសដូចជាទៅប្រទេសសៀម និងយូហ្គោស្លាវី។ ក្រោយមក រាជរដ្ឋាភិបាលបានដំឡើងឋានៈឱ្យលោកក្លាយជាឯកអគ្គរាជទូតខ្មែរប្រចាំនៅប្រទេសឥណ្ឌូនេស៊ី ប្រទេសវៀតណាម និងជាអ្នកតំណាងពិសេសប្រចាំ អង្គការសហប្រជាជាតិផងដែរ។

ឆ្នាំ១៩៥២ សម្តេចព្រះនរោត្តម សីហនុ បានតែងតាំងលោកនូ ហាច



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជារដ្ឋលេខាធិការ ក្រសួងសាធារណការ និងគមនាគមន៍។ នៅឆ្នាំ១៩៥៨ លោកបានចូលជាសមាជិកនៃសមាគមអ្នកនិពន្ធខ្មែរដែលបង្កើតឡើងនៅឆ្នាំ១៩៥៤ ដោយលោក រីម គីន។ លោក នូ ហាច ត្រូវបានគេស្គាល់បំផុតតាមរយៈស្នាដៃប្រលោមលោករបស់លោក រឿង«ផ្កាស្រពោន» ដែលបានបញ្ចូលក្នុងកម្មវិធីសិក្សានៅមធ្យមសិក្សានាឆ្នាំ១៩៥៨ ហើយបច្ចុប្បន្នរឿងនេះបានដាក់បញ្ចូលក្នុងកម្មវិធីសិក្សាថ្នាក់ទី៨។

### ២.២.១.២ ចរន្តអក្សរសិល្ប៍ប្រាកដនិយម និងរវើរវាយនិយម

នៅក្នុងរឿង«កូឡាបប៉ៃលិន» លោក ញ៉ុក ថែម ចង់បង្ហាញថា សេចក្តីតស៊ូក្នុងជីវិត ជាពិសេសជំហររឹងប៉ឹងរបស់ចៅចិត្រ ដោយវិជ្ជាសម្បត្តិ គុណសម្បត្តិ សមត្ថភាព និងសុខភាព ព្រមទាំងអំពើជាគុណប្រយោជន៍នៅក្នុងសង្គម គឺជាកត្តាសំខាន់នៅក្នុងជីវិត។ ថ្វីត្បិតតែចៅចិត្រជាកូនកំព្រា តែចៅចិត្រមានគុណសម្បត្តិដូចតទៅ ៖ មានចិត្តស្មោះត្រង់នឹងហ្វូងរតនសម្បត្តិ និងយុនទារីដែលជាចៅហ្វាយនាយ ជាមនុស្សទាន់សម័យ និយាយត្រង់ បានរៀនសូត្រចេះដឹង ចេះអត់ធ្មត់សេចក្តីលំបាកគ្រប់យ៉ាង ហ៊ានពុះពារឧបសគ្គ ជម្នះគ្រោះថ្នាក់ មានជំនាញខាងធ្វើឡាន និងចេះបើកឡាន ធ្វើការមិនរើសអើង និយាយសមហេតុផល មិនចេះខ្លាច មានសេចក្តីក្លាហាន ហ៊ានតស៊ូ ដើម្បីការពារជីវិតខ្លួន និងជីវិតស្ត្រីដែលខ្លួនស្រឡាញ់ ដោយអង់អាចក្លាហានឥតខ្លាចស្លាប់បន្តិចឡើយ។ ដូច្នេះ យើងអាចចាត់ទុករឿង«កូឡាបប៉ៃលិន»ថា ជាវណ្ណកម្មអក្សរសិល្ប៍ប្រាកដនិយម ដោយសារយើងជួបប្រទះនឹងតួអង្គនេះជាញឹកញយ នៅក្នុងសង្គមកម្ពុជា។ គុណសម្បត្តិទាំងនោះ គឺជាអ្វីដែលខ្មែរយើងហៅថា កូនប្រុសដើមទ្រូងប្រាំហត្ថ។

ទន្ទឹមនឹងនេះ យើងឃើញនូវលក្ខណសម្បត្តិរបស់ចៅចិត្តផ្សេងទៀតដែរ គឺចៅចិត្រមិនជឿលើព្រហ្មលិខិតទេ ហើយហ៊ានតស៊ូនឹងវាសនា និងហ៊ានតវ៉ានឹងព្រហ្មលិខិត។ ចៅចិត្រហ៊ានសារភាពស្រឡាញ់ចៅហ្វាយ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្រមុំរបស់ខ្លួន ទោះបីជាយល់ថាមិនសមគ្នាក៏ដោយ។ ម្យ៉ាងវិញទៀត ថៅ ចិត្រយល់ថា សេចក្តីស្នេហាក្នុងលោកមិនមានកម្រិតកំណត់ព្រំប្រទល់ឡើយ។ ថៅចិត្រប្រឆាំងនឹងទស្សនៈ«ខ្លួនទាបកុំតោង ដៃខ្លីកុំឈោងស្រវាឱបភ្នំ» ដោយ ហ៊ានសារភាពស្នេហាជាមួយយុវនារី ថាស្រឡាញ់នាងជាងជីវិតខ្លួន ហើយ យកខ្លួនទៅរាំងគ្រាប់កាំភ្លើង ដើម្បីការពារនាង។ ត្រង់នេះ អ្នកនិពន្ធចង់ បង្ហាញថា យុវវ័យតែងតែមានចរិតរវើរវាយដែលយើងអាចចាត់ទុកថា រឿង «កូឡាបប៉ៃលិន»ក៏មានលក្ខណៈជាអក្សរសិល្ប៍រវើរវាយនិយមផងដែរ។

ក្នុងរឿង«ផ្កាស្រពោន» បញ្ហាសំខាន់ដែលលោក នូ ហាច លើកមក ចោទសួរ គឺរឿងស្នេហាស្មោះរវាង ប៊ុន ធឿន និងវិធាវី ដែលឪពុក និងឪពុក ដែលជាភ្ញៀវម្រាក់ចិត្តមួយបានផ្តែផ្តាំទុកដាក់ជាគូ តែត្រូវម្តាយនាងវិធាវី យាយ នួន បានលើកទៅឱ្យនាយ ណៃសឹត ដែលជាកូនថៅកែកាណូតវិញ នៅ ពេលដែលចិក ប៊ុន ថន ជាឪពុក ប៊ុន ធឿន ធ្លាក់ខ្លួនក្រ ដោយសារមាន គ្រោះថ្នាក់លិចទូកកណ្តាលទន្លេ។ នាយ ប៊ុន ធឿន គឺគ្មាននរណាក្រៅពី លោក នូ ហាច ទេ។ ប៊ុន ធឿន កើតនៅភូមិកំពង់ព្រះ ដែលជាភូមិកំណើត របស់អ្នកនិពន្ធ ស្រឡាញ់ការសិក្សា តស៊ូរៀនសូត្រ ចូលចិត្តអានសៀវភៅ ជាពិសេសសៀវភៅកវីបារាំង។ តាមរយៈរឿង«ផ្កាស្រពោន»នេះ យើង ឃើញថា ស្នាដៃតែងនិពន្ធរបស់លោក នូ ហាច បានឈានទៅដល់កម្រិត វណ្ណកម្មក្លាសិកខ្មែរ ដែលមិនចាញ់រឿងប្រលោមលោកបារាំងទេ។ រឿងនេះ បង្ហាញផងដែរនូវឥទ្ធិពលបារាំង (អ្នកស្រុកទៅលេងបុណ្យជាតិបារាំង) និងឥទ្ធិពលសៀម (វិធាវីរៀនភាសាសៀម) នៅក្នុងសង្គមខ្មែរជំនាន់នោះ។ ការឱ្យតម្លៃលើស្នេហាបរិសុទ្ធ ហើយទស្សនៈដែលថានៅក្នុងលោកនេះគ្មាន អ្វី ដែលធំជាងស្នេហានោះ គឺជារឿងអណ្តែតអណ្តូងនិយម ហើយថែមទាំង មានលក្ខណៈឧត្តមគតិនិយមផងដែរ។

យាយ នួន ជាម្តាយ វិធាវី គឺជាតួអង្គតំណាងឱ្យវណ្ណៈអភិជនស្រុក ស្រែ។ គាត់ជាស្ត្រីរឹងប៉ឹង នេត្រាមានពន្លឺថ្លាយង់ តែមានចិត្តរឹងរូសមានះ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ណាស់។ បើគំនិតគាត់បែរចាប់អ្វីហើយ គ្មាននរណាងាយនឹងដកគំនិតនោះយកមកបានទេ។ គាត់ខំការពារទ្រព្យធនទាំងអស់ទុកឱ្យកូនស្រី ដែលគាត់មានសេចក្ដីប្រតិព័ទ្ធលើសលប់ជាងអ្វីៗ។ គាត់យល់ថា ទ្រព្យសម្បត្តិអាចដោះស្រាយនូវអ្វីៗទាំងអស់ក្នុងសង្គម រួមទាំងផ្ដល់សុភមង្គលឱ្យកូនផង។ «កូនអើយ ឯងកុំអាក់អន់ថ្វី ចូរនាងរក្សាចិត្តឱ្យហ្នឹងហ្ន បំភ្លេច ប៊ុន ធឿនចោលទៅ។ ដល់ថ្ងៃក្រោយទៅ លុះនាងបានប្រកបតែសុវត្ថិភាព និងសុភមង្គល នាងនឹងនឹកឃើញថា ម៉ែគាត់និយាយត្រូវមែន»។ យើងសង្កេតឃើញថា តួអង្គបែបនេះមានច្រើននៅក្នុងសង្គមខ្មែរបុរាណ។ ដូច្នេះ រឿង«ផ្កាស្រពោន» អាចចាត់ទុកថាជាវណ្ណកម្មអក្សរសិល្ប៍ប្រាកដនិយម។

### ២.២.១.២ សិល្បវិធីតែងនិពន្ធ

អត្តរូបនៃអក្សរសិល្ប៍ខេមរនិយម គឺជាសិល្បវិធី ក្នុងការតែងនិពន្ធដើម្បីបង្ហាញពីភាពសប្បាយរីករាយ ឬទុក្ខព្រួយរបស់តួអង្គ ការចាប់ផ្ដើមរឿង និងការបញ្ចប់រឿងជាដើម។ ក្នុងការតែងនិពន្ធ អ្នកនិពន្ធប្រើប្រាស់នូវសិល្បវិធីជាច្រើនដូចជា វចនវិធី(ការប្រើពាក្យ) រចនាវិធី(ការប្រើឃ្លាល្បះទាក់ទាញ) ឧបមានវិធី(ប្រៀបធៀបតួអង្គទៅនឹងអ្វីមួយ) សំវាទវិធី(តួអង្គឆ្លើយឆ្លងគ្នា) សន្ទេហវិធី(ធ្វើឱ្យចង់តាមដាន) ឯកវាទវិធី(និយាយតែម្នាក់ឯង) វណ្ណនាវិធី(លើកតួអង្គ ធម្មជាតិមកពណ៌នាដូចឃើញនឹងភ្នែកស្រស់) បដិវិធី(តួអង្គខុសគ្នា)ជាដើម។

អក្សរសិល្ប៍ខេមរនិយមបង្ហាញផងដែរនូវលក្ខណៈធម្មជាតិ លក្ខណៈមនុស្ស និងលក្ខណៈសង្គម។ ក្នុងរឿង«ផ្កាស្រពោន» លោក នូ ហាច លើកលក្ខណៈធម្មជាតិ មកបង្ហាញមនោសញ្ចេតនារបស់នាង វិធាវី ៖ «មានយប់មួយនៅវេលាអធ្រាត្រ នាងវិធាវីដែលនិទ្រាមិនលក់សោះនោះ ក៏ក្រោកឡើងបើកបង្អួចក្បាលដំណេក។ ខ្យល់ត្រជាក់បោកក្លិនរុក្ខជាតិស្គុះចូលមកអង្អែលភក្ត្រានាង។ នៅខាងក្រៅ លោកខែបញ្ចាំងរស្មីទន់ត្រជាក់ដូចព្រៃ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មកគ្របដណ្ដប់លើសាកលទ្វីប។ នៅក្នុងមេឃពណ៌ខៀវថ្លាត្រយង់ ដុំពពកសៗដូចកប្បាសរសាត់បន្តគ្នា ជួនកាលមកបាំងវង់ព្រះចន្ទ បណ្ដាលឱ្យស្រទំស្អាប់មួយភ្លែត។ កាលណាពពកនោះអណ្ដែតផុតទៅ ពន្លឺពជិនីនៃរាត្រីមកពាំងលើផាងដូង ដែលយោលរេរាដោយវាយោ ហើយដែលភ្លឺភ្លែតៗដូចជាបន្ទះដែកស្និត»។

**២.២.២ អត្ថន័យនៃអក្សរសិល្ប៍ខេមរនិយម**

ន័យសេចក្ដីដ៏សំខាន់បំផុតនៃអក្សរសិល្ប៍ខេមរនិយម គឺបង្ហាញពីឧត្ដមគតិរបស់អ្នកនិពន្ធ ដោយលើកយកបញ្ហាជីវិតជាក់ស្ដែងក្នុងសង្គមខ្មែរមកចោទ និងដោះស្រាយ។ បញ្ហាទាំងនោះឆ្លុះបញ្ចាំងពីសង្គមខ្មែរ បញ្ហាជីវភាពរស់នៅ បញ្ហាទំនៀមទម្លាប់ ប្រពៃណី បញ្ហាស្នេហារវាងតួប្រុសនិងតួស្រី បញ្ហាសង្គម ដែលទាក់ទងនឹងអ្នកមាននិងអ្នកក្រ និងការប្រកាន់វណ្ណៈក្នុងសង្គមជាដើម។ ក្នុងការដោះស្រាយបញ្ហាទៀតសោត អក្សរសិល្ប៍ខេមរនិយម តួអង្គពឹងផ្អែកលើសមត្ថភាពផ្ទាល់ខ្លួន ដោយគ្មានអន្តរាគមន៍របស់ព្រះ។ ឧត្តមគតិនៃអក្សរសិល្ប៍ខេមរនិយមផ្ដោតលើការអប់រំ ដោយយកតម្លៃមនុស្សជាធំឱ្យខំប្រឹងតស៊ូ ខិតខំប្រឹងប្រែងធ្វើខ្លួនឱ្យថ្លៃថ្នូរ ខិតខំរៀនសូត្រ និងជឿជាក់លើខ្លួនឯង។ នៅក្នុងរឿង«កុលាបប៉ៃលិន» មុននឹងលាចាកលោកនេះទៅ តា ចឹម បានផ្ដែផ្ដាំទៅចៅ ចិត្រ ថា ៖ «ធម្មជាតិគ្រប់យ៉ាងក្នុងលោកនេះ ដែលមនុស្សលោកសម្គាល់ថា ជាការរុងរឿងថ្លៃថ្លានោះ គឺជាការតាំងខ្លួនប្រាណឱ្យបានថ្លៃថ្នូរ ស្អុកស្កម្ភ»។ នៅក្នុងរឿង«ផ្កាស្រពោន» ចិក ប៊ុន ថន បានផ្ដែផ្ដាំទៅ ប៊ុន ធឿន ថា ៖ «ឪពុកដឹងចិត្តកូនឯងចង់លែងរៀន ដើម្បីមកជួយធ្វើការឪពុកម្ដាយ។ គំនិតនេះគាប់ប្រសើរហើយ តែចិត្តឪពុកមិនចង់ឱ្យឯងឈប់រៀនទេ ស៊ូត្រដេត្រដរផ្ដល់សោហ៊ុយឱ្យឯងរៀនលុះត្រាតែបានឌីប្លូម»។

ទស្សនវិជ្ជានៃអក្សរសិល្ប៍ខេមរនិយមមានគោលដៅពន្យល់ពីរឿង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

រ៉ាវក្នុងសង្គមខ្មែរនៅសម័យឯករាជ្យ ដោយផ្ដោតលើចំណុចសំខាន់ៗដូចតទៅ ៖

១. **ទ្រឹស្ដីអត្តា ហិអត្តនោ នាថោ** គឺជាទ្រឹស្ដីខ្លួនត្រូវទីពឹងខ្លួនតែប៉ុណ្ណោះ ពោលគឺតួអង្គត្រូវចេះខំប្រឹងប្រែងកសាងជីវភាពខ្លួនឱ្យបានចម្រើន ឱ្យមានជំហររឹងប៉ឹងដោយវិជ្ជាសម្បត្តិ គុណសម្បត្តិ សមត្ថភាព ទ្រព្យសម្បត្តិ និងសុខភាព ទើបអាចរស់នៅក្នុងសង្គមមនុស្សបានថ្លៃថ្នូរ ហើយអាចផ្ដល់បាននូវអត្ថប្រយោជន៍ដល់សង្គម ឱ្យបានចម្រើនឡើងទៀតផង។

២. **ទ្រឹស្ដីជាតិនិយមខ្មែរ** គឺយើងម្នាក់ៗត្រូវខំបំពេញករណីយកិច្ចរបស់ខ្លួនចំពោះខ្លួនឯង ចំពោះសង្គម ចំពោះជាតិ សាសនា ព្រះមហាក្សត្រ ដែលជាឧត្តមគតិរបស់ពលរដ្ឋជាតិខ្មែរ។

៣. **ទស្សនៈនំមិនធំជាងនាឡិ ៖** ទោះបីជានាង វិធាវី ស្រឡាញ់ ប៊ុនធឿន យ៉ាងណាក្ដី ក៏នាងមិនហ៊ានជំទាស់នឹងចិត្តរបស់ម្ដាយនាង។

៤. **ការតស៊ូគង់តែនឹងបានសម្រេច** ៖ ការតស៊ូរបស់ចៅចិត្រ ជម្នះគ្រប់ឧបសគ្គបានធ្វើឱ្យចៅចិត្រអាចឈោងទៅបេះផ្កាកុលាបដ៏ស្រស់បំព្រងបីដូចជាបេះផ្កាយលើមេឃផងដែរ។

## ២.២.៣ អត្ថរសនៃអក្សរសិល្ប៍ខេមរនិយម

អត្ថរស គឺជាតម្លៃនៃស្នាដៃអក្សរសិល្ប៍ខេមរនិយមដែលបង្ហាញពីសង្គមខ្មែរ។ អត្ថរសនៃអត្ថបទអក្សរសិល្ប៍ខេមរនិយមអាចចែកចេញជា ៖

ទីមួយ **បច្ចេករស** ដោយប្រើប្រាស់ពាក្យកាព្យ និងរៀបចំជាដំណើររឿងឱ្យមានភាពអណ្ដែតអណ្ដូង ឱ្យអ្នកអានរំភើបតាមដំណើររឿង។

«ចៅចិត្រ ចោលភ្នែកក្រឡេកទៅប្រទះនឹងភ្នែកទាំងគូ កំពុងតែសម្លឹងចំត្រង់មក ជាដួងភ្នែកប្រកបដោយទឹកដម គួរជាទីចាប់ចិត្តស្នេហា តែមានឫកពាឆ្មើងឆ្មៃបន្តិច មានកិរិយាក្អិកក្អក់ ព្រៀងញ៉ង ស្វាសល្វន់ល្អណាស់ សម្បុរស្បែកសស្អាត មុខមូលក្រឡង់ដូចវង់ព្រះចន្ទ សូរសំឡេងស្រួយស្រស់ដូចសូរគាំងប្រាក់



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដំណើរល្វាសល្វន់ដូចផ្កាកុលាប ដែលត្រូវខ្យល់បក់លិចៗនៅកណ្តាលសួនច្បារ ដូច្នេះ ឱល្អម្ល៉េះ! នេះប្រហែលជាអញយល់សប្តិឃើញទេដឹង?»

*ទីពីរ **វិសេសរស** ដោយបង្ហាញពីតម្លៃល្អ តម្លៃអាក្រក់ សកម្មភាពអស្ចារ្យ វីរភាព សកម្មភាពតស៊ូរបស់តួអង្គ សោកនាដកម្ម និងសកម្មភាពរស់រវើក ដើម្បីឱ្យអ្នកអានរីករាយ។ តើចៅចិត្រមានលក្ខណៈពិសេសអ្វីដែលធ្វើឱ្យយុវនារី ចាប់ចិត្តប្រតិព័ទ្ធ? ហេតុអ្វីបានជាយុវនារីមិនស្រឡាញ់លោកបាឡាត់ស្រុកសង្កែ? តួអង្គចៅចិត្រ គឺជាតំណាងយុវជនខ្មែរជំនាន់ថ្មីដែលមានការអប់រំល្អ មានចិត្តស្មោះត្រង់ មានសេចក្តីក្លាហាន ប៉ិនប្រសប់ចេះធ្វើការងារគ្រប់សព្វសារពើ ហ៊ានយកខ្លួនទៅរងគ្រាប់កាំភ្លើង ដើម្បីការពារនារីដែលខ្លួនស្រឡាញ់ ខុសពីលោកបាឡាត់ ដែលកំសាក ទុច្ចរិត។*

*លក្ខណៈពិសេសរបស់នាងវិធាវី ក្នុងរឿង«ផ្កាស្រពោន» គឺនាងហ៊ានលះបង់ជីវិតដើម្បីស្នេហាស្មោះ ថ្វីត្បិតតែនាងមិនព្រមរើបម្រះប្រឆាំងនឹងសណ្តាប់ធ្នាប់សង្គមខ្មែរជំនាន់នោះ។*

*ទីបី **សព្វរស** ដោយចុះបញ្ចាំងពីតថភាពក្នុងសង្គម សោភ័ណ និងកុសលរសដែលជាតម្លៃនៃការទូន្មានប្រៀនប្រដៅ។ ដើម្បីឱ្យមានភាពទាក់-ទាញ អ្នកនិពន្ធបានរៀបចំអក្សរសិល្ប៍ខេមរនិយមនេះ ជាការតែងនិពន្ធដែលមានសោភ័ណផ្សេងៗដូចតទៅ៖*

*__១. សោភ័ណខាងវោហារសាស្ត្រ__ ៖ ក្នុងអក្សរសិល្ប៍ខេមរនិយម អ្នកនិពន្ធខ្មែរអាចរៀបរាប់ដោយលេងពាក្យ ឱ្យណែងណង ឱ្យមានសំឡេងរណ្តំ។ នេះគឺជាអត្ថបទក្នុងរឿង«ផ្កាស្រពោន» ដែលមានឈ្មោះថាមាគ៌ាទៅកាន់អង្គរ ៖*

«នៅក្នុងព្រៃដែលដុះព័ទ្ធបុរាណប្រាសាទនានា មានរបស់ពីរយ៉ាងដែលនាំបង្អើតដួងចិត្តទេសចរ ឱ្យរីងរឹតតែស្រងេះស្រងោចខ្លោចផ្សា ដោយសេចក្តីស្តាយអាល័យដល់កេរ្តិ៍ស្នាដៃនៃបុព្វបុរសខ្មែរ។ វត្ថុនោះហាក់ដូចជាខ្យល់ព្រលឹង និងសំឡេងនៃប្រវត្តិមាតុភូមិយើង។

ពេលរសៀល! វេលាដែលព្រះសុរិយាកំពុងដុតចំហុយអស់ទាំងធម្មជាតិរៃកណ្ដឹងយំទម្លាក់សំឡេងពីចុងស្រឡៅ ឬចុងឈើទាលដែលខ្ពស់ត្រដែតក្នុងអាកាស។ សព្ទតូរ្យតន្ត្រីចម្លែកនេះ ជ្រាបចូលសព្វសព៌ាង្គកាយ ហើយមករុំស្រោបបេះដូង នាំឱ្យអ្នកដំណើរទាំងពួងយន់ចិត្តអាសូរដល់ស្រុកកំណើតដែលធ្លាប់ថ្កុំថ្កើង។

នៅខែចេត្រនិងពិសាខ តាមផ្លូវពីក្រុងសៀមរាបទៅអង្គរ ផ្កាវំដួលបញ្ចេញរំភើយពិដោរក្រអូបឈ្ងុយ។ បើជួនវាមានវាយោបក់បន្តិចៗផង អ្នកដែលដើរយកអាកាសពេលល្ងាចតាមថ្នល់នេះនឹងមានចិត្តរសាប់រសាយអណ្ដែតអណ្ដូងប្រហែលជានឹងលាន់មាត់ថា ទោះជាឋានតុសិត ក៏មិនសប្បាយជាជាងនេះមើលទៅ។

ឱក្លិនវំដួល! ឱសំឡេងរៃ! កម្លាំងអ្នកដូចជាទិព្វឱសថដែលអាចចូលមករំលាយសេចក្ដីសោកសង្រេងបានមួយពេលបាន»។

២. *សោភ័ណខាងគំនិតខ្មែរ ៖ អត្ថបទអក្សរសិល្ប៍ខេមរនិយម បង្ហាញពីគំនិតខ្មែរ ដែលអ្នកនិពន្ធត្រូវលើកយកប្រធានបទនៃសង្គមខ្មែរមកបកស្រាយ ក្នុងគោលដៅទូន្មានកូនចៅ ឱ្យចេះត្រៀមខ្លួនក្នុងជីវិត ៖*

- *យុវជនត្រូវមានសមត្ថភាពវិជ្ជាជីវៈ មានចំណេះដឹង និងមានបំណិន*
- *យុវជនត្រូវចេះតស៊ូក្នុងជីវិត*
- *យុវជនត្រូវបំពេញភារកិច្ចរបស់ខ្លួនចំពោះសង្គមនិងប្រទេសជាតិ*
- *យុវជនត្រូវចេះគិតពីប្រយោជន៍រួម*
- *យុវជនត្រូវមានភាពស្មោះត្រង់នឹងប្រទេសជាតិ និងស្មោះនឹងស្នេហា*
- *យុវជនត្រូវមានភាពរឹងប៉ឹង*
- *យុវជនត្រូវរក្សាភាពថ្លៃថ្នូរ*

*យុវជនត្រូវមានសុខភាពល្អ។*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ផ្នែកទី២
## ឥណ្ឌាភារូបនីយកម្មកម្ពុជា
## តាមរយៈអក្សរសិល្ប៍ព្រាហ្មណ៍និយម

*គោលដៅនៃបាឋកថានេះ គឺការវិភាគការចូលរួមវិភាគទាននៃវប្បធម៌ឥណ្ឌា នៅក្នុងវប្បធម៌ខ្មែរ ដើម្បីឱ្យកូនខ្មែរជំនាន់ក្រោយបានយល់ដឹងចេះឱ្យតម្លៃលើទ្រព្យសម្បត្តិដ៏សម្បូណ៌បែបរបស់ខ្លួន និងចូលរួមអភិរក្សរក្សាមត៌កនេះ ទុកដល់ជនានុជនជំនាន់ក្រោយៗ ដើម្បីសម្រេចគោលដៅនេះ ខ្ញុំចោទជាសំណួរដូចខាងក្រោម ៖*

*ទី១-តើអ្វីទៅជាឥណ្ឌាភារូបនីយកម្ម? តើខ្មែរមានវប្បធម៌របស់ខ្លួនមុនការហូរចូលនៃវប្បធម៌ឥណ្ឌាដែរ ឬយ៉ាងណា?*

*ទី២-ហេតុអ្វីបានជារឿងរាមកេរ្តិ៍បានចាក់ឫសចូលសង្គមខ្មែរយ៉ាងជ្រៅ? តែផ្ទុយទៅវិញ ប្រជាជនខ្មែរមិនសូវចាប់អារម្មណ៍លើរឿងមហាភារតៈរបស់ឥណ្ឌាឡើយៗ*

*ដើម្បីឆ្លើយទៅនឹងសំណួរខាងលើ ខ្ញុំសូមចែកបាឋកថានេះជាពីរផ្នែក ៖ (១) ទិដ្ឋភាពទូទៅនៃឥណ្ឌាភារូបនីយកម្ម ដែលចែកចេញជា ៖ (ក) វប្បធម៌ខ្មែរមុនការហូរចូលនៃវប្បធម៌ឥណ្ឌា និង (ខ) តួនាទីពាណិជ្ជកម្ម និងសាសនានៅក្នុងឥណ្ឌាភារូបនីយកម្ម និង (២) វិភាគទានអក្សរសិល្ប៍ព្រាហ្មណ៍និយមក្នុងឥណ្ឌាភារូបនីយកម្ម ដែលចែកចេញជា ៖ (ក) ឥទ្ធិពលអក្សរសិល្ប៍ឥណ្ឌាទៅលើចម្លាក់បុរាណខ្មែរ និង (ខ) ឥទ្ធិពលអក្សរសិល្ប៍ឥណ្ឌាទៅលើអក្សរសិល្ប៍ព្រាហ្មណ៍និយមខ្មែរៗ*



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

## I. ទិដ្ឋភាពទូទៅនៃឥណ្ឌាភាវូបនីយកម្ម

### ១.១ វប្បធម៌ខ្មែរមុនការហូរចូលនៃវប្បធម៌ឥណ្ឌា

មុនការហូរចូលនៃវប្បធម៌ឥណ្ឌា ខ្មែរមានវប្បធម៌ និងអរិយធម៌របស់ខ្លួនរួចមកហើយ។ កម្ពុជា គឺជាប្រទេសបរមបុរាណ ដែលមានវប្បធម៌ និងអរិយធម៌របស់ខ្លួន។ មុនការទទួលយកការគោរពប្រតិបត្តិពីសាសនាមកពីប្រទេសឥណ្ឌា ពលរដ្ឋខ្មែរគោរពប្រតិបត្តិអ្នកតា ដែលមានរូបរាងជាដុំថ្មផ្សេងៗ។ បន្ទាប់មក វប្បធម៌ និងអរិយធម៌នេះទទួលរងនូវឥទ្ធិពលពីលទ្ធិនៃព្រហ្មញ្ញសាសនា និងពុទ្ធសាសនា។ ដូច្នេះ អរិយធម៌ខ្មែរ គឺជាលទ្ធផលនៃការស្ទូ និងច្របាច់បញ្ចូលគ្នាក្នុងរយៈពេលជាច្រើនសតវត្សរ៍រវាងអរិយធម៌ខ្មែរបុរាណ និងអរិយធម៌បរទេស ដែលមានដើមប្រភពពីឥណ្ឌា បស្ចិមប្រទេស និងចិន។ យើងឃើញថា ក្នុងការវិភាគពីអរិយធម៌ខ្មែរ គេឃើញមានទស្សនៈពីរខុសគ្នា ៖ ទស្សនៈទីមួយ គឺអរិយធម៌ខ្មែរមានឥទ្ធិពលពីឥណ្ឌា ហើយទស្សនៈទីពីរ គឺខ្មែរបានយកវប្បធម៌ពីឥណ្ឌា ដើម្បីយកមកស្ទូឱ្យទៅជារបស់ខ្មែរ។

អ្នកស្រាវជ្រាវដែលប្រកាន់យកទស្សនៈទី១ យល់ឃើញថា ៖ មូលដ្ឋាននៃអរិយធម៌ខ្មែរស្ថិតនៅក្នុងទស្សនវិជ្ជានៃសាសនា ដែលជនជាតិខ្មែរទទួលយកជាបន្តបន្ទាប់ ឬក្នុងពេលតែមួយ ដូចជាវេទនិយម ព្រាហ្មណ៍និយម ហិណ្ឌូនិយម និងពុទ្ធនិយម។ មូលដ្ឋាននេះតែងតែវិវត្តជាលំដាប់ទៅតាមដំណាក់កាលនៃប្រវត្តិសាស្ត្រកម្ពុជា។ ដូច្នេះការសិក្សាវប្បធម៌ និងអរិយធម៌ខ្មែរទាមទារឱ្យយល់ពីព្រហ្មញ្ញសាសនា និងពុទ្ធសាសនា ដែលខ្មែរទទួលពីឥណ្ឌាផងដែរ។

លោកសាស្ត្រាចារ្យ កេង វ៉ាន់សាក់ ជាអ្នកប្រកាន់យកទស្សនៈទី២។ នៅក្នុងនិក្ខេបបទដែលមានចំណងជើងថា «ការស្រាវជ្រាវនៃឫសគល់វប្បធម៌ខ្មែរ» លោកសាស្ត្រាចារ្យ កេង វ៉ាន់សាក់ បានលើកឡើងពីសម្មតិកម្មថា ៖ «វប្បធម៌ខ្មែរ គឺជាវប្បធម៌ ចម្រុះ ដែលច្របាច់បញ្ចូលនូវមូលដ្ឋានក្នុងស្រុក



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

(វប្បធម៌ខ្មែរ-មន ដែលមានសមាសធាតុនៃវប្បធម៌អូស្ត្រូអាស៊ី) និងវិភាគទានពីបរទេស ជាពិសេសពីឥណ្ឌា បស្ចិមប្រទេស និងចិន»។ លោកបន្តទៀតថា ៖ «[អក្សរសិល្ប៍ខ្មែរ-ឥណ្ឌា] បានអនុញ្ញាតឱ្យខ្ញុំយល់យ៉ាងច្បាស់ពីទំនាក់ទំនងពិតៗដែលមានលក្ខណៈមិនត្រឹមតែខុសគ្នាទេ តែផ្ទុយគ្នារវាងអក្សរសិល្ប៍ឥណ្ឌា និងខ្មែរ។ អ្វីដែលអង្រួនខ្ញុំឱ្យភ្ញាក់ពីដំណេក គឺខ្ញុំតែងតែជឿថា ឥណ្ឌា និងខ្មែរអាចប្រៀបប្រដូចទៅនឹងការរៀបអាពាហ៍ពិពាហ៍នឹងគ្នា។ ខ្ញុំចាប់ផ្តើមភ្ញាក់ខ្លួនបន្តិចម្តងៗ រហូតដល់ពេលមួយ ដែលខ្ញុំរកឃើញរចនាសម្ពន្ធនៃភាសាខ្មែរ ដែលធ្វើឱ្យខ្ញុំលែងស្រមើស្រមៃទៀត ហើយចាប់ផ្តើមមើលឃើញនូវការផ្ទុយគ្នា និងការខុសគ្នាជាមូលដ្ឋានរវាងវប្បធម៌ទាំងពីរ ៖ គឺឥណ្ឌា និងខ្មែរ»។ ពោល សាស្ត្រាចារ្យ កេង វ៉ាន់សាក់ បានទាត់ចោលសម្មតិកម្មរបស់លោក George Coedès ដែលថា៖ «ខ្មែរគឺជាជនជាតិកួយដែលទទួលយកវប្បធម៌ឥណ្ឌា»។

ក៏ប៉ុន្តែ សាស្ត្រាចារ្យ កេង វ៉ាន់សាក់ មិនបានទាត់ចោលនូវការចូលរួមនៃវប្បធម៌ឥណ្ឌាក្នុងការបង្កើតវប្បធម៌ខ្មែរឡើយ។ លោកចែកវប្បធម៌ជាពីរផ្នែក ៖ វប្បធម៌ខាងផ្នែកសម្ភារ និងវប្បធម៌ខាងផ្នែកគំនិតស្មារតី។ លោកលើកឡើងថា លោក Jean Delvert (Le paysan cambodgien) និង លោកស្រី Éveline Porée-Maspero (Étude sur les Rites agraires des Cambodgiens) បានសិក្សាវប្បធម៌ខ្មែរខាងផ្នែកសម្ភារយ៉ាងល្អិតល្អន់ហើយ។ ដោយឡែកចំពោះវប្បធម៌ខាងផ្នែកគំនិតស្មារតី លោកបានចែកចេញជាពីរផ្នែកគឺ ៖ ទី១-វិភាគទានឥណ្ឌាក្នុងវប្បធម៌ និងអរិយធម៌ខ្មែរ តាមរយៈសាសនាព្រាហ្មណ៍ និងពុទ្ធសាសនាមហាយាន និងភាសាសំស្ក្រឹត និងពុទ្ធសាសនាថេរវាទ និងភាសាបាលី និង ទី២-វប្បធម៌ខ្មែរសុទ្ធសាធ ដែលមានតាំងតែពីជំនាន់ហ្វូណន ហើយដែលស៊ូជាមួយវប្បធម៌ឥណ្ឌា ដែលជំរុញឱ្យខ្មែរអាចឈានដល់ភាពរីកចម្រើនដូចជំនាន់អង្គរ។

បណ្ឌិត មីសែល ត្រាណេ បានយកសម្មតិកម្មរបស់សាស្ត្រាចារ្យ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កេង វ៉ាន់សាក់ ទៅធ្វើការស្រាវជ្រាវបន្ថែម និងបានធ្វើសេចក្តីសន្និដ្ឋានថា៖ «វប្បធម៌ខ្មែរដែលបានប្រសូតឡើងនាដើមសម័យប្រវត្តិសាស្ត្រក្រោមឥទ្ធិពលឥណ្ឌានោះ គឺជាវប្បធម៌មួយដែលប្រកបដោយលក្ខណៈសំយោគរវាងសមាសធាតុមន-ខ្មែរ និងឥណ្ឌា។ មុនមានលំហូរវប្បធម៌បរទេស អ្នកស្រុកនៃជ្រោយសុវណ្ណភូមិមានវប្បធម៌ដើមរបស់ខ្លួនរួចហើយ ដូចយើងឃើញតាមរយៈកំណាយនៃស្ថានីយល្អាងស្ពាននៅខេត្តបាត់ដំបង សំរោងសែននៅខេត្តកំពង់ឆ្នាំង ស្ថានីយយុគថ្ម ក្រូសបំបែក នៅខេត្តក្រចេះ និងស្ទឹងត្រែងជាដើម។ នៅលើមូលដ្ឋានគ្រឹះដ៏រឹងមាំរបស់ដូនតាទាំងនោះ ដែលមានអាយុកាលរាប់ពាន់សែនឆ្នាំមុនគ.ស. ទើបធាតុឥណ្ឌាបានចាប់ពន្លកពីលើចាប់តាំងពីស.វ.ទី១ដល់ស.វ.ទី១២ ដោយបាននាំមកនូវការអភិវឌ្ឍដ៏ឧត្តុង្គឧត្តមគ្រប់វិស័យ។ ក៏ប៉ុន្តែ នៅពេលដែលឥទ្ធិពលឥណ្ឌាមកដល់ប្រជាជនខ្មែរពុំទាន់មានអក្សរនៅឡើយទេ។ សំណេរប្រវត្តិសាស្ត្រខ្មែរចាប់បដិសន្ធិឡើងនៅដើមស.វ.ទី១ ដោយទទួលនូវឥទ្ធិពលរបស់ឥណ្ឌា ហើយបង្កើតបានអក្សរជាតិតាមលំនាំឥណ្ឌា។ ឥទ្ធិពលឥណ្ឌាក៏បាននាំមកនូវរបបនយោបាយរាជាធិបតេយ្យដូចឥណ្ឌា។

វប្បធម៌ឥណ្ឌា និងចិនចូលកម្ពុជាចាប់តាំងពីសតវត្សទី១នៃគ.ស. ហើយលើកទី២ នៅសតវត្សទី៣នៃគ.ស. ក្នុងរជ្ជកាលព្រះបាទអសោក។ នៅអាស៊ីអាគ្នេយ៍នៅពេលនោះមានអាណាចក្រធំៗពីរ គឺ ហ្វូណន និងចម្ប៉ា ដែលទទួលយកព្រហ្មញ្ញសាសនា។

បើតាមការស្រាវជ្រាវរបស់បណ្ឌិត មីសែល ត្រាណេ វប្បធម៌ និងអារ្យធម៌ខ្មែរមានតាំងពីសម័យបុរេប្រវត្តិ ហើយបានជួបនឹងវប្បធម៌ចិន មុននឹងមានការហូរចូលនៃវប្បធម៌ឥណ្ឌានាដើមស.វ.ទី១នៃគ.ស.។ ទំនាក់ទំនងខ្មែរ និងចិនឆ្លុះបញ្ចាំងតាមរយៈស្គរមហោធិក ឬស្គរអារក្សហៅទឹកភ្លៀងដែលគេបានរកឃើញនៅក្នុងចក្រភពបុរេអង្គរ ក៏ដូចជាក្បាច់ក្បូរលម្អលើវត្ថុសិល្បៈមួយចំនួន ដូចជាជួង កាំបិត កងដៃ កងជើងជាដើម។ ការផ្សព្វ-

ផ្សាយវប្បធម៌ឥណ្ឌាប្រព្រឹត្តទៅតាមពីរផ្លូវ ៖ (១) គឺតាមរយៈពួកឈ្មួញ ដែលខិតខំរៀនសូត្រភាសាអ្នកស្រុកដើម ហើយខ្លះក៏បានរៀបមង្គលការជាមួយជនជាតិដើម និង (២) គឺតាមរយៈសាសនា និងពួកបញ្ញវន្តខ្មែរក្នុងវណ្ណៈខ្ពស់។

## ១.២ តួនាទីពាណិជ្ជកម្ម និងសាសនានៅក្នុងឥណ្ឌាភាវូបនីយកម្ម

ឥណ្ឌាភាវូបនីយកម្ម ឬការទទួលធាតុផ្សេងៗនៃវប្បធម៌ឥណ្ឌាបានកើតមានឡើងចាប់តាំងពីស.វ.ទី១មុនគ.ស.មកម្ល៉េះ ពោលគឺក្នុងពេលជាមួយគ្នានឹងពាណិជ្ជកម្មជាមួយចិនដែរ ដោយឈរលើមូលដ្ឋាននៃការវិភាគវត្ថុសិល្បៈបុរាណ ដូចជាអង្កាំ កុលាលភាជន៍ និងកំណាត់ហេតុផ្សេងៗ។ នរវិទូបានបែងចែកឥណ្ឌាភាវូបនីយកម្មជាពីរប្រភេទ ៖ ប្រភេទទី១ គឺតាមរយៈការប្រើប្រាស់ភាសាសំស្ក្រឹត ច្បាប់ និងព្រហ្មញ្ញសាសនា និងប្រភេទទី២ គឺតាមរយៈស្រុកភូមិ ទំនៀមទម្លាប់ និងជំនឿអ្នកស្រុក។

តួនាទីពាណិជ្ជកម្មនៃឥណ្ឌាភាវូបនីយកម្ម ៖ ពាណិជ្ជកម្មដើរតួនាទីយ៉ាងសំខាន់ក្នុងការហូរចូលនៃវប្បធម៌ឥណ្ឌា។ អាណាចក្រភ្នំ គឺជាអាណាចក្រតូចមួយ តែជាមជ្ឈមណ្ឌលពាណិជ្ជកម្មមួយដ៏សំខាន់នៅអាស៊ីអាគ្នេយ៍ ហើយកំពង់ផែ អូរកែវ ដើរតួនាទីយ៉ាងសំខាន់នៅក្នុងពាណិជ្ជកម្មនេះ។ កំពង់ផែអូរកែវ គឺជាកំពង់ផែដ៏សំខាន់របស់អាណាចក្រហ្វូណន ហើយគឺជាផែអន្តរជាតិដ៏ធំមួយនៅអាស៊ីអាគ្នេយ៍។ កំណាយនៅអូរកែវបានរកឃើញនូវសម្ភារមកពីឥណ្ឌា ដែលជាចំណុចចាប់ផ្ដើមនៃឥណ្ឌានីយកម្ម។ ជនជាតិឥណ្ឌាដែលមកកាន់អាណាចក្រហ្វូណន មានជនភៀសខ្លួន ក៏ដូចជាឈ្មួញ ដែលមករកទិញមាស គ្រឿងប្រណីត និងគ្រឿងទេស។

អរិយធម៌ហ្វូណនមានលក្ខណៈផ្សេងពីឥណ្ឌា ទោះបីជាចាប់ផ្ដើមមានឥណ្ឌានីយកម្មក្ដី។ ដូច្នេះហើយ ទើបគេហៅអរិយធម៌នេះថា ជាអរិយធម៌ខ្មែរ-ឥណ្ឌា។ ហ្វូណនមានប្រព័ន្ធប្រមូលពន្ធ ប្រព័ន្ធតុលាការ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បណ្ណាល័យ សម្ងៀកបំពាក់ កសិកម្ម សិប្បកម្ម និងពាណិជ្ជកម្ម។ អ្នកស្រុកហ្វូណនគោរពបូជាព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនា។

អាណាចក្រភ្នំមានការរៀបចំផ្នែកនយោបាយតាមបែបឥណ្ឌា។ ព្រះរាជាមានឋានន្តរនាមជា ក្រុងភ្នំ ព្រោះយកតាមភ្នំ ដែលព្រះអង្គគង់យាងឡើងទៅធ្វើសក្ការៈចំពោះព្រះ មហេស្វរៈ និងមានតម្កល់លិង្គព្រះ គិរិស គឺឈ្មោះព្រះឥសូរដែលសណ្ឋិតនៅលើភ្នំនោះ។ នៅក្នុងវិស័យនយោបាយក្រៅប្រទេស អាណាចក្រភ្នំបានចងស្ពានមេត្រីជាមួយប្រទេសធំៗ ដូចជាប្រទេសឥណ្ឌា និងប្រទេសចិន។ កំពង់ផែ អូរកែវ ជាកំពង់ផែដ៏ធំមួយរបស់អាណាចក្រភ្នំ។ អ្នកប្រាជ្ញបារាំង លោក Louis Malleret បានធ្វើកំណាយនៅស្ថានីយ អូរកែវ ហើយរកឃើញខឿនសំណង់ផ្សេងៗ ព្រមទាំងវត្ថុផ្សេងច្រើនទៀតមកពីចក្រភពរ៉ូម និងឥណ្ឌា។

តួនាទីសាសនានៃឥណ្ឌាភាវូបនីយកម្ម ៖ នៅសម័យអាណាចក្រភ្នំប្រជាជនខ្មែរខ្លះគោរពបូជាព្រហ្មញ្ញសាសនា និងខ្លះទៀតព្រះពុទ្ធសាសនា។ នៅក្នុងព្រហ្មញ្ញសាសនា អ្នកខ្លះគោរពព្រះឥសូរ អ្នកខ្លះគោរពព្រះវិស្ណុ។ ដល់ក្រោយស.វ.ទី៨ ប្រជាជនខ្មែរគោរព ព្រះហរិហរៈ ដែលម្ខាងជាឥសូរ និងម្ខាងទៀតជាវិស្ណុ ដែលរូបចម្លាក់ច្រើនធ្វើពីសំរឹទ្ធិ និងថ្ម។

នៅសម័យអាណាចក្រភ្នំ ព្រះពុទ្ធសាសនាមានការរុងរឿងក្រៃលែង ហើយអ្នកស្រុកច្រើនគោរពនិកាយថេរវាទ។ គេបានរកឃើញពុទ្ធរូបជាច្រើនអង្គធ្វើពីសំរឹទ្ធិ ពីថ្ម ឬពីឈើ ជារចនាបថភ្នំដានៅអង្គរបុរី ដែលជាមជ្ឈមណ្ឌលផលិតបដិមាទាំងនោះ។ ព្រះពុទ្ធរូបសម័យនោះដែលរកឃើញគឺព្រះពុទ្ធរូបថ្មនៅវត្តរំលក ស្រុកព្រៃកប្បាស ខេត្តតាកែវ ព្រះពុទ្ធរូបសំរឹទ្ធិនៅបាណន់ ខេត្តបាត់ដំបង និងព្រះពុទ្ធរូបនៅទួលព្រះធាតុ ខេត្តកំពង់ស្ពឺ។

អាណាចក្រភ្នំប្រើប្រាស់ភាសាសំស្ក្រឹតជាភាសាផ្លូវការ ក៏ប៉ុន្តែ ភាសាខ្មែរក៏ត្រូវបានគេប្រើប្រាស់ទន្ទឹមនឹងភាសាសំស្ក្រឹតដែរ។ ក្នុងវិស័យជំនឿសាសនា ប្រជាជននៅអាណាចក្រភ្នំបានកាន់សាសនាធំៗទាំងពីររបស់


fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឥណ្ឌា គឺសាសនាព្រាហ្មណ៍ និងពុទ្ធសាសនា។ ព្រះពុទ្ធសាសនាដែលនាំចូលមកកាន់អាណាចក្រភ្នំដំបូង គឺព្រះពុទ្ធសាសនាមហាយាន ដែលប្រើប្រាស់ភាសាសំស្ក្រឹត។ ចំណែកខាងសាសនាព្រាហ្មណ៍ គេឃើញមានការគោរពចំពោះ ព្រះឥសូរ ព្រះវិស្ណុ ព្រះហរិហរៈ (វិស្ណុ និងឥសូរ រួមគ្នា) និងព្រះព្រហ្ម។

នៅក្នុងវិស័យស្ថាបត្យកម្ម ប្រាសាទបុរាណត្រូវបានសាងសង់ពីដីឥដ្ឋ។ ខឿនសំណង់ផ្សេងៗ ដែលគេបានរកឃើញនៅកំពង់ផែអូរកែវ និងនៅអង្គរបុរីក៏ជាសំណង់ពីឥដ្ឋ។ នៅផ្នែកសិល្បៈបដិមា គេបានរកឃើញព្រះពុទ្ធរូប និងទេវរូបជាច្រើននៅតំបន់ភ្នំដា ស្រុកព្រៃកប្បាស ខេត្តតាកែវ ដូចជាពុទ្ធរូបវត្តរំលក រូបព្រះវិស្ណុ ព្រះពលរាម ព្រះកល្កិន និងព្រះក្រឹស្ណគោវធ៌នជាដើម។ ស្នាដៃទាំងនេះមានលក្ខណៈជាឥណ្ឌានៅឡើយ។

តាមប្រភពឯកសាររបស់លោក Bernard Philippe Groslier អាណាចក្រភ្នំមិនគ្រាន់តែមានអំណាចសមុទ្រ និងជំនួញប៉ុណ្ណោះទេ ប្រទេសនេះបានជានាឱ្យមានធនធានកសិកម្មរបស់គេយ៉ាងច្រើនបំផុត ដោយរៀបចំទឹកដីរបស់គេបានប្រសើរ ដោយឈរលើការប្រឹងប្រែងដ៏មហិមា តាមរយៈការបង្កើតនូវប្រព័ន្ធព្រែកជីកសម្រាប់បង្ហូរទឹក និងធ្វើការស្រោចស្រពយ៉ាងប្រទាក់ក្ដាចម្រុះ ប្រកបដោយប្រសិទ្ធភាពខ្ពស់សម្រាប់ដំណាំស្រូវ។ ប្រព័ន្ធព្រែកជីកទាំងនេះប្រទាក់ក្រឡាគ្នាពីមួយទៅមួយ រួចហើយក៏បត់បែនទៅនឹងបុរី ហើយក៏បម្រើដល់ការដឹកជញ្ជូននានា ជាពិសេសសម្រាប់នាវាធំៗ ដែលអាចចូលដល់ទៅខាងក្នុងទីក្រុង។ ជាការពិតណាស់ នៅតាមដងផ្លូវទាំងនេះហើយ ដែលឥទ្ធិពលឥណ្ឌាបានជ្រាបចូលទៅតំបន់ខាងក្នុងបានយ៉ាងងាយ ។

សិលាចារឹកវូកាញ់(Vo Cành) ខេត្តញ៉ាត្រាង(Nha Trang) វៀតណាម ប្រហែលចារឹកនៅសតវត្សទី៣ (តែអ្នកប្រាជ្ញខ្លះថានៅសតវត្សទី៤) បានកត់ត្រាទុកនូវប្រវត្តិសាស្ត្រខ្មែរជំនាន់អាណាចក្រគោកធ្លក ឬហ្វូណាន ក្នុង

រជ្ជកាលរបស់ព្រះបាទ ហ្វាន់ ចេម៉ាន់ ឬព្រះបាទ ស្រីមារៈ។ ព្រះអង្គមានព្រះរាជហឫទ័យជ្រះថ្លា និងតែងសន្តោសដល់ប្រជាពលរដ្ឋទូទៅ។ ទ្រង់បានបរិច្ចាគព្រះរាជទ្រព្យធ្វើជាទានដល់សាធារណជន។ ទ្រង់បានត្រាស់ផ្តាំផ្ញើដល់ព្រះរាជាក្រោយៗ សូមឱ្យទ្រង់មានព្រះមេត្តាធម៌ដូចព្រះអង្គដែរ។ ក៏ប៉ុន្តែ អ្នកប្រាជ្ញខ្លះ ដូចជាលោក Vickery បានសន្និដ្ឋានថា ព្រះបាទ ហ្វាន់ ចេម៉ាន់ មិនត្រូវនឹងព្រះបាទ ស្រីមារៈ ហើយលោកបញ្ជាក់ថា ហ្វូណនទំនងមិនមែនជារដ្ឋឯកភាព ដែលមានអំណាចគ្រប់គ្រងកំពង់ផែសមុទ្រពីពាក់កណ្តាលឆ្នេរប្រទេសវៀតណាម ដល់ឆ្នេរតំបន់សុងខ្លារបស់ថៃសព្វថ្ងៃនេះដែរ។

## II. វិភាគទានអក្សរសិល្ប៍ព្រាហ្មណ៍និយមក្នុងឥណ្ឌាភាវូបនីយកម្ម

### ២.១ ឥទ្ធិពលអក្សរសិល្ប៍ឥណ្ឌាទៅលើចម្លាក់បុរាណខ្មែរ

ពុទ្ធបដិមា និងរូបចម្លាក់ខាងព្រហ្មញ្ញសាសនា ៖ ចាប់តាំងពីដើមគ្រិស្តសករាជ វប្បធម៌ឥណ្ឌាមានឥទ្ធិពលខ្លាំងទៅលើសាសនា ដោយគេឃើញមានរូបចម្លាក់ជាច្រើននៅក្នុងប្រាសាទ និងនៅក្នុងកំណាយបុរាណដូចជារូបបដិមានៅក្នុងប្រាសាទភ្នំដា។ ចំណែករូបចម្លាក់បីនៃរចនាបថមុនអង្គរ ពោលគឺក្នុងសម័យនគរភ្នំ ដែលរកឃើញនៅក្នុងប្រាសាទ ដែលមានលក្ខណៈធម្មជាតិនិយម និងពិសិដ្ឋនិយមគឺ ៖ ព្រះវិស្ណុដៃ៨ មួយអង្គ និងពុទ្ធបដិមា២អង្គដែលមានស្លាកស្នាមវប្បធម៌ឥណ្ឌា-ក្រិក។

ដូច្នេះ លោក Jean Boisselier បានចាត់ថ្នាក់រចនាបថភ្នំដា ដោយឈរលើមូលដ្ឋាននៃរូបបដិមាតែប៉ុណ្ណោះ។

ប្រាសាទ សម្បូណ៌ព្រៃគុក ស្ថិតនៅក្នុងខេត្តកំពង់ធំ សាងសង់ឡើងនៅស.វ.ទី៧ ក្នុងរជ្ជកាលព្រះបាទ ឦសានវរ្ម័ន ដែលបានតាំងរាជធានីនៅឦសានបុរៈ ដែលជារាជធានីដំបូងបង្អស់របស់នគរភ្នំ និងចេនឡារួមគ្នា ហើយដែលប្រវត្តិវិទូបានចាត់ទុកថា ជាដើមកំណើតនៃអាណាចក្រខ្មែរ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ចំណុចសំខាន់នៃប្រាសាទ សម្បូណ៌ព្រៃគុក គឺវត្តមាននៃស្វាកស្នាមដ៏ច្រើន លើសលប់នៃវប្បធម៌ឥណ្ឌា។ រូបបដិមាព្រះនាងទុគ៌ា ដែលរកឃើញនៅក្នុងប្រាសាទបង្ហាញឱ្យឃើញពីសម្រស់ និងរូបរាងស្ត្រីឥណ្ឌាតែម្តង។

ការវិវត្តនៃសិល្បៈ និងប្រាសាទខ្មែរ ៖ អារ្យធម៌ខ្មែរបានឈានដល់កម្រិតកំពូលចាប់ពីស.វ.ទី១១ ដល់ស.វ.ទី១៣។ នៅពេលនោះ ព្រះមហាក្សត្រខ្មែរបានកសាងប្រាង្គប្រាសាទជាច្រើន ដើម្បីឧទ្ទិសដល់ព្រះអាទិទេព ឬបុព្វការីជនរបស់ព្រះអង្គ និងដើម្បីជានាឱ្យបាននូវវិបុលភាព និងឯកភាពជាតិខ្មែរ។ ការសាងសង់ប្រាសាទបុរាណខ្មែរមានការវិវត្ត និងកែលម្អជាប្រចាំ ដែលឆ្លុះបញ្ចាំង ពីដំណាក់កាលយុវវ័យ ភាពចាស់ទុំ និងជរាភាព។ អ្នកដែលសិក្សាសិល្បៈខ្មែរបានបែងចែកប្រាសាទបុរាណខ្មែរ ជាស្ថាបត្យកម្ម មុនសម័យបុរាណ(ពីស.វ.ទី១ដល់ស.វ.ទី៨) ស្ថាបត្យកម្មសម័យអង្គរ (ពីស.វ.ទី៩ដល់ស.វ.ទី១៣) និងស្ថាបត្យកម្មក្រោយសម័យអង្គរ(ពីស.វ.ទី១៤ដល់សព្វថ្ងៃនេះ)។ លោក Claude Jacques បានគូសបញ្ជាក់ថា សិល្បៈខ្មែរបានវិវត្តទៅតាមវិធីសាស្ត្របួនយ៉ាងគឺ ៖

ទីមួយ-តក្កកម្ម មានន័យថា ការបង្កើតអ្វីៗថ្មីទាំងស្រុង។

ទីពីរ-ការចូលរួមវិភាគទានពីសិល្បៈបរទេស(គឺពីសិល្បៈឥណ្ឌា តែក៏មានសារធាតុខ្លះនៃសិល្បៈជ្វា និងសិល្បៈចាមដែរ)។

ទីបី-ការខ្ចីនូវរចនាបថពីអតីតកាល តែមិនបានចម្លងទាំងស្រុងនូវរចនាបថទេ ដោយគ្រាន់តែស្វែងរកប្រធានបទចាស់ៗ ដើម្បីបញ្ចូលសាជាថ្មី ដោយមានធ្វើវិសោធនកម្ម នៅលើអ្វីដែលមានចាស់។

ទីបួន-ការចម្លងតាមនូវបច្ចេកទេសផ្សេងៗ ហើយអ្វីដែលគេច្រើនជួបប្រទះ គឺការចម្លងតាមនូវក្បូរក្បាច់រចនានៃសំណង់ឈើតូចតាច។

ដោយឈរលើមូលដ្ឋាននៃការសិក្សានូវលក្ខណៈពិសេសខាងផ្នែកស្ថាបត្យកម្ម ឬក្បាច់រចនាផ្សេងៗ លោក Philippe Stern និង Gilbert de Coral-Rémusat បានបង្កើតបានជាបញ្ជីរចនាបថចំនួន១៣ ដោយដាក់

ឈ្មោះតាមប្រាសាទសំខាន់ៗនិងមានលក្ខណៈពិសេស ហើយដែលតំណាង ឱ្យរចនាបថសម័យនោះ។ តាមរយៈការសិក្សារូបចម្លាក់ លោក Jean Boisselier និង Pierre Dupont បានបន្ថែមនូវរចនាបថពីរទៀត គឺរចនាបថភ្នំដា និងរចនាបថប្រាសាទអណ្ដែត។ ដូច្នេះ សិល្បៈខ្មែរបានវិវត្តទៅតាមរចនាបថចំនួន១៥។ យើងឃើញថា សិល្បៈខ្មែរក្នុងដំណាក់កាលដំបូងស្ថិតនៅក្នុងសភាពក្មេងខ្ចីនៅឡើយ ហើយខ្ចីពីសិល្បៈឥណ្ឌាយ៉ាងច្រើន ដោយពុំទាន់ស្វ័ឱ្យចេញជាអត្តសញ្ញាណជាតិខ្មែរឱ្យបានទាំងស្រុងនៅឡើយ។

ចម្លាក់និងប្រាសាទខ្មែរតាមប្រធានបទរឿងរាមកេរ្តិ៍ និងរឿងមហាភារតៈ៖

ចម្លាក់ខ្មែរនៃរចនាបថមុនអង្គរ គេច្រើនប្រើប្រាស់ស្លឹករុក្ខជាតិ ដើម្បីតែងលម្អ។ ប្រាសាទខ្មែរដែលមានរូបចម្លាក់ទាក់ទងនឹងរឿងរាមកេរ្តិ៍ និងរឿងមហាភារតៈ គឺប្រាសាទកោះកេរនៅដើមសតវត្សទី១០ ប្រាសាទបន្ទាយស្រីនៅពាក់កណ្ដាលសតវត្សទី១០ ប្រាសាទបាពួនក្នុងសតវត្សទី១១ និងប្រាសាទអង្គរវត្តក្នុងសតវត្សទី១២។

ប្រាសាទនៃរចនាបថ កោះកេរ ដែលត្រូវបានសាងសង់ចាប់ពីឆ្នាំ៩២១ដល់ឆ្នាំ៩២៨ មានរូបចម្លាក់ធំៗដែលបង្ហាញពីរូបមានចលនា ដូចជារូបព្រះសិវៈរាំ រូបគ្រុឌដើរ រូបចំបាប់រវាងសុគ្រីព និងពាលី រូបចំបាប់រវាងយក្ខនិងទេវតា ដែលយកពីរឿងរាមកេរ្តិ៍ និងរឿងមហាភារតៈ ដូចជាប្រាសាទធំ ប្រាង្គប្រាសាទនាងខ្មៅ ប្រាសាទដំរី ប្រាសាទក្រហម ប្រាសាទចិន ប្រាសាទបូក និងប្រាសាទប្រាំជាដើម។

បណ្ដុំប្រាសាទអង្គរវត្ត គឺជាឃ្លាំងនៃសិល្បៈខ្មែរ ដែលជាវណ្ណកម្មនៃការច្នៃប្រឌិតថ្មីខាងផ្នែកសិល្បៈ និងស្ថាបត្យកម្ម។ នៅចុងស.វ.ទី១១ និងពាក់កណ្ដាលទីមួយនៃស.វ.ទី១២ ស្ថាបត្យកម្មខ្មែរបានឈានដល់កម្រិតកំពូលហើយ។ យើងឃើញថា បន្ទាប់ពីមានការវិវត្តក្នុងរយៈពេល៥០០ឆ្នាំមក ទើបសិល្បៈ និងស្ថាបត្យកម្មខ្មែរ ជាពិសេស ក្បូរក្បាច់រចនានៅលើ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ប្រាសាទ បានឈានដល់កម្រិតកំពូលយ៉ាងសុក្រឹតមួយដ៏ល្អស្ងប់ស្ងែង។ ប្រាសាទទាំងអស់នៃរចនាបថអង្គរវត្តសុទ្ធសឹងតែសាងសង់ឡើង ដោយប្រើថ្មភក់ទាំងអស់ពីឆ្នាំ១១០០ដល់១១៧៥។ សសរពេជ្រនៃរចនាបថអង្គរវត្តបានវិវត្តទៅមុខ ដោយមានថ្នាក់ក្បាច់ចិញ្ចៀនរហូតដល់១០ ឬ១២។ ហោជាងនៃរចនាបថអង្គរវត្តរក្សានូវពេជផ្ចូកំប៉ោង ដូចរចនាបថមុនដែរ តែលើផ្ទៃហោជាង ក្បាច់ក្បូរស្លឹកឈើត្រូវបានជំនួសដោយរឿងទេវកថា មហាភារតៈ និងរាមកេរ្តិ៍វិញ។

ម្យ៉ាងវិញទៀត នៅលើជញ្ជាំងប្រាសាទអង្គរវត្តបានឆ្លាក់ចម្លាក់លឹប (*Bas-relief*) លើផ្ទាំងថ្មយ៉ាងច្រើនសន្ធឹកសន្ធាប់ ជាពិសេសនៅលើជញ្ជាំងនៃថែវប្រាសាទដែលដកស្រង់ពីឈុតល្បីៗនៃទេវកថា មហាភារតៈ និងរាមកេរ្តិ៍ ដូចជា កូរសមុទ្រទឹកដោះជាដើម។

ជារួមយើងអាចសន្និដ្ឋានបានថា វីរកថា(*épopée*)ទាំងពីររបស់ឥណ្ឌា រឿងមហាភារតៈ និងរឿងរាមកេរ្តិ៍ ពិតជាមានឥទ្ធិពលយ៉ាងខ្លាំងក្លាទៅលើចម្លាក់ និងប្រាសាទបុរាណខ្មែរ។ ដូច្នេះ សំណួររបស់ខ្ញុំគឺ ហេតុអ្វីបានជាឥទ្ធិពលនេះមិនបានជ្រាបចូលដល់សង្គមខ្មែរសម័យទំនើប?

## ២.២ ឥទ្ធិពលអក្សរសិល្ប៍ឥណ្ឌាទៅលើអក្សរសិល្ប៍ព្រាហ្មណ៍និយមខ្មែរ

ខ្ញុំយល់ថា មូលហេតុដែល រឿងមហាភារតៈ មិនមានឥទ្ធិពលខ្លាំង និងមិនបានជ្រាបចូលដល់សង្គមខ្មែរសម័យទំនើប គឺដោយសារតែកវីនិពន្ធខ្មែរមិនបានតែងរឿងនេះទៅជាកំណាព្យ។

ដោយឡែករឿងរាមកេរ្តិ៍ ដែលតែងជាពាក្យកាព្យ គឺជាជម្រុកពាក្យពេចន៍នៃភាសា និងវោហារសាស្ត្រខ្មែរ និងជាប្រភពនៃការច្នៃប្រឌិតខាងតែងនិពន្ធ។ គេបានប្រើប្រាស់ពាក្យកាព្យក្នុងរឿងរាមកេរ្តិ៍ ដើម្បីបង្កើតវណ្ណកម្មថ្មីៗទៀត ដូចជាវិចិត្រកម្ម សិល្បៈនាដសាស្ត្រ និងល្ខោន។ សិល្បករនាដករ និងអ្នកនិពន្ធខ្មែរបានយករឿងរាមកេរ្តិ៍ទៅសម្តែងក្នុងល្ខោនព្រះ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

រាជទ្រព្យ ល្ខោនខោល ល្ខោនស្បែកតូច និងស្បែកធំ។ ដូច្នេះហើយទើបរឿងរាមកេរ្តិ៍ជ្រាបចូលជ្រៅទៅក្នុងសង្គមខ្មែរ បើប្រៀបធៀបទៅនឹង រឿងមហាភារតៈ។

## ២.២.១ អត្តរូបនៃអក្សរសិល្ប៍ព្រាហ្មណ៍និយមខ្មែរ

«អត្តរូប» សម្រាប់សម្គាល់នូវសភាពរូបរាង ទម្រង់បែបបទនៃអត្ថបទដែលកើតឡើងអំពីវិធីតែងនិពន្ធដែលប្រើដោយពាក្យសម្ដីឃ្លាប្រយោគ។ ក្នុងការសិក្សាអត្តរូប យើងត្រូវដឹងថាតើរឿងរាមកេរ្តិ៍មានប្រភពចេញមកពីណា? សរសេរជាវណ្ណកម្មបែបដូចម្ដេច? ជាប្រលោមលោក ឬជាកំណាព្យ? តែងនិពន្ធនៅក្នុងសម័យណាជាដើម។ ក្នុងន័យនេះ យើងនឹងសិក្សាពីប្រភពនៃរឿងរាមកេរ្តិ៍ និងកាលបរិច្ឆេទតែងនិពន្ធ។

អរិយធម៌ខ្មែរមានប្រភពចេញពីលទ្ធិព្រាហ្មណ៍និយមផង ជាពិសេសគឺអរិយធម៌ជំនាន់អង្គរ និងលទ្ធិពុទ្ធនិយមផង ដែលជាអរិយធម៌ខ្មែរជំនាន់ក្រោយអង្គរ។ ចលនាអក្សរសិល្ប៍បែបព្រាហ្មណ៍និយមដែលតំណាងដោយរឿងរាមកេរ្តិ៍ ដែលមានរូបសេចក្ដី និងសណ្ឋាន ដែលដកស្រង់ចេញពីប្រភពនៃរាមាយណៈរបស់ឥណ្ឌា។ លោក វាល្មិកិ បានយកសង្គ្រាមរវាងព្រះរាមដែលជាតំណាងសភាវៈល្អ និងក្រុងរាពណ៍នៅលង្កា ហើយដែលត្រូវបានចាត់ទុកដោយអ្នកនិពន្ធថា ជាតំណាងសភាវៈអាក្រក់។

ក៏ប៉ុន្តែ រឿងរាមកេរ្តិ៍ ថ្វីត្បិតតែរឿងនេះមានលំនាំប្រហាក់ប្រហែលរឿងរាមាយណៈមែន តែអ្នកនិពន្ធបានយករឿង រាមាយណៈទៅស្ងួដាក់គ្រឿងគ្រៅឱ្យក្លាយទៅជារឿងខ្មែរបាត់ទៅហើយ។ យើងក៏ឃើញដូចគ្នាដែរថាប្រាង្គប្រាសាទ និងរូបចម្លាក់ ដែលនៅរចនាបថសម្បូណ៌ព្រៃគុកមានលក្ខណៈស្រដៀងឥណ្ឌា។ ក៏ប៉ុន្តែ បន្ទាប់ពីអ្នកប្រាជ្ញ និងសិល្បៈករខ្មែរបានជុសខាត់ កែលម្អ និងវិវត្តអស់រយៈពេលជិត ៥០០ ឆ្នាំមក ស្នាដៃសិល្បៈទាំងនេះបានក្លាយទៅជារបស់ខ្មែរពិតៗ។ ឧទាហរណ៍ រូបបដិមាព្រះនាងទុគ៌ា



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដែលរកឃើញនៅក្នុងប្រាសាទសម្បូណ៌ព្រៃគុកបង្ហាញឱ្យឃើញពីសម្រស់ និងរូបរាងស្ត្រីឥណ្ឌាតែម្តង។ ផ្ទុយទៅវិញ រូបបដិមាដែលរកឃើញនៅក្នុងប្រាសាទអង្គរវត្តមានរាងរាវ និងបង្ហាញឱ្យឃើញពីសម្រស់ និងរូបរាងស្ត្រីខ្មែរពិតៗ។

ដូច្នេះ យើងអាចសន្និដ្ឋានបានថា រឿងរាមកេរ្តិ៍ជាស្នាដៃអក្សរសិល្ប៍សម័យក្រោយអង្គរដ៏អស្ចារ្យ ដែលជាបេតិកភណ្ឌជាតិខាងផ្នែកអក្សរសាស្ត្រ។ រឿងរាមកេរ្តិ៍ មានលំនាំប្រហាក់ប្រហែលនឹងរឿងរាមាយណៈ ដែលជាវីរកថា យុទ្ធកថារបស់ឥណ្ឌាក៏ពិតមែន តែកវីនិពន្ធខ្មែរបានយករឿងនោះមកស្ទូកែច្នៃសាច់រឿង និងថែមគ្រឿង ដោយប្រើប្រាស់វិធីសាស្ត្រ និងសិល្បវិធីតែងនិពន្ធ ថែមថយពាក្យពេចន៍ បញ្ចូលទស្សនៈ និងខ្លឹមសារឱ្យឆ្លុះបញ្ចាំងពីតថភាពក្នុងសង្គមខ្មែរ ប្រើប្រាស់វោហារសាស្ត្រខ្មែរ ដើម្បីឱ្យសាច់រឿងនេះក្លាយជារបស់ខ្មែរសុទ្ធសាធ។

រឿងរាមកេរ្តិ៍ គឺជាវណ្ណកម្មឯក ដែលឆ្លុះបញ្ចាំងនូវទេពកោសល្យនៃកវីនិពន្ធខ្មែរ ហើយដែលត្រូវបានចាត់ទុកជាវណ្ណកម្មអក្សរសិល្ប៍ព្រាហ្មណ៍និយម។ មានអ្នកសិក្សាស្រាវជ្រាវជាច្រើនបានសរសេរវិភាគរួចមកហើយនូវរឿងរឿមកេរ្តិ៍នេះដូចជា (១)លោកសាស្ត្រាចារ្យ សរ សារុន សាស្ត្រាចារ្យនៃវិទ្យាស្ថានស្រាវជ្រាវឯកសារគរុកោសល្យ (២)លោកសាស្ត្រាចារ្យ លាង ហាប់អាន (៣)លោកសាស្ត្រាចារ្យ ឃួន សុខម្ភូ (៤)លោកស្រីសាស្ត្រាចារ្យ ពៅ សាវរស់ និងមានសៀវភៅសិក្សាអក្សរសិល្ប៍ខ្មែរ ចលនាព្រាហ្មណ៍និយមជាច្រើនទៀត។

តាមការសិក្សារបស់លោកស្រីសាស្ត្រាចារ្យ ពៅ សាវរស់ រឿងរាមកេរ្តិ៍ត្រូវបានតែងនិពន្ធ ដោយប្រើប្រាស់ពាក្យពេចន៍នៃភាសាខ្មែរសម័យកណ្តាល នៅសតវត្សទី១៥ និងទី១៦ ពោលគឺនៅសម័យមុនលង្វែក និងនៅសម័យលង្វែក។ អត្ថបទសរសេរជាពាក្យកាព្យដ៏អស្ចារ្យនេះ មិនបានបញ្ជាក់ពីពេលវេលានៃការតែងនិពន្ធ និងឈ្មោះរបស់កវីនិពន្ធឡើយ។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អ្នកនិពន្ធមុនៗបានបង្ហាញពីភាពខុសគ្នារវាងរឿងរាមកេរ្តិ៍ និងរឿងរាមាយណៈរបស់លោកវាល្មិកិដែលតែងនិពន្ធចាប់ពីការផ្ដើមរឿងខុសគ្នាដល់ដំណើររឿងតែម្ដង។ រាមច្បងរបស់យើងបានសិក្សាពីទីកន្លែងរឿង តួអង្គរឿង បញ្ហាទំនាស់ក្នុងរឿង ការដោះស្រាយបញ្ហារឿង និងបញ្ហាផ្សេងៗទៀត ដែលអ្នកនិពន្ធបានលើកមកចោទ និងដោះស្រាយនៅក្នុងរឿងរាមកេរ្តិ៍។ អ្នកនិពន្ធបានលើកយកបញ្ហាមនុស្សមកចោទសួរ មកបង្ហាញ មករិះគន់ និងមកដោះស្រាយតាមរយៈកម្រងកំណាព្យដែលតែងនិពន្ធ នៅក្នុងសតវត្សទី ១៥ និង ទី១៦ នៅពេលដែលខ្មែរយើងខិតខំប្រឹងប្រែងកសាងជាតិឡើងវិញ នៅក្នុងគ្រប់វិស័យ ជាពិសេសក្នុងការលើកកម្ពស់អក្សរសិល្ប៍ខ្មែរសម័យកណ្ដាល។

## ២.២.២ អត្ថន័យនៃរឿងរាមកេរ្តិ៍

សាស្ត្រារឿងរាមកេរ្តិ៍ ត្រូវបានបំផ្លាញចោល នៅពេលដែលព្រះពុទ្ធសាសនាមានឥទ្ធិពលខ្លាំងនៅកម្ពុជា។ ដូច្នេះហើយ ទើបរឿងរាមកេរ្តិ៍ត្រូវបានហាមឃាត់មិនឱ្យផ្សព្វផ្សាយជាសាធារណៈ មុនអំឡុងទសវត្សឆ្នាំ១៩៥០។ សាស្ត្រាដែលនៅសេសសល់ពីខ្សែទី១ដល់ទី១០ និងពីខ្សែទី៧៥ដល់៨០ ដោយសារតែលោកស្រី ស៊ូហ្សាន កាប៉ឺឡេស រក្សាទុកយ៉ាងស្ងាត់កំបាំង ហើយបន្ទាប់មក យកទៅរៀបរៀងបោះពុម្ពផ្សព្វផ្សាយឡើងវិញនៅវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ ក្នុងទសវត្សឆ្នាំ១៩៥០។ ការបោះពុម្ពឡើងវិញលើកទី៣ បានធ្វើឡើងនៅឆ្នាំ១៩៥៩។ ការសិក្សាស្ដីពី«អត្ថន័យ»នៃរឿងរាមកេរ្តិ៍សំដៅលើការលើកឡើងក្នុងរឿងនូវមតិ ទស្សនៈ និងបញ្ហាសំខាន់ៗក្នុងអក្សរសិល្ប៍ព្រាហ្មណ៍និយម។

### ២.២.២.១ សង្ខេបរឿងរាមកេរ្តិ៍

យើងអាចសង្ខេបរឿងរាមកេរ្តិ៍ពីខ្សែ១ដល់១០ ដោយផ្ដោតលើចំណុច

សំខាន់ៗដូចតទៅ ៖

រឿងរាមកេរ្តិ៍ខ្មែរចាប់ផ្ដើមពីព្រះរាម និងព្រះលក្សណ៍បានរៀនចប់គម្ពីរវេទ ដែលជាគម្ពីរនៃព្រហ្មញ្ញសាសនា ដែលមានឥសីពិស្វាមិត្រជាគ្រូបាអាចារ្យ។ ពេលនោះ ព្រះបាទជនក ដែលជាស្ដេចសោយរាជ្យនៅនគរមិថិលាបានរៀបចំពិធីជ្រើសរើសគូស្រករ។ ប្រសិនបើស្ដេចអង្គណាអាចលើកធ្នូសរបាន ព្រះអង្គនឹងលើកបុត្រីចិញ្ចឹម គឺនាងសីតាជាមហេសី។

បន្ទាប់ពីលើកធ្នូសរបានជោគជ័យរួចមក ព្រះរាមបានអភិសេកជាមួយនាងសីតា ហើយក៏យាងត្រឡប់មកនគរអយុធ្យាវិញ។ លុះមកដល់នគរព្រះបិតានាមទសរថមានបំណងលើកព្រះរាមជារាជបុត្រច្បងឱ្យឡើងគ្រងរាជ្យតាមប្រពៃណីនៃត្រកូលក្សត្រ តែនាងកៃកេសីជំទាស់ដោយសំអាងលើពាក្យសច្ចៈព្រះទសរថបានសន្យាថានឹងឱ្យបុត្ររបស់ព្រះនាងឈ្មោះភិរុត ឡើងគ្រងរាជ្យវិញ នៅពេលដែលនាងជួយព្រះអង្គក្នុងសង្គ្រាមបានឈ្នះព្រះអាទិត្យ។ ទាំងបីអង្គានាំគ្នាចាកចេញពីនគរអយុធ្យាទៅទៅរស់នៅភ្នំចិត្តកូត។

ឯក្រុងអយុធ្យាឯនោះវិញ ព្រះបាទទសរថទ្រង់សោយទិវង្គត។ នាងកៃកេសីលួចថ្ងៃងសារ ឱ្យព្រះរាជបុត្រត្រឡប់មកកាន់នគរដើម្បីអភិសេក តែព្រះភិរុតមិនព្រម។ ក្សត្រា ក្សត្រីបានទៅយាងព្រះរាមឡើងសោយរាជ្យ តែព្រះរាមបដិសេធមិនព្រម ហើយព្រះអង្គទ្រង់ទុកឱ្យព្រះភិរុតនាំត្រឡប់ទៅ ក្រុងអយុធ្យាវិញ។ ព្រះរាមសម្រេចព្រះទ័យនាំមហេសី និងព្រះអនុជចូលទៅព្រៃជ្រៅឆ្ងាយទៅទៀត។ ក្សត្រទាំងបីអង្គបានបន្តដំណើរដល់ភ្នំកណ្ដាការណ្យពន ក៏បួសជាតាបស។ ពេលនោះមានយក្ខិនីមួយឈ្មោះនាងសូបនខា ត្រូវជាប្អូនយក្សក្រុងរាពណ៍បានឃើញក្សត្រទាំងពីរមានរូបឆោមលោមពណ៌គួរឱ្យបេតី ក៏កាឡាខ្លួនជាទេពអប្សរយ៉ាងស្រស់ប្រិមប្រិយចូលទៅប្រលោមលួងលោម សុំសេចក្ដីស្នេហាពីព្រះរាម។ តែព្រះរាមបានប្រាប់នាងឱ្យទៅសុំពីព្រះលក្សណ៍វិញ។ ព្រះលក្សណ៍ដាច់សីលខ្ចាល់នឹង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នាងសូបនខាមករុកគួនក៏ចាប់ផ្តួលកោសក់កាត់ដៃ ស្រែកបណ្តោញចេញទៅ។ នាងសូបនខាក៏ហោះសំដៅទៅក្រុងលង្កា ញុះញង់បងប្រុសគឺក្រុងរាពណ៍ឱ្យចេញមកសងសឹក ព្រមទាំងឱ្យចាប់នាងសីតាយកមកធ្វើជាមហេសីផង។ ក្រុងរាពណ៍ក៏ហៅមហារីកជាសេនាឱ្យកាឡាខ្លួនជាប្រើសមាសចេញមកបង្អួតយ៉ាងសង្ហាចំពោះមុខនាងសីតា។ ពេលឃើញប្រើសមាសភ្លាមនាងសីតាក៏បង្ខំស្វាមីឱ្យចេញទៅតាមប្រហារដើម្បីយកស្បែកទុកលម្អ។ ព្រះរាមចេញទៅតាមប្រើសមាស ហើយបន្ទាប់មកព្រះលក្សណ៍ ចេញពីអាស្រមទៅតាមព្រះរាមទៀត។ ក្រុងរាពណ៍បានឱកាសកាឡាខ្លួនជាឥសីលួងលោមប្រលោមនាងសីតា រួចឆក់នាងសីតាចេញបាត់ទៅ។

ក្រុងរាពណ៍នាំនាងសីតាហោះលើអាកាសក៏ជួបសត្វគ្រុឌមួយឈ្មោះជតាយុ ដែលគំរាមឱ្យក្រុងរាពណ៍ដោះលែងព្រះនាងសីតា។ នាងសីតាបានផ្តាំផ្ញើនឹងសត្វកុកឱ្យថ្វាយដំណឹងនេះដល់ព្រះរាមជាស្វាមីផង។ បន្ទាប់មកក្រុងរាពណ៍បាននាំនាងសីតាទៅទុកក្នុងសួនអសោកនៅលង្កា។ ព្រះរាមបានជួបនឹងសត្វកុកដែលបានយកដំណឹងពីនាងសីតាមកប្រាប់។ ក្នុងព្រៃហេមពាន្ត ទូភីជួបឪពុក ដែលជាស្តេចក្របីឈ្មោះ មហិង្សរាជ ដែលតែងតែសម្លាប់កូនខ្លួនឯងចោល ហើយអង្វរឱ្យទទួលស្គាល់ខ្លួនជាកូន។ ប៉ុន្តែមហិង្សរាជមិនយល់ព្រម ក៏មានការប្រយុទ្ធគ្នារវាងឪពុកនិងកូន ទីបំផុតទូភីក៏ប្រហារជីវិតឪពុកស្លាប់ទៅ។ តាំងពីពេលនោះមក ទូភីតែងតែដើររករឿងរាតត្បាតគេឯង។ ទីបំផុតក៏ទៅររករឿងពាលីដែលជាស្តេចស្វាសោយរាជ្យនៅខាស់ខិនបុរី។ ការប្រយុទ្ធនៅខាងក្រៅ៧យប់៧ថ្ងៃមិនចាញ់ឈ្នះ ហើយនាំគ្នាទៅប្រកួតក្នុងគុហារមួយ។ ការប្រកួតគ្នានៅក្នុងគុហារនេះ ពាលីក៏ប្រហារទូភីនឹងព្រះខ័នឈាមទូភីហូរចេញមកតាមរូងគុហារលាយនឹងទឹកភ្លៀងដែលទេព្តាប្រោសព្រហ្មមកនោះ សុគ្រីពជាប្អូនពាលី ដែលយាមនៅមាត់រូងប្រទ្បំស្មានថាឈាមបងក៏សន្ទប់ថ្មបិទរូងគុហារនោះទៅ។ អ្នកនគរខាស់ខិនបុរីក៏លើកសុគ្រីពឱ្យឡើងគ្រងរាជ្យស្នងក្រុងពាលី។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្រោយមក ពាលីចេញផុតពីរូងក៏ខឹងនឹងសុគ្រីពយ៉ាងខ្លាំង សុគ្រីពរត់ចេញពីទីនោះទៅជ្រកនៅភ្នំមគង្គបព៌ត ហើយឈឺចិត្តយ៉ាងខ្លាំង។ ព្រះរាមនិងព្រះលក្សណ៍បានជួបសុគ្រីព ដែលប្រាប់អស់រឿងរ៉ាវឈ្លោះគ្នាជាមួយពាលី។ ព្រះរាមបានធានានឹងសុគ្រីពថានឹងយកនគរខាស់ខិនបុរី ព្រមទាំងព្រះនាងដារាទេពីប្រទានដល់សុគ្រីព។ រីឯសុគ្រីពក៏ថ្វាយខ្លួនធ្វើជាសេនា។ ព្រះរាមបានប្រើសុគ្រីពឱ្យទៅបញ្ឆោតពាលីចេញច្បាំង។ បន្ទាប់ពីពាលីស្លាប់ទៅ សុគ្រីពបានកេណ្ឌទ័ពស្វាថ្វាយព្រះរាម តាំងអង្គតឱ្យជាខុនពលហ្លួង ហនុមានឱ្យនៅនែបនិតនឹងព្រះរាម ព្រះលក្សណ៍។

កាលបើកេណ្ឌទ័ពស្វា បានច្រើនមកជួបជុំគ្នាហើយ ព្រះរាមត្រាស់បញ្ជាឱ្យហនុមានទៅស៊ើបការណ៍នៅក្រុងលង្កា។ មុននឹងធ្វើដំណើរទៅ ហនុមានបានស្នើសុំចិញ្ចៀនទម្រង់ព្រះរាមដើម្បីឱ្យនាងសីតាជឿជាក់ថាខ្លួនជាសេនាព្រះរាម។

បន្ទាប់ពីបានទទួលព្រះទម្រង់ពីព្រះរាម ហនុមានហោះចេញទៅលង្កា តែរកនាងសីតាមិនឃើញសោះ។ បន្ទាប់ពីរកកន្លែងរបស់នាងសីតាឃើញហើយ ហនុមានបានចូលថ្វាយបង្គំព្រះនាងសីតា និងថ្វាយព្រះទម្រង់ទតជាកស្តុតាង។ នាងសីតាបូតទម្រង់របស់នាងប្រទានទៅហនុមាន ហើយនាងផ្តែផ្តាំទៅព្រះស្វាមីថា នាងនៅតែស្មោះត្រង់ជានិច្ចនាងរង់ចាំដល់១០ខែ បើមិនយល់ព្រះភក្ត្រព្រះរាមទេនោះ នាងនឹងក្ស័យជីវិតនៅក្រុងលង្កានេះ។ ពេលចេញទៅ ហនុមានក៏ដុតក្រុងលង្កាឆេះខ្ទេចខ្ទីអស់។

ព្រះរាម និងព្រះលក្សណ៍បានចងសម្ព័ន្ធមិត្ត ជាមួយស្តេចស្វា មហាជម្ពូ សោយរាជ្យនៅហេមពាន្តដែលមានសេនា២រូបគឺ ខុននិល ខុននលជាដៃឆ្វេងដៃស្តាំដ៏ស័ក្តិសិទ្ធិ។ ព្រះរាមត្រាស់នឹងមហាជម្ពូសុំជួយសង់ស្ពានឆ្លងសមុទ្រទៅក្រុងលង្កា។ មហាជម្ពូព្រមថ្វាយខុននិល ខុននលជាតំណាងព្រោះខ្លួនចាស់ហើយសុំវិលទៅនគរវិញ។ លុះបានទ័ពជំនួយពីមហាជម្ពូហើយ ព្រះរាមបញ្ជាឱ្យសង់ស្ពានកាត់សមុទ្រ។ លុះដឹងថាព្រះរាមលើក

ទ័ពមកលង្កាហើយ រាពណ៍ក៏រៀបចំទ័ពដែរ។

ក្រុងរាពណ៍បានទូងស្គរប្រមូលទ័ព ហើយបញ្ជាឱ្យពិភេគទាយអំពីវាសនានៃនគរលង្កា ពិភេគបានគន់គូរ ហើយស្នើក្រុងរាពណ៍ឱ្យយកនាងសីតាទៅថ្វាយព្រះរាមវិញ។ ក្រុងរាពណ៍ខឹងក៏បណ្ដេញចេញពីនគរ។ ពិភេគក៏កៀសខ្លួនរត់ទៅសុំថ្វាយខ្លួនព្រះរាម ហើយព្រះរាមរីករាយទទួលពិភេគឱ្យនៅជាមួយ។ សង្គ្រាមរវាងព្រះរាម និងក្រុងរាពណ៍ចេះតែបន្តគ្មានឈ្នះ គ្មានចាញ់។

កុម្ភការណ៍ លើកទ័ពយ៉ាងច្រើនមកតាមអាកាស តាមថ្មើរជើង ច្បាំងនឹងព្រះរាម។ ព្រះរាមក៏ចាត់ពិភេគឱ្យទៅនិយាយបញ្ចុះបញ្ចូលកុម្ភការណ៍។ ហើយព្រះរាមនឹងឱ្យរង្វាន់ព្រមទាំងបុណ្យស័ក្តិយ៉ាងធំ។ កុម្ភការណ៍មិនគ្រាន់តែមិនព្រមចុះចូលនឹងព្រះអង្គទេ ថែមទាំងពោលអះអាងថា ទោះព្រះរាមមានមហិទ្ធិរិទ្ធិយ៉ាងណាក៏ដោយ ទោះជាក្រុងរាពណ៍ខុសដូចម្ដេចក៏ដោយក៏ពុំព្រមរស់នៅក្រោមការត្រួតត្រារបស់ព្រះរាមជាដាច់ខាត គឺសុខចិត្តស្លាប់ក្នុងការបម្រើជាតិ។

ការចរចាពុំបានសម្រេច ព្រះរាមក៏ប្រើពិភេគជាមួយព្រះលក្សណ៍ព្រមទាំងពលស្វាឱ្យចូលនិយាយម្ដងទៀត កុម្ភការណ៍ជេរលត្មះឱ្យពិភេគយ៉ាងខ្លាំង និងដោយក្រេវក្រោធក៏យកមោគ្គស័ក្តិចោលទៅត្រូវព្រះលក្សណ៍ដួលត្មោល សន្លប់បាត់ស្មារតី។ បើសិនជាព្រះអាទិត្យរះឡើងផ្សំថ្នាំមិនទាន់នោះ ព្រះលក្សណ៍នឹងត្រូវស្លាប់។ ហនុមានដោយខ្លាចគ្រោះថ្នាក់ដល់ជីវិតព្រះលក្សណ៍ក៏វាយសេះ ព្រះអាទិត្យបាក់ព្រះរាជរថរត់ខ្ចាត់ខ្ចាយអស់។ ជំងឺព្រះលក្សណ៍បានជាសះស្បើយ ក៏ចេញច្បាំងម្ដងទៀតជាមួយកុម្ភការណ៍។ ព្រះលក្សណ៍បានថ្ងៃងសរផ្ដាច់ក្បាលកុម្ភការណ៍ស្លាប់ទៅ។

ចំណែក ព្រះរាមក៏ចេញតតាំងដោយប្រើហនុមាន ព្រះលក្សណ៍អង្គត ចេញទៅប្រយុទ្ធ។ ឥន្ទ្រជិតថ្ងៃងសរជានាគចុះមកព័ទ្ធពលសេនាស្វា និងព័ទ្ធជើងព្រះលក្សណ៍ទាំងពីរជាប់។ ព្រះរាម ទ្រង់វិតក្កគ្រោះថ្នាក់នេះ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទើបទ្រង់សោយសោកម្តងទៀត ហើយខ្ញាល់ជាខ្លាំងបម្រុងនឹងថ្លែងសរ ប្រល័យទេវលោកចោល ទុកតែស្ថានព្រះឥសូរមួយប៉ុណ្ណោះ។ ទ្រង់កាច់សរជាពីរកំណាត់មួយកំណាត់ចោលទៅប្រល័យស្ថានទេវលោក មួយកំណាត់ទៀតចោលទៅក្រុងអយុធ្យា។ ទេវតាទាំងឡាយនាំគ្នាភ័យ ផ្អើលឡើងទៅគាល់ព្រះឥសូរសុំឱ្យព្រះអង្គជួយដោះគ្រោះភ័យ។ ព្រះឥសូរប្រើព្រះព្រហ្មឱ្យទៅស្ថានសិម្ពលី គ្រុឌ មកជួយដោះដេញកម្ចាត់នាគចេញ។ បន្ទាប់មកព្រះលក្សណ៍ និងទ័ពស្វាក៏បានរស់ជីវិតជាថ្មីទៀត។ រាពណ៍ខឹងណាស់ក៏ប្រើឥន្ទ្រជិតចេញច្បាំងសាជាថ្មី។ បន្ទាប់មកក៏ប្រើកូនទាំង១០ឱ្យទៅច្បាំងទៀត ហើយត្រូវស្លាប់ទាំងអស់។

សាស្ត្រារឿងរាមកេរ្តិ៍ខ្មែរ ត្រង់វគ្គចាប់ពីខ្សែទី១១ដល់ខ្សែទី៧៤ ត្រូវបានបាត់បង់រកពុំឃើញ និងចាប់បន្តទៅទៀតពីខ្សែទី៧៥ដល់ចប់។

ខ្សែទី៧៥ ចាប់ផ្តើមពីព្រះរាម និងព្រះលក្សណ៍បាននាំរេពលសេនាទៅប្រពាតព្រៃ។ ព្រះនាងសីតាគង់នៅក្នុងប្រាសាទនៃព្រះនគរអយុធ្យា។ កាលនោះមានយក្ខិនីឈ្មោះនាង អាតុល័យ ត្រូវជាសាច់ញាតិរបស់ក្រុងទសមុខរាពណ៍រស់នៅក្រោមដីបានកាឡាខ្លួនជាស្នំ ចូលមកនិយាយប្រលោមលួងចិត្តព្រះនាងសីតាឱ្យរៀបរាប់អំពីរូបរាងកាយក្រុងរាពណ៍ ហើយសុំឱ្យព្រះនាងសីតាគូររូបទសមុខរាពណ៍លើក្តារខៀន។ ខណៈ នោះ ព្រះរាម និងព្រះលក្សណ៍យាងវិលចូលមកព្រះនគរវិញ។ ព្រះនាងសីតាមានការភិតភ័យក៏ប្រញាប់ប្រញាល់លុបរូបយក្សទសមុខនោះ តែលុបមិនជ្រះស្អាត ក៏យកទៅញាត់លាក់ក្រោមក្រឡាបន្ទំ។

លុះដល់សន្ធិយារាត្រី ព្រះរាមក៏យាងចូលទៅក្នុងក្រឡាបន្ទំក៏បែរជាក្តៅក្រហល់ក្រហាយ។ ព្រះរាមបញ្ជាឱ្យព្រះអនុជរើកកាយរកគ្រប់ទីកន្លែងក្នុងក្រឡាបន្ទំ ក៏ឃើញក្តារខៀននៅក្រោមគ្រែព្រះនាងសីតាមានរូបយក្សក្រុងរាពណ៍។ ឃើញដូច្នោះព្រះរាមក៏ទ្រង់ខ្ញាល់ ហើយក៏ទ្រង់ត្រាស់បញ្ជាឱ្យព្រះលក្សណ៍យកព្រះរាជទេពី យកទៅប្រហារជីវិត។ ដោយមានចិត្ត



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អាណិតព្រះរាជទេពីដែលទ្រង់គភ៌ផង ព្រះលក្សណ៍ក៏ក្រាបលំឱនកាយ ហើយសុំអង្វរព្រះនាងឱ្យយាងចេញទៅ។ ព្រះនាងសីតាក៏យាងតែមួយអង្គឯងកាត់ព្រៃព្រឹក្សាពរពោះគ្រប់ខែផង។ ព្រះឥន្ទ្រកោសីយ៍ទ្រង់ទតយល់នូវទុក្ខលំបាកនៃនាងសីតាក៏និម្មិតជាមហិង្សរាជ ហើយនាំព្រះនាងឆ្ពោះទៅកាន់អាស្រមឥសីវិជ្ជប្រិត។ ឥសីក៏ជប់ឱ្យកើតជាអាស្រមសម្រាប់នាងរក្សាគភ៌បន្ទាប់មកក៏បានប្រសូត ព្រះរាជបុត្រមួយព្រះអង្គ។ ព្រះនាងដោះចិញ្ចៀនព្រះទម្រង់ចងដៃព្រះឱរស ដែលមានព្រះនាមថារាមលក្សណ៍ ហើយតាឥសីជប់ក្មេងម្នាក់ទៀតឈ្មោះ ជប្បលក្សណ៍។

លោកតាឥសីក៏បានបង្រៀនសិល្បសាស្ត្រគម្ពីរវេទឱ្យក្មេងទាំងពីរចេះចាំសព្វមន្តអាគម វិជ្ជាបាញ់ធ្នូសរ ទាំងពីរអង្គព្រមទាំងជប់ធ្នូសរថ្វាថ្វាយទៀត។ ព្រះនាងសីតាទ្រង់អរនឹងបុត្រាទាំងទ្វេដែលបានចេះមន្តវិជ្ជាការផ្សេងៗ។ នាងសីតានិទានរឿងពីអតីតកាលឱ្យរាជបុត្រស្តាប់។ ដំណឹងថា មានអ្នកមានបុណ្យរស់នៅក្នុងព្រៃដឹងដល់ព្រះរាម។ ហនុមានមានបំណងចាប់រាជកុមារ តែត្រូវមួយធ្នូវីធវាយដួលត្មោលដេកដី ហើយជប្បលក្សណ៍បោចវល្លិចាប់ហនុមានចង ហើយបញ្ជូនទៅឱ្យម្ចាស់។ ព្រះរាមរឹតតែខឹងឆេវឆេះទើបត្រាស់បញ្ជាឱ្យហនុមានទៅប្រាប់ព្រះអនុជភិរុត សុត្រុត ឱ្យលើកទ័ពទៅឡោមព័ទ្ធកុមារទាំងទ្វេ យកមកថ្វាយទ្រង់ភ្នាម។

រាជកុមារមិនខ្វបខ្វាចព្រះភិរុត និងព្រះសុត្រុតឡើយ។ សង្គ្រាមកំពុងតែជាប់ដៃគ្នា ហនុមានបានកាឡាខ្លួនដ៏ធំមហិមាបម្រុងលោតទៅសង្គ្រប់ចាប់ព្រះរាជកុមារតែត្រូវនឹងដងធ្នូសន្ទប់ធំ។ ហនុមាន និងពលសេនារត់ចូលឈូធរទៅប្រចាប់ក៏ចាប់បានតែរាមលក្សណ៍ ឯជប្បលក្សណ៍រហ័សរត់រួចខ្លួនសំដៅទៅអាស្រមតាឥសី និងព្រះមាតា។ ព្រះនាងសីតាកាលបើបានជ្រាបអំពីរាមលក្សណ៍ត្រូវកងទ័ពចាប់ហើយ ក៏ព្រួយបារម្ភភ័យតក្កមា។ ជប្បលក្សណ៍ សូមខ្លួនជានាទៅតាមយកអាសាបង។ ព្រះនាងសីតា ក៏ប្រទានព្រះទម្រង់ដល់ព្រះរាជបុត្រ ដើម្បីជាភស្តុតាង។ អ្នកនគរគេនាំគ្នា



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

និយាយពីមាត់មួយទៅមាត់មួយថា នៅថ្ងៃស្អែកគេនឹងយកកុមារពាមលក្សណ៍ទៅប្រហារជីវិតហើយ។ ព្រះឥន្ទ្រក៏ទ្រង់បើកទិព្វចក្ខុយល់ហេតុការណ៍ដូច្នោះ ក៏ប្រើនាងទេពរម្ភាឱ្យចុះមកជួយយកអាសា។

នាង ទេពរម្ភាធិតាស្រីសួគ៌ កាឡាខ្លួនជាស្រីជំទង់តម្រង់មកជប្បលក្សណ៍ ធ្វើជាសាកសួរដឹងដើមចមហើយប្រាប់ថា ខ្លួននាងមករកដងទឹកទៅធ្វើបុណ្យដល់អ្នកទោស។ ដោយសារតេជៈទឹកមន្តព្រះឥន្ទ្រ និងគុណព្រះទម្រង់នៃព្រះមាតា ពាមលក្សណ៍ក៏រំដោះរួចពីទ្រុងដែក ហែកចេញមកជួបជប្បលក្សណ៍ដែលនៅពួនសម្ងំក្រោមដើមជ្រៃក្រៅទ្វារនគរ។ ព្រះពាម បន្ទាប់ពីបានជ្រាបអាថ៌សេចក្ដីថា អ្នកទោសដែលត្រូវប្រហារជីវិតនោះត្រូវហែកទ្រុងដែកចេញរួចទៅ ក៏ទ្រង់ក្រេវក្រោធខ្លាំងណាស់ក៏ត្រាស់បញ្ជាឱ្យក្ដុំពលមួយរំពេច ដើម្បីចេញទៅចាប់អ្នកទោសយកមកវិញឱ្យទាល់តែបាន។ ព្រះភិរុតទតស្គាល់មុខពាមលក្សណ៍ដ៏មានភក្ត្រដូចជប្បលក្សណ៍ក៏ថ្លែងសរសេក្ដិអន្ទាក់យ៉ាងច្រើន ដើម្បីចាប់ចងក្មេងទាំងពីរ។ ពាមលក្សណ៍ជប្បលក្សណ៍ក្លាហានគ្មានតក់ស្លុតភិតភ័យអ្វីសោះ ក៏ថ្លែងតបដកព្រះខ័នកាប់អន្ទាក់ដាច់ខ្ទេចខ្ទីគ្មានសល់។ ព្រះពាមថ្លែងសរជាភ្លើងឆេះរន្ទាលពេញអាកាស។ ពាជកុមារមិនបង្អង់ដៃក៏ថ្លែងសរជាព្រះភិរុណបង្ក្រាបសរព្រះពាមត្រូវរលត់អស់ទៅវិញ។ ព្រះពាមថ្លែងសរជាសត្វគ្រុឌម្ដងវិញ ប៉ុន្តែត្រូវខ្យល់ក្រិសផាត់របស់ពាមលក្សណ៍ផាត់បាត់វិនាសទៅអស់ទៀត។ ព្រះពាមកើតសង្ស័យ និងវិទ្ធីចេស្ដារបស់កុមារណាស់ក៏សច្ចាផ្សងជាពូជពង្សអង្គអញសូមឱ្យសរកើតជាភោជនាហារបូជាដូចប្រាថ្នា។ ពាមលក្សណ៍ ជប្បលក្សណ៍សញ្ជឹងគិតខ្លាចគេទៅយាយីដល់ព្រះមាតាក៏មិនព្រមទូលការណ៍ពិតដល់ព្រះពាមវិញឡើយ។ លុះដឹងរឿងពិតហើយ ព្រះពាមក៏អង្វរពាជកុមារទាំងពីរឱ្យចូលទៅគង់ក្នុងនគរ តែព្រះពាជកុមារពុំព្រម ហើយត្រឡប់មកអាស្រមលោកតាឥសី។ ព្រះពាមអង្វរព្រះនាងសីតាពីក្រៅអាស្រមឱ្យបើកទ្វារថ្វាយក៏ប៉ុន្តែ ព្រះនាងមិនព្រម។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*ព្រះរាម ខំលួងលោមព្រះនាងសីតាឱ្យត្រឡប់ទៅកាន់អយុធ្យាវិញ តែព្រះនាងមិនយល់ព្រម។ រាមលក្សណ៍ ជប្បលក្សណ៍ បង្គំលាព្រះរាម ជាបិតា និងអយ្យកា យាងទៅលេងនឹងព្រះមាតា។ ព្រះនាងសីតារំឭកនឹក ឃើញរឿងដើម ក៏រឹងរិតតែខ្លាច់ ហើយទ្រង់មានសុវណ្ណីថា នាងនឹងវិល ត្រឡប់ចូលនគរ លុះណាតែព្រះរាមចូលសុវណ្ណគត។ ព្រះរាមក៏ធ្វើឧបាយ ចូលកោដិបញ្ឆោតនាងសីតាឱ្យចូលនគរ។ ព្រះនាងសីតាស្មានថា ព្រះរាម ចូលសុវណ្ណគតមែន ទ្រង់សោយសោកយ៉ាងខ្លាំងហើយក៏ចូលគោរពវិញ្ញាណ-ក្ខន្ធព្រះស្វាមីនៅក្នុងរាជធានី។ ព្រះនាងយំសោករៀបរាប់បោកខ្លួនរហូត ដល់សន្លប់។ លុះព្រះនាងភ្ញាក់ស្មារតីឡើងឃើញព្រះភ័ក្ត្រស្វាមីក៏ស្ទុះរត់ ហើយ ត្មះតិះដៀលឱ្យស្វាមី។ ព្រះរាមតាមអង្វរពុំបានដូចបំណង។*

**២.២.២.២ ទ្រឹស្តីព្រាហ្មណ៍និយម**

*ព្រហ្មញ្ញសាសនាវិវត្តចេញពីលទ្ធិវេទនិយម។ លទ្ធិព្រាហ្មណ៍និយម បែងចែកពិភពលោកជាបីផ្នែក ៖ ឋានទេវតា ឋានមនុស្សលោក និងឋាន បាតាល។ ចំណែកមនុស្សលោកចែកចេញជាពីរប្រភេទ ៖ មនុស្សអស្ចារ្យ និងមនុស្សធម្មតា។ ព្រហ្មញ្ញសាសនាគោរពអាទិទេពបី ៖ (១)ព្រះព្រហ្មជា អ្នកបង្កើតលោក (២)ព្រះវិស្ណុជាអ្នកគ្រប់គ្រងថែរក្សាលោក បែងភាគជា អវតា ដើម្បីជួយមនុស្ស និង(៣)ព្រះសិវៈដែលមានមុខងារជាអ្នកបំផ្លាញ លោក។ ដើម្បីសម្រេចបានសេចក្តីសុខពិតប្រាកដ ៖ (១)បំបាត់កម្មដែល ជាប្រភពនៃសង្សារ (២)បួសជាតាបស ដើម្បីធ្វើសមាធិ (៣)បង្កើតវិជ្ជា ឱ្យយល់ខ្លួនច្បាស់ជាព្រហ្ម័ន និង(៤)បំបាត់តណ្ហា និងការជំពាក់នឹង ប្រយោជន៍លោកិយ។*

**២.២.២.៣ ទស្សនៈសំខាន់ៗក្នុងរឿងរាមកេរ្តិ៍**

*រឿងរាមកេរ្តិ៍បង្ហាញនូវទស្សនៈសំខាន់ៗ ដែលមានជាលក្ខណៈសង្គម*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

លក្ខណៈអច្ឆរិយៈ លក្ខណៈមនុស្ស និងចរិយាធម៌ ដូចតទៅ ៖

**លក្ខណៈសង្គម** ៖ រឿងរាមកេរ្តិ៍ គឺជានិមិត្តរូបនៃសង្គ្រាមរវាងសភាវៈអាក្រក់ ដែលតំណាងដោយក្រុងរាពណ៍ និងព្រះរាម ដែលជាតំណាងសភាវៈល្អ និងជាអវតារនៃព្រះវិស្ណុដែលមានភារកិច្ចជួយថែរក្សាលោក និងមនុស្សជាតិ។ ក្នុងន័យនេះ រឿងរាមកេរ្តិ៍មានលក្ខណៈជារឿងសង្គមមនុស្ស និងជាការតស៊ូដើម្បីរកយុត្តិធម៌ក្នុងសង្គម។

**លក្ខណៈអច្ឆរិយៈ** ៖ ព្រះរាម គឺជាអវតារនៃព្រះវិស្ណុ ដែលមានញាណយ៉ាងមោះមុត ហើយប្រព្រឹត្តទៅតាមទេវៈបញ្ជា។ ព្រះរាមបង្ហាញនូវអច្ឆរិយភាព ដោយព្រះអង្គគឺជាតួអង្គតែមួយគត់ ដែលអាចលើកធ្នូសរបួចនៅនគរមិថិលា ព្រះអង្គផ្ចាញ់យក្ខជាច្រើន ប្រកបដោយជោគជ័យដូចជាពាមាសូរ និងពិរាធ ដែលមានចិត្តកំណាចឃោរឃៅ ចង់ចាប់ឆក់យកព្រះនាងសីតា។ ព្រះរាមថ្វៃងសរសម្លាប់មេទ័ពយក្ខឈ្មោះខុនទូសណ៍ ត្រីសិរៈ និងក្រុងខរ ដែលជាបងរបស់នាងសូបនខា ដោយសារពួកគេចង់សងសឹក។ ព្រះរាមបញ្ចេញមហិទ្ធិឫទ្ធិឱ្យស្វឹកឈើ និងផ្កាឈើដែលឆេះក្រៀមក្លាយជាស្រស់ញញឹមឡើងវិញ និងធ្វើឱ្យព្រះអាទិត្យបន្ថយកម្តៅបាន ធ្វើឱ្យសត្វសាហាវប្រែជាសត្វស្លូត។

ក៏ប៉ុន្តែ អំណាចរបស់អាទិទេពក៏នៅមានកម្រិតដែរ។ ព្រះរាមនៅចាញ់កលល្បិចរបស់ក្រុងរាពណ៍ ដែលឱ្យសេនាកាឡាខ្លួនជាប្រើសមាសដើម្បីយកឱកាសចាប់នាងសីតាយកមកធ្វើជាមហេសី ដើម្បីសងសឹកឱ្យប្អូនស្រី ដែលត្រូវបានព្រះលក្សណ៍ចាប់កោសក់ និងកាត់ដៃ។

**សច្ចធម៌** ៖ ព្រះរាម គឺក្សត្រិយ៍ដែលប្រកាន់សច្ចធម៌។ ព្រះអង្គមិនព្រមឡើងគ្រងរាជ្យតាមប្រពៃណី ដោយព្រះបាទទសរថធ្លាប់បានសន្យានាងកៃកេសី ថានឹងឱ្យបុត្ររបស់ព្រះនាងឈ្មោះ ភិរុត ឡើងគ្រងរាជ្យវិញ នៅពេលដែលនាងជួយព្រះអង្គក្នុងសង្គ្រាមបានឈ្នះព្រះអាទិត្យ។ ដើម្បីប្រកាន់សច្ចធម៌ ព្រះរាមសុខចិត្តចាកចោលនគរ ទៅបំបរបង់អស់រយៈពេល១៤ឆ្នាំ



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ដើម្បីទុករាជសម្បត្តិឱ្យព្រះកិរុតឡើងសោយរាជ្យ។

**លក្ខណៈមនុស្ស** ៖ នៅក្នុងទំនាស់រវាងព្រះរាម ជាមួយនឹងពាលី ដែលជាស្តេចស្វានៅខាស់ខិនបុរី ព្រះរាមបានប្រើល្បិចដូចមនុស្សដែរ ដោយថ្វែងសរព្រហ្មមាស និងលបបាញ់ស្វាពាលីពីក្រោយ នៅពេលដែលស្វាពាលីកំពុងតែប្រយុទ្ធជាមួយសុគ្រីពជាប្អូន។ មតិខ្លះយល់ថា ព្រះរាមគឺជាមនុស្សកំសាក ដែលលួចបាញ់គេពីក្រោយខ្នង។

ថ្វីត្បិតតែព្រះរាមជាអវតារនៃព្រះវិស្ណុ ព្រះរាមនៅតែត្រូវពឹងឱ្យសុគ្រីពជួយកេណ្ឌទ័ពហនុមាននៅឯកន្ទលីវ៉ែន ក្នុងការធ្វើសង្គ្រាមជាមួយលង្កា។ ម្យ៉ាងវិញទៀត ដើម្បីយកជ័យជម្នះលើក្រុងរាពណ៍ ព្រះរាមត្រូវចងសម្ព័ន្ធមិត្ត ជាមួយមហាជម្ពូ ដែលសោយរាជ្យនៅហេមពាន្ត ដើម្បីពឹងលើទ័ពជំនួយពីមហាជម្ពូ ក្នុងការសង់ស្ពានកាត់សមុទ្រទៅលង្កា។

នៅក្នុងរឿងរាមកេរ្តិ៍ អ្នកនិពន្ធបង្ហាញលក្ខណៈមនុស្សរបស់ព្រះរាម ដែលចេះខឹង ចេះស្រឡាញ់ និងចេះស្អប់។ នៅពេលដែលព្រះលក្សណ៍ច្បាំងចាញ់អង្គត ព្រះរាមទ្រង់ខ្ញាល់ជាខ្លាំង ហើយបម្រុងនឹងថ្វែងសរប្រល័យទេវលោកចោល ទុកតែស្ថានព្រះឥសូរមួយប៉ុណ្ណោះ។ ថ្វីត្បិតខ្លួនជាអាទិទេព ព្រះរាមនៅតែត្រូវបន់ទេវតា។ នៅពេលព្រះលក្សណ៍ចេញតតាំងនឹងឥន្ទ្រជិត យក្សក៏កៀសខ្លួនបាំងបាត់ក្នុងពពក។ ព្រះរាមភ័យណាស់ ហើយក៏បន់ស្រន់ទេវតាសុំឱ្យជួយមើលឃើញយក្ស។ ការបន់ស្រន់បានសម្រេចដូចបំណង ព្រះរាមក៏ថ្វែងសរព្រហ្មមាសប្រហារឥន្ទ្រជិតស្លាប់ទៅ។

ព្រះរាមចូលកោដិបញ្ឆោតនាងសីតា ៖ ព្រះរាមចាញ់កលយក្ខិនីឈ្មោះនាង អាតុល័យ ដែលជាសាច់ញាតិរបស់ក្រុងទសមុខរាពណ៍ ហើយយកព្រះនាងសីតាទៅលម្ងាប់ចោល។ លុះដល់ដឹងរឿងច្បាស់ ព្រះរាមក៏ធ្វើឧបាយចូលកោដិបញ្ឆោតនាងសីតាត្រឡប់មកនគរវិញ។ ព្រះនាងសីតាស្មានថាព្រះរាមចូលសុវណ្ណគតមែន ទ្រង់សោយសោកយ៉ាងខ្លាំងហើយក៏ចូលគោរពវិញ្ញាណក្ខន្ធព្រះស្វាមីនៅក្នុងរាជធានី។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

### ២.២.៣ អត្ថរសនៃរឿងរាមកេរ្តិ៍

*«អត្ថរស»នៃរឿងរាមកេរ្តិ៍សំដៅលើរសជាតិខ្លឹមសារ ដែលធ្វើឱ្យអត្ថបទមានលម្អ មានលក្ខណៈពីរោះជាទីចាប់ចិត្ត ចាប់អារម្មណ៍។ តម្លៃនៃស្នាដៃអក្សរសិល្ប៍ព្រាហ្មណ៍និយមខ្មែរស្តែងចេញនូវការស្ទបញ្ចូលគ្នានូវទស្សនៈព្រហ្មញ្ញសាសនា ជាមួយនឹងទស្សនៈខ្មែរ ក្នុងការអប់រំមនុស្ស ដើម្បីសម្រេចបានសេចក្តីសុខពិតប្រាកដ តាមរយៈការបំបាត់កម្ម ការធ្វើសមាធិ ការបង្កើតវិជ្ជា ការបំបាត់តណ្ហា និងការគិតគូរពីប្រយោជន៍រួម។ អត្ថរសនៃអត្ថបទអក្សរសិល្ប៍ព្រាហ្មណ៍និយមអាចចែកចេញជា ៖*

*ទីមួយ* ***បច្ចេករស*** *ដោយប្រើប្រាស់ពាក្យកាព្យ និងរៀបចំជាដំណើររឿងឱ្យមានភាពអណ្តែតអណ្តូងឱ្យអ្នកអានរំភើបតាមដំណើររឿង។ កំណាព្យនិពន្ធរឿងរាមកេរ្តិ៍ គឺជាអត្ថបទកំណាព្យដែលសរសេរជាអក្សរខ្មែរក្នុងស.វ. ទី១៥-១៦នៅសម័យលង្វែក មុននឹងការវិវត្តនៃភាសាខ្មែរ និងកំណាព្យខ្មែរក្នុងសតវត្សទី ១៧-១៩ ដែលនៅពេលនោះ កំណាព្យនៃស្នាដៃអក្សរសិល្ប៍ពុទ្ធនិយមបានឈានដល់កម្រិតកំពូល ទាំងផ្នែកអត្ថរូប អត្ថន័យ និងអត្ថរស។ កំណាព្យរឿងរាមកេរ្តិ៍សរសេរជាពាក្យ៧ ដោយមានចាប់ចុងជួនរវាងល្បះ និងរវាងឃ្លា។*

*ទម្រង់បែបបទនៃកំណាព្យរឿងរាមកេរ្តិ៍៖ ទម្រង់បែបបទនៃការតែងកំណាព្យក្នុងរឿងរាមកេរ្តិ៍មានការផ្លាស់ប្តូរ។ រឿងរាមកេរ្តិ៍ពីខ្សែ១ដល់១០ កំណាព្យតែងជា៣ល្បះ ដោយមានចាប់ចុងជួនរវាងល្បះ និងរវាងឃ្លា។*

ឯក្រុងរាពណ៍លុះលង្កា ក្រេវក្រោធដ៏ក្រៃទា ក៏ភ្ជុំនូវគ្រឿងអាវុធ។
ប្រើឥន្ទ្រជិតរាជបុត្រ ដោយតេជោឫទ្ធ នូវពលយក្សទ្វេគុណា។
រៀបពលមហិមាលើសមុន ក្រោយឆ្វេងស្តាំលន់ ពន់ពេកនូវពលកុម្ភន្ធ។
ឥន្ទ្រជិតលាក្រុងទសកណ្ឋ កាន់ធនូសរខ័ន ក៏ឡើងច្បានយាត្រា។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*ក៏ប៉ុន្តែ រឿងរាមកេរ្តិ៍ពីខ្សែ៧៥ដល់៨០ កំណាព្យតែងជា៤ល្បះ ដោយមានចាប់ចុងជួនរវាងល្បះ និងរវាងឃ្លា។*

កាលអើយកាលនោះ　ព្រះនារាយណ៍រុងរឿងឫទ្ធិ　ស្តែងស្តេចផ្ទុំលើទែនទី<br>
នែបនឹងនាងនាងសីតា។

ប្រទីបផ្កាលាព្រោងព្រាត　គ្រប់ល្វែងប្រាសាទសុវណ្ណា　ឯអស់ស្នំស្និទ្ធស្នេហា<br>
អង្គុយយាមដូចសព្វដង។

លុះព្រះសុរិយារឿងរះ　ឧទ័យថ្លាជ្រះម៉ដ្ឋហ្មង　ភ្ញាក់ងារប្រគំភ្លេងផង<br>
តូរ្យតន្ត្រីត្រែស្រទៃ្យ។

ព្រះនារាយណ៍តើនចាកនិន្ទ្រា　ស្រប់ព្រះភក្ត្រាហើយនៃ　ចរជួបព្រះអនុជថ្លាថ្លៃ<br>
ចរចូលទៅស្រង់គង្គា។

*ដោយទម្រង់បែបបទនៃការតែងកំណាព្យក្នុងរឿងរាមកេរ្តិ៍ពីខ្សែ១ដល់១០ ខុសពីទម្រង់បែបបទនៃការតែងកំណាព្យក្នុងរឿងរាមកេរ្តិ៍ពីខ្សែ៧៥ដល់៨០ ទើបមានមតិខ្លះបានលើកឡើងថា កវីនិពន្ធដែលតែងរឿងរាមកេរ្តិ៍ពីខ្សែ១ដល់១០ និងកវីនិពន្ធដែលតែងរឿងរាមកេរ្តិ៍ពីខ្សែ៧៥ដល់៨០ គឺជាមនុស្សពីរនាក់ផ្សេងគ្នា។ ម្យ៉ាងវិញទៀត នៅក្នុងរឿងរាមកេរ្តិ៍ពីខ្សែ៧៥ដល់៨០ អ្នកនិពន្ធតែងជាបទផ្សេងៗគ្នា ដូចជាបទឆា បទរាយ បទទ្រង់គ្រឿងជាដើម សម្រាប់សូត្រ។*

*យើងឃើញថា កំណាព្យរាមកេរ្តិ៍តែងនៅក្នុងស.វ.ទី១៥-១៦ នៅមិនទាន់មានបទ ដែលគេនិយមប្រើដូចជា បទព្រហ្មគីតិ បទពំនោល និងបទកាកគតិនៅឡើយ ហើយដែលត្រូវបានយកមកតែងក្នុងកំណាព្យ«ល្បើកអង្គរវត្ត» ដែលជាវណ្ណកម្មរបស់កវី ប៉ាង តាត នៅក្នុងឆ្នាំ ១៦២០ ដែលតែងដោយប្រើពាក្យខ្មែរកណ្តាលដូចគ្នាដែរ។*

*ទីពីរ* ***វិសេសរស*** *ដោយបង្ហាញពីតម្លៃល្អ តម្លៃអាក្រក់ សកម្មភាពអស្ចារ្យ វីរភាពរបស់តួអង្គ សកម្មភាពតស៊ូរបស់តួអង្គ សោកនាដកម្ម និង*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សកម្មភាពរស់រវើក និងកំប្លែង ដើម្បីឱ្យអ្នកអានរីករាយ។

ព្រះរាមស្ដេចមើលអស់ភូ- ធរលើកឫទ្ធិធនូ ក៏ព្រើសព្រះភក្ត្រប្រិមប្រិយ៍។
ស្ដេចចូលលងឫទ្ធិដ៏ពិធី អស់ទេពីដ៏ឥសី ក្សត្រទតអានុភាពចេស្ដា។
ព្រះរាមរឹងឫទ្ធិហោះហិហ ស្ដែងស្ដេចចេស្ដា ធិការនុភាពលើសក្រៃ។
ស្ដេចលើកកៅទ័ណ្ឌសរជ័យ អស់ទេពមនុស្សព្រួ ដ៏មានកំឡាំងលោកធាតុ។
សឹងថ្វាយសព្ទសាធុការសាទរ ព្រះបរមនាថ ឫទ្ធីអំណាចយល់ថ្កើង។
ស្ដេចវាត់កៅទ័ណ្ឌបីជុំឡើង កោះសរសក្ដិថ្លើង សម្ដែងនូវតេជប្រត្យ័ក្ស។
ស្ដេចក្រាយកៅទ័ណ្ឌសរសក្ដិ រូមណ្ឌលចក្រ រំភាយព្រះកេសោភា។

ទីបី **សព្វរស** ដោយឆ្លុះបញ្ចាំងពីតថភាពក្នុងសង្គម ជីវភាពប្រចាំថ្ងៃ និងកុសលរសដែលជាតម្លៃនៃការទូន្មានប្រៀនប្រដៅ។

ខ្ញុំសូមពិចារណាបកស្រាយ នូវគំនិតនៅក្នុងរឿងរាមកេរ្តិ៍ ដូចតទៅ៖

១) **គំនិតអប់រំពីចំណេះវិជ្ជាជាសម្បត្តិមហាសាល** ៖ ព្រះរាម និងព្រះលក្សណ៍រៀនចេះចប់គម្ពីរនៃព្រហ្មញ្ញសាសនា ពីឥសីពិស្វាមិត្រដែលជាគ្រូបាអាចារ្យ រួចហើយអាចលើកធ្នូសរ ហើយបានព្រះនាងសីតាជាមហេសី។

២) **គំនិតអប់រំមនុស្សឱ្យមានសច្ចធម៌** ៖ ព្រះរាមប្រកាន់នូវសច្ចធម៌ ដោយពុំព្រមឡើងសោយរាជ្យ ហើយទុករាជ្យបល្ល័ង្កឱ្យភិរុត ជាព្រះអនុជសោយរាជ្យ តាមពាក្យសន្យារបស់ព្រះបិតា ព្រះទសរថ។

៣) **គំនិតអប់រំមនុស្សកុំឱ្យមានចិត្តពោរពេញដោយកំហឹងនិងសងសឹក** ៖ នាងសូបនខានាំមកនូវមហន្តរាយ ដោយញុះញង់បងៗនាង ដូចជាក្រុងខរ និងក្រុងពពណ៌ ឱ្យចេញមកសងសឹក ដោយសារព្រះលក្សណ៍ដាច់សីលខ្វាល់នឹងនាងមករុកគួន ហើយក៏កោសក់កាត់ដៃរបស់នាង។

៣) **គំនិតអប់រំមនុស្សកុំឱ្យលោភលន់ និងត្រូវចេះគោរពជីវិតសត្វលោក** ៖ ប្រសិនបើព្រះនាងសីតាមិនលោភចង់ប្រហារប្រើសមាស ដើម្បី



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

យកស្បែកទុកលម្អទេនោះក្រុងរាពណ៍ពិតជាមិនអាចមានឱកាសឆក់ព្រះនាងសីតាបានឡើយ។

៤) **គំនិតអប់រំមនុស្សឱ្យមានចិត្តសណ្ដោសប្រណី** ៖ ស្ដេចក្របីមហិង្សរាជ គ្មានចិត្តប្រណី ហើយសូម្បីតែកូនខ្លួនឯងក៏មិនទុកដែរ ដោយមិនចង់ឱ្យមានអ្នកខ្លាំងជាងខ្លួន។ តែទីបំផុត នៅតែត្រូវទូភី ដែលខិតខំត្រង-ត្រាប់តាមដំបូន្មានមេក្របីជាម្ដាយឈ្មោះ សន្តគីរី ដែលតែងតែទូន្មានកូនឱ្យហាត់ប្រាណដើម្បីឱ្យមានកម្លាំងបរិបូណ៌មុននឹងទៅជួបឪពុក។ ដោយសារមហិង្សរាជមិនយល់ព្រម ទើបមានការប្រយុទ្ធរវាងឪពុកនិងកូន ហើយទីបំផុតទូភីក៏ប្រហារជីវិតឪពុកខ្លួនទៅ។ ភ្នំមួយខ្ពស់ តែងតែមានភ្នំខ្ពស់ជាងជាក់ជាមិនខាន។

៥) **គំនិតអប់រំកុំឱ្យមានអំនួត** ៖ ទូភីសម្លាប់ស្ដេចក្របី មហិង្សរាជហើយមានអំនួត តែងតែដើររករឿងរាតត្បាតគេឯង ដូចជារករឿងឥសីបញ្ចលិង្គ នាងទេពធីតារក្សាសមុទ្រព្រៃហេមពាន្ត និងទៅរករឿងពាលី ដែលជាស្ដេចស្វាសោយរាជ្យនៅខាស់ខិនបុរី ហើយទីបំផុត ពាលីក៏ប្រហារទូភីនឹងព្រះខ័នស្លាប់ទៅ។

៦) **គំនិតក្នុងការដោះស្រាយទំនាស់** ៖ តាមរយៈសង្គ្រាម ការចរចាការចងសម្ព័ន្ធ និងការពឹងផ្អែកលើវាសនា ព្រហ្មលិខិត តាមរយៈអន្តរាគមន៍របស់អាទិទេព។ ព្រះរាមបានបង្ហាញពីទេពកោសល្យ ក្នុងការដោះស្រាយទំនាស់ ដោយប្រើប្រាស់អស់មធ្យោបាយដែលមាន។ ដើម្បីយកឈ្នះលើក្រុងរាពណ៍ ព្រះរាមជួយសុគ្រីពសម្លាប់ពាលី ដើម្បីឱ្យសុគ្រីពជួយកេណ្ឌទ័ពហនុមាន។ បន្ទាប់មក ព្រះរាមចងសម្ព័ន្ធមិត្តជាមួយស្ដេចស្វា មហាជម្ពូសោយរាជ្យនៅព្រៃហេមពាន្ត ដើម្បីសុំទ័ពជំនួយសាងសង់ស្ពានកាត់សមុទ្រទៅលង្កា។ ព្រះរាមទទួលពិភេក ដែលត្រូវក្រុងរាពណ៍បណ្ដេញចេញពីលង្កា ហើយចាត់ពិភេកទៅនិយាយបញ្ចុះបញ្ចូលកុម្ភការណ៍ តែកុម្ភការណ៍មិនព្រះក្បត់ក្រុងរាពណ៍។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*៧) **គំនិតក្នុងការគ្រប់គ្រងប្រទេស** ៖ ត្រូវចេះស្ដាប់មតិគេឯង ទោះបីជាមតិទាំងនោះខុសពីគំនិតរបស់ខ្លួនក៏ដោយ។ ប្រសិនបើក្រុងរាពណ៍ស្ដាប់តាមគំនិតរបស់ពិភេគ នោះប្រហែលជាព្រះរាមមិនអាចកម្ទេចលង្កាបានឡើយ ដោយពិភេគបានទាយពីវាសនានៃនគរលង្កា ហើយស្នើក្រុងរាពណ៍ឱ្យយកព្រះនាងសីតាទៅថ្វាយព្រះរាមវិញ។*

*៨) **គំនិតអប់រំឱ្យមានចិត្តស្មោះត្រង់** ៖ កុម្ភការណ៍ពុំព្រមចុះចូលនឹងព្រះរាមទេ ហើយថែមទាំងអះអាងថា ទោះព្រះរាមមានមហិទ្ធិឫទ្ធិយ៉ាងណាក៏ដោយ ទោះជាក្រុងរាពណ៍ខុសដូចម្ដេចក៏ដោយក៏ពុំព្រមរស់នៅក្រោមការត្រួតត្រារបស់ព្រះរាមជាដាច់ខាត គឺសុខចិត្តស្លាប់ក្នុងការបម្រើជាតិ។*

*៩) **គំនិតអប់រំដោះស្រាយបញ្ហាដោយសន្តិវិធី** ៖ ការធ្វើសង្គ្រាមធ្វើឱ្យក្រុងលង្កាលាយ។ ប្រសិនបើក្រុងរាពណ៍ដោះស្រាយតាមសន្តិវិធី នោះប្រហែលជាក្រុងលង្កាមិនជួបនឹងមហន្តរាយទេ។*

*១០) **គំនិតអប់រំឱ្យត្រិះរិះពិចារណា ឱ្យបានគ្រប់ជ្រុងជ្រោយ ហើយកុំជឿតាមពាក្យញុះញង់** ៖ ប្រសិនបើព្រះរាមមិនធ្លាក់ចូលក្នុងអន្ទាក់របស់យក្ខិនី អាតុល័យ ដែលជាសាច់ញាតិរបស់ក្រុងទសមុខរាពណ៍ ហើយសុំឱ្យព្រះនាងសីតាពន្យល់រឿងឱ្យបានច្បាស់លាស់ នោះព្រះរាមប្រាកដជាមិនបែកពីព្រះនាងសីតា និងរាមលក្សណ៍ជាបុត្រឡើយ។*

## III. សេចក្ដីសន្និដ្ឋាន

*អក្សរសិល្ប៍ព្រាហ្មណ៍និយមរឿងរាមកេរ្ដិ៍ គឺជាប្រភេទអក្សរសិល្ប៍ដែលតែងជាពាក្យកាព្យ តាមលំនាំសាច់រឿងនៃ រាមាយណៈ តែត្រូវអ្នកនិពន្ធក្នុងស.វ.ទី១៥-១៦ បានស្នូកែច្នៃឱ្យឆ្លុះបញ្ចាំងសង្គមខ្មែរ និងមនុស្សខ្មែរបាត់ទៅហើយ។ អក្សរសិល្ប៍កំណាព្យខ្មែរ រឿងរាមកេរ្ដិ៍ឆ្លុះបញ្ចាំងពីការវិវត្តនៃអក្សរសិល្ប៍កំណាព្យខ្មែរ ជាពិសេស អក្សរសាស្ត្រខ្មែរជារួម។ តាមរយៈរឿងរាមកេរ្ដិ៍ យើងឃើញថាភាសាខ្មែរបច្ចុប្បន្នមានការវិវត្តយ៉ាង*



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

លឿន ប្រសិនបើប្រៀបធៀបនឹងភាសាខ្មែរសម័យកណ្ដាល ទាំងខាងផ្នែកក្បួនវេយ្យាករណ៍ ការតែងនិពន្ធ ការចាប់ចុងជួនរវាងពាក្យ និងការតែងជាបទសម្រាប់សូត្រ។ រឿងរាមកេរ្តិ៍ បានក្លាយទៅជាជម្រុកពាក្យពេចន៍នៃភាសា និងវោហារសាស្ត្រខ្មែរ ដែលសិល្បករ នាដករ និងអ្នកនិពន្ធខ្មែរបានយកទៅសម្ដែងក្នុងល្ខោនព្រះរាជទ្រព្យ ល្ខោនខោល ល្ខោនស្បែកតូច និងស្បែកធំ ហើយដែលធ្វើឱ្យរឿងរាមកេរ្តិ៍ ជ្រាបចូលជ្រៅទៅក្នុងសង្គមខ្មែរបានយ៉ាងជ្រៅ។ យើងអាចចាត់ថា រឿងរាមកេរ្តិ៍គឺជាបេតិកភ័ណ្ឌអរូបីរបស់ជាតិខ្មែរយើង។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

# ផ្នែកទី៣
# ការវិវត្តអក្សរសិល្ប៍ពុទ្ធនិយម នៅសម័យក្រោយអង្គរ

## I. ទិដ្ឋភាពទូទៅនៃអក្សរសិល្ប៍ខ្មែរសម័យក្រោយអង្គរ

### ១.១ អក្សរសិល្ប៍ខ្មែរសម័យលង្វែក

សម័យក្រោយអង្គរគឺជាសម័យកាល ដែលខ្មែរចុះដុនដាបខាងផ្នែកសេដ្ឋកិច្ច ដោយសារអស្ថិរភាពនយោបាយ ដែលបង្កើតឡើងដោយសារទំនាស់ផ្ទៃក្នុងរាជវង្សខ្មែរ ជាពិសេសបញ្ហាស្នងរាជ្យសម្បត្តិ ការឃុបឃិតនិងទំនាស់រវាងមន្ត្រីជាន់ខ្ពស់ និងសង្គ្រាមជាមួយប្រទេសជិតខាង។ អក្សរសិល្ប៍ខ្មែរចាប់ពីស.វ.ទី១៥ បន្ទាប់ពីការចាកចោលក្រុងអង្គរ ដល់ស.វ.ទី១៩ ត្រូវបានចាត់ទុកថាជាអក្សរសិល្ប៍សម័យកណ្ដាល។

ប្រវត្តិសាស្ត្រខ្មែរសម័យក្រោយអង្គរអាចចែកចេញជាពីរដំណាក់កាលធំៗ[១] ៖

ដំណាក់កាលទី១ ពីឆ្នាំ១៤៣១ដល់១៥៩៥ គឺជាដំណាក់កាលភ្នំពេញ-លង្វែក។ ភ្នំពេញស្ថិតនៅជារាជធានីនៃព្រះរាជាណាចក្រកម្ពុជាធិបតីអស់រយៈពេល៣០ឆ្នាំ។ ក្រោយមក រាជធានីបានលើកទៅស្រីសន្ធរ និងទៅលង្វែក។ នៅក្នុងដំណាក់កាលនេះ ស្ដេចបីអង្គគឺ ស្រីរាជា បរមរាជា និងអង្គចន្ទ បានខិតខំពង្រឹងសន្តិភាព និងស្ថិរភាព ដោយធ្វើការទប់ទល់

[១] Khin Sok (1991). *Le Cambodge entre le Siam et le Vietnam* (de 1775 à 1869), EFEO, Paris, p. 27.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ជាមួយប្រទេសសៀម។ ស.វ.ទី១៦ ខ្មែរបានខិតខំប្រឹងប្រែងងើបឡើងវិញពីអន្ធការ។ ព្រះបាទ អង្គចន្ទ បានចាត់ចែងឱ្យមន្ត្រីធ្វើការជួសជុលអង្គរ[២]។ ក៏ប៉ុន្តែ នៅឆ្នាំ១៥៨៦ ស្តេច សត្ថា បានលើកបុត្រ ជ័យជេដ្ឋា និងពញាតន់ ដែលមានអាយុទើបតែ១១ឆ្នាំ និង៦ឆ្នាំឱ្យឡើងគ្រងរាជ្យ។ មន្ត្រីសព្វមុខអ្នកការមានការមិនសប្បាយចិត្ត ធ្វើឱ្យប្រទេសធ្លាក់ចុះទៅក្នុងវិបត្តិ។ បន្ទាប់ពីការវាយលុកពីប្រទេសសៀម ទីក្រុងលង្វែកត្រូវសៀមវាយបែកក្នុងឆ្នាំ១៥៩៤។ អ្នកចេះដឹងជាច្រើនត្រូវកៀសខ្លួនទៅស្រុកសៀម។ ស្នាដៃអក្សរសិល្ប៍ក៏ធ្លាក់ចុះដែរ ដោយមិនមានអ្វីបន្សល់ទុកជាដុំកំភួន។ ម្យ៉ាងវិញទៀត ក្រាំង និងសាស្ត្រាស្លឹករឹតក៏វិនាសខ្ទេចខ្ទីដោយសារសង្គ្រាមផងដែរ មិនបានបន្សល់ទុកដល់ជនជំនាន់ក្រោយ។ សាស្ត្រាជំនាន់អង្គរជាច្រើនត្រូវបានបាត់បង់ផងដែរនៅក្នុងសង្គ្រាម ខ្លះទៀតត្រូវគេប្រមូលយកទៅទីក្រុងអយុធ្យា[៣] ហើយត្រូវភ្លើងឆេះអស់នៅពេលដែលភូមាដុតក្រុងអយុធ្យាក្នុងឆ្នាំ១៧៦៧។ នៅស.វ.ទី១៧ ខ្មែរបានខិតខំប្រឹងប្រែងកសាងប្រទេស ហើយស្នាដៃអក្សរសិល្ប៍ក៏ចាប់ផ្តើមងើបឡើងវិញដែរ។ ដូច្នេះហើយទើបយើងមិនមានអក្សរសិល្ប៍អ្វីដែលនៅសេសសល់ពីដំណាក់កាលលង្វែកឡើយ។

### ១.២ អក្សរសិល្ប៍ខ្មែរសម័យឧដុង្គ

ដំណាក់កាលទី២ គឺដំណាក់កាលឧដុង្គ នៅស.វ.ទី១៧ និង១៨ នៅពេលដែលស្ថានភាពនយោបាយនៅកម្ពុជាកាន់តែមានសភាពយ៉ាប់យ៉ឺនទៅៗ។ ក្នុងរយៈពេល៣៥០ឆ្នាំ ពោលគឺពីឆ្នាំ១៧៧៦ដល់១៨៦០ កម្ពុជាបានបាត់បង់ទាំងស្រុងនូវតួនាទីនៅជ្រោយកូសាំងស៊ីន។ កម្ពុជាធ្លាក់ចុះបន្តិចម្តងៗទៅក្នុងកលិយុគ។

[២] Saveros Lewitz (1972), « Les inscriptions modernes d'Angkor Wat » *Journal Asiatique* no. 260 (1972) : 1-2, 107-129 ; Edwards, P. (2007), Cambodge, p. 23.

[៣] Khin Sok (1991). *Le Cambodge entre le Siam et le Vietnam (de 1775 à 1869)*. EFEO. Paris. p. 31.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ស្នាដៃអក្សរសិល្ប៍ត្រូវបានកត់ត្រាទុកលើក្រាំង ដែលជាសន្លឹកក្រដាសស្នាច់បត់ជាផ្នត់ និងលើស្លឹករឹត ដែលហៅថាសាស្ត្រា ដែលសរសេរជាពាក្យកាព្យ។ អក្សរសិល្ប៍សម័យកណ្ដាលមានដូចជាសិលាចារឹក(សិលាចារឹកជ័យនន្ទ) របាក្សត្រ ឬព្រះរាជពង្សាវតារ ក្រម-ក្បួន-តម្រា (Les codes cambodgiens) ច្បាប់-សុភាសិត រឿងព្រេង រឿងល្បែង និងវីរកថា[៨]។

«**ច្បាប់**» គឺជាកំណាព្យទូន្មានប្រៀនប្រដៅ ដែលមានលក្ខណៈជាក្រមសីលធម៌ សម្រាប់ត្រងត្រាប់ តែគ្មានលក្ខណៈចាប់បង្ខំឡើយ។ ច្បាប់ទាំងនេះត្រូវបានតែងជាពាក្យកាព្យ ដើម្បីទាក់ទាញ និងឱ្យងាយទន្ទេញចាំមាត់។ ច្បាប់ខ្មែរមាន ច្បាប់ពាក្យចាស់ ច្បាប់មហាបដ្ឋាន ច្បាប់ហែមហាជន ច្បាប់សុភាសិត ច្បាប់បណ្ដាំបិតា ច្បាប់ស្រី ច្បាប់អរិយសត្ថា ច្បាប់វិធូបណ្ឌិត ច្បាប់ធម្មបាលជាដើម។

## ច្បាប់ពាក្យចាស់

១ ពាក្យចាស់ពាក្យពីព្រេង ទោសខ្លួនឯងមើលពុំយល់
ទោសគេតូចសោតសល់ រមិលយល់ប៉ុនទាំងភ្នំ។
២ ចូលព្រៃសត្វសាហាវ រករំពាវគ្នាមកជុំ
ដល់បានស្កុទិកឃ្មុំ ពួនក្នុងជុះស៊ីម្នាក់ឯង។

«**សាស្ត្រាល្បែង**» គឺជាអត្ថបទអក្សរសិល្ប៍ដែលពេញនិយមនៅសម័យឧដុង្គ។ រឿងល្បែងគឺជាស្នាដៃអក្សរសិល្ប៍ ដែលច្នៃប្រឌិតសម្រាប់ប្រលោមលួងលោមអារម្មណ៍ អ្នកអានក្នុងកម្រងភាសាកំណាព្យដ៏ប្រណីត ពោលគឺជាកម្រងអត្ថបទរឿងរ៉ាវបែបប្រពៃណី ដែលតាក់តែងជាកាព្យឃ្លោងឡើងនៅរវាងស.វ.ទី១៨-១៩[៩]។ អ្នកនិពន្ធបំបែរគោលដៅទៅរកការអប់រំ ការសម្រាលទុក្ខសោក ពោគភ័យមួយចំណែកធំរបស់មនុស្សជាតិ។ «សាស្ត្រា

---

[៨] សូមមើល ឃីង ហុកឌី (២០០៣) «ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ» មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ។

[៩] ឃីង ហុកឌី (២០០៣) «ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ» ទំព័រ៩៦។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ល្បែង»[៦] គឺសាស្ត្រាដែលអានសម្រាប់បន្ធូរចិត្តទុក្ខព្រួយ ចិត្តលំបាកតឹងតែង ឱ្យធូរស្រាល[៧]។

សាស្ត្រាមានសាស្ត្រាក្លាម និង សាស្ត្រាសួស្តី ៖

១ កូនអើយអញអា- ពុកប្រដៅបា
ជាកូនពិសី ពិសេសពិសុទ្ធ
ដោយបទបាលី ហៅរាជសួស្តី
មន្ត្រីហោងណា។

ឱ្យរៀនឱ្យសព្វ ឱ្យរៀនឱ្យគ្រប់
កុំឱ្យសល់អី ឱ្យស្គាល់សង្គ្រាម
សឹកសាំក្រក្រី ទើបហៅមន្ត្រី
មានប្រាជ្ញាយល់។

«**រឿងព្រេង**»[៨] គឺជាការនិទាន សេចក្តីតំណាលតាមលំដាប់លំដោយដែលដូនតាយើងនិទានពីមាត់មួយទៅមាត់មួយជាយូរលង់ណាស់មកហើយ និងដែលឆ្លុះបញ្ចាំងឱ្យឃើញពីទំនៀមទម្លាប់ និងប្រពៃណីរបស់ជនជាតិខ្មែរយើង។ រឿងព្រេងទាំងអស់នេះត្រូវបានកត់ត្រាទុកដោយកវីបណ្ឌិតខ្មែរ ជាសំណេរលើស្លឹករឹត ឬលើក្រដាស ដើម្បីទុកជាកេរឱ្យខ្មែរជំនាន់ក្រោយ។ រឿងព្រេងភាគច្រើនត្រូវបានសរសេរជាពាក្យពាយ ហើយគ្មានកាលបរិច្ឆេទទេ។ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យបានចងក្រងរឿងព្រេងខ្មែរ និងបានបោះពុម្ពផ្សាយរហូតដល់ឆ្នាំ១៩៧២ ជា«ប្រជុំរឿងព្រេងខ្មែរ» ដែលមាន៨ភាគ និងមានរឿងទាំងអស់ចំនួន២១៦។ លោកស្រី ពៅ សាវរស

៦ ដូចជារឿង ក្រុងសុភមិត្រ(១៧៩៨) គោគកុលកុមារ(១៩៤០) កាកី(១៨១៥) ដាវរឿង(១៨៣៧)។ល។

៧ លាង ហាប់អាន (១៩៦៧) «សិក្សាប្រវត្តិអក្សរសាស្ត្រខ្មែរ៖ សម័យនគរភ្នំដល់សម័យឧដុង្គ (ស.វ.ទី១ ដល់១៨៥៩)» ទំព័រ ២១៥។

៨ ឃីង ហុកឌី (២០០៣) «ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ» ទំព័រ ៩២-៩៤។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

បានចែករឿងព្រេងទាំងនេះជា ៖ រឿងល្បើក រឿងព្រេងទាក់ទងនឹងដំណើរហេតុផ្សេងៗ រឿងព្រេងប្រជាប្រិយ និងរឿងព្រេងសម្រាប់ស្ថាបនា[៩]។

អស់ជាច្រើនសតវត្សបន្ទាប់ពីការដួលរលំនៃសម័យអង្គរ ទីអារាមព្រះពុទ្ធសាសនាបានក្លាយជាមជ្ឈមណ្ឌលសិក្សារៀនសូត្រ និងក្លាយទៅជាទីកន្លែងសម្រាប់ថែរក្សា និងអភិរក្សវប្បធម៌ ហើយបព្វជិតព្រះពុទ្ធសាសនាគឺតំណាងឱ្យបញ្ញាជនកម្ពុជា។ ប្រព័ន្ធអប់រំខ្មែរសម័យក្រោយអង្គរ គឺជាប្រព័ន្ធអប់រំបែបព្រះពុទ្ធសាសនា។ វត្តអារាមមានតួនាទីយ៉ាងសំខាន់ក្នុងការបណ្ដុះបណ្ដាលធនធានមនុស្សឱ្យមកបម្រើនៅក្នុងរាជការ។ ភាសាយាន គឺភាសាបាលី ដែលជាភាសាកម្រិតខ្ពស់ និងភាសាខ្មែរ ដែលជាភាសាសម្រាប់ប្រជាជនសាមញ្ញ។ ប្រព័ន្ធអប់រំនេះមានចំណុចខ្លាំង និងចំណុចខ្សោយរបស់វា។ ចំណុចខ្លាំងស្ថិតត្រង់ថា ការអប់រំបែបព្រះពុទ្ធសាសនាត្រូវផ្ដោតលើការរៀនសូត្រព្រះត្រៃបិដក ច្បាប់ស្នាដៃអក្សរសិល្ប៍ និងគម្ពីរសាស្ត្រានានាដែលជាមូលដ្ឋាននៃសាសនាព្រះពុទ្ធ។ ក៏ប៉ុន្តែ ដោយសារសំណង់វត្តអារាមគឺជាសំណង់ឈើ គេគ្មានតម្រូវការក្នុងការបណ្ដុះបណ្ដាលស្ថាបត្យករ ឬវិស្វករឡើយ។ ដូច្នេះហើយ កម្មវិធីសិក្សាគ្មានមុខវិជ្ជាដែលពាក់ព័ន្ធនឹងវិទ្យាសាស្ត្រ ដូចនៅអារ្យប្រទេសឡើយ។ ជាក់ស្ដែង យើងគ្មានភស្តុតាងពីវត្តមានអ្នកប្រាជ្ញខាងផ្នែកគណិតវិទ្យា ឬវិទ្យាសាស្ត្រនៅប្រទេសកម្ពុជាឡើយ។ ក៏ប៉ុន្តែ ប្រព័ន្ធអប់រំពុទ្ធសាសនានេះក៏បានផលិតនូវអ្នកប្រាជ្ញ កវីនិពន្ធល្បីៗ ដែលបង្កើតនូវចលនាអក្សរសិល្ប៍ពុទ្ធនិយម ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការស្ទូ ឱ្យអរិយធម៌ខ្មែរមានភាពសម្បូណ៌បែប។ ការវិភាគស្នាដៃអក្សរសិល្ប៍ពុទ្ធនិយមខ្មែរផ្ដោតលើទិដ្ឋភាពធំៗចំនួនបីគឺ ៖ អត្ថរូប អត្ថន័យ និងអត្ថរស។

[៩] Pou, S. (1977), *Etude sur le Ramakerti (XVIe-XVIIe siècles)*, Paris, Pub. EFEO, p. 33-35.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## II. អត្ថរូបនៃអក្សរសិល្ប៍ពុទ្ធនិយមខ្មែរ

### ២.១ ប្រភពនៃអក្សរសិល្ប៍ពុទ្ធនិយម

*អរិយធម៌ខ្មែរមានប្រភពចេញពីលទ្ធិព្រាហ្មណ៍និយមផង ជាពិសេសគឺអរិយធម៌ជំនាន់អង្គរ និងលទ្ធិពុទ្ធនិយមផង ដែលជាអរិយធម៌ខ្មែរជំនាន់ក្រោយអង្គរ។ ចលនាអក្សរសិល្ប៍បែបពុទ្ធនិយមមានរូបសេចក្តី និងសណ្ឋានដែលដកស្រង់ចេញពីប្រភពនៃគម្ពីរព្រះត្រៃបិដក។ ពោល គឺការយកគោលគំនិត និងទស្សនវិជ្ជាព្រះពុទ្ធសាសនាមកផ្ទុះបញ្ចាំង ក្នុងស្នាដៃអក្សរសិល្ប៍ ៖*

*១- វិន័យបិដក (ព្រះវិន័យ)*

*២- សុត្តន្តបិដក (ព្រះសូត្រ)*

*៣- អភិធម្មបិដក (ព្រះអភិធម្ម)។*

*គេនិយមបែងចែកអក្សរសិល្ប៍ពុទ្ធនិយមជាពីរប្រភេទ ៖*

***ទីមួយគឺអក្សរសិល្ប៍ពុទ្ធនិយមពិត*** *ដែលអ្នកនិពន្ធបានដកស្រង់ចេញពីគម្ពីរ ទសជាតក គឺជាប្រវត្តិរបស់ព្រះសក្យមុនីគោតមបរមសម្ពុទ្ធក្នុង១០ជាតិ ហើយចែងក្នុងរឿងទាំង១០។ រឿងទាំងនេះផ្តល់នូវដំបូន្មាន និងភាសិតសំខាន់ៗប្រកបដោយឧត្តមគតិ។ នៅក្នុងឆ្នាំ១៩៥៨ គណៈកម្មការរៀបចំកម្មវិធីសិក្សានៃក្រសួងអប់រំជាតិ បានបញ្ចូលរឿងសង្ខេបទសជាតក ក្នុងកម្មវិធីសិក្សា ៖*

| | | |
|---|---|---|
| (១) | ***តេមិយជាតក*** | *និយាយពីការបំពេញនេក្ខម្មបារមី គឺការចេញបួសរបស់ពោធិសត្វ* |
| (២) | ***មហាជនកជាតក*** | *និយាយពីការបំពេញវិរិយបារមី គឺសេចក្តីព្យាយាមដ៏មុតមាំ* |
| (៣) | ***សុវណ្ណសាមជាតក*** | *និយាយពីការបំពេញមេត្តាបារមី គឺការកាន់ចិត្ត មេត្តា ករុណាចំពោះមនុស្សសត្វ* |
| (៤) | ***នេមិរាជជាតក*** | *និយាយពីការបំពេញបញ្ញាបារមី គឺការ* |



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

តាំងចិត្តមាំក្នុងសីល

(៥) **មហោសថជាតក** និយាយពីការបំពេញបញ្ញាបារមីគឺអ្នកមានបញ្ញាដ៏លើសលប់

(៦) **ភូរិទត្តជាតក** និយាយពីការបំពេញសីលបារមី

(៧) **ចន្ទកុមារជាតក** និយាយពីការបំពេញខន្តីបារមី គឺការកាន់ចិត្តអត់ធ្មត់

(៨) **នារទជាតក** និយាយពីការបំពេញឧបេក្ខាបារមី គឺការកាន់ចិត្តជាកណ្ដាល

(៩) **វិធុរជាតក** និយាយពីការបំពេញសច្ចបារមី គឺការកាន់ពាក្យទៀងត្រង់

(១០) **មហាវេស្សន្តរជាតក** និយាយពីការបំពេញទានបារមី គឺការចំណាយធនធានឱ្យទៅជាទានអ្នកដទៃ។

***មូលហេតុអ្វីបានជាគេចាត់ទុករឿងទាំងនេះថា ជាចលនាអក្សរសិល្ប៍ពុទ្ធនិយមពិត?***

អក្សរសិល្ប៍ពុទ្ធនិមយពិត គឺដោយសារជារឿងរបស់ព្រះពោធិសត្វនិងការកសាងបារមីដើម្បីត្រាស់ជាព្រះពុទ្ធ។ តួអង្គឯកប្រុសជាព្រះពោធិសត្វ ចំណែកតួអង្គឯកស្រីជាកន្សែរសពេជ្ជ។

អក្សរសិល្ប៍ពុទ្ធនិយមពិត គឺជាអក្សរសិល្ប៍ដែលមានលក្ខណៈទេវនិយម មានអន្តរាគមន៍ពីព្រះឥន្ទ្រ តែមិនឆ្ងុះបញ្ចាំងពីតថភាពក្នុងសង្គមឡើយ។ ឧទាហរណ៍ រឿងមហាវេស្សន្តរជាតក គឺជារឿងដែលបានបង្ហាញពីព្រឹត្តិការណ៍សំខាន់ តាមរយៈការបំពេញទានបរិច្ចាគទាំងប្រាំយ៉ាងរបស់តួអង្គព្រះពោធិសត្វព្រះនាមព្រះវេស្សន្តរ ដែលមានធនបរិច្ចាគ គឺលះបង់ទ្រព្យសម្បត្តិជាទាន អង្គបរិច្ចាគ គឺលះបង់សរីរាង្គណាមួយជាទាន ជីវិតបរិច្ចាគ គឺលះបង់អាយុជីវិតជាទាន បុត្តបរិច្ចាគ គឺលះបង់កូនជាទាន និងភរិយាបរិច្ចាគ គឺលះបង់ប្រពន្ធជាទាន។ សំណួរដែលយើងសួរថា តើរឿង



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

នេះមានពិតមែនក្នុងសង្គមទេ។ ទាល់តែព្រះទើបមានចិត្តដូច្នេះ។ អ្នកនិពន្ធដោះស្រាយបញ្ហា ដោយប្រើវិធីអហិង្សា ហើយបញ្ចប់រឿង ដោយការសរជាតិ។

ទីពីរ គឺអក្សរសិល្ប៍ពុទ្ធនិយមក្លាយ ដែលអ្នកនិពន្ធបានដកស្រង់ចេញពីគម្ពីរ បញ្ញាសជាតក ដែលមានរឿងនិទានចំនួន៥០រឿង ដូចជារឿងក្រុងសុភមិត្រ រឿងព្រះសុធន រឿងភោគកុលកុមារ រឿងសព្វសិទ្ធិ រឿងមរណមាតា រឿងចៅស្រទបចេកជាដើម[១០]។ ហេតុអ្វីបានជាហៅថាពុទ្ធនិយមក្លាយ? គឺដោយសារតែអក្សរសិល្ប៍នេះមើលទៅដូចពិតដែរ ដោយសារតែរឿងរ៉ាវទាំងឡាយមានមូលដ្ឋានពីទស្សនវិជ្ជាពុទ្ធសាសនា។ ក៏ប៉ុន្តែ ពុទ្ធនិយមក្លាយ គឺមកពីមិនពិត ពោលគឺជាអត្ថបទដែលទាក់ទងនឹងទស្សនៈក្នុងព្រះពុទ្ធសាសនាតិចតួចតែប៉ុណ្ណោះ ហើយមិនមែនជារឿងក្នុងគម្ពីរព្រះត្រៃបិដកឡើយ។ ការតែងនិពន្ធអត្ថបទអក្សរសិល្ប៍ខ្មែរ និងច្បាប់ជាពាក្យកាព្យបានឈានដល់ចំណុចកំពូលក្នុងស.វ.ទី១៨-១៩។

ក្នុងការតែងនិពន្ធ កវីនិពន្ធប្រើប្រាស់នូវសិល្ប៍វិធីជាច្រើន ដូចជាវចនវិធី(ការប្រើពាក្យ) រចនាវិធី(ការប្រើឃ្លាល្បះទាក់ទាញ) ឧបមានវិធី(ប្រៀបធៀបតួអង្គទៅនឹងអ្វីមួយ) សំវាទវិធី(តួអង្គឆ្លើយឆ្លងគ្នា) សន្ទេហវិធី(ធ្វើឱ្យចង់តាមដាន) ឯកវាទវិធី(និយាយតែម្នាក់ឯង) វណ្ណនាវិធី(លើកតួអង្គ ធម្មជាតិមកពណ៌នាដូចឃើញនឹងភ្នែកស្រស់) បដិវិធី(តួអង្គខុសគ្នា)ជាដើម។

## ២.២ អ្នកនិពន្ធពីស.វ.ទី១៧ដល់១៩

ខ្ញុំសូមសម្រាំងជ្រើសរើសតែអ្នកនិពន្ធខ្មែរល្បីៗសម័យកណ្តាលតែមួយចំនួនប៉ុណ្ណោះ ៖

[១០] ម៉ុញ សារី (២០១១) វចនាធិប្បាយអក្សរសិល្ប៍ខ្មែរ(Encyclopedia of Khmer Literature) មជ្ឈមណ្ឌលស្រាវជ្រាវអាស៊ីនៃរាជបណ្ឌិត្យសភាកម្ពុជា ទំព័រ ២៦៨។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

**ស.វ.ទី១៧ ៖**

(១) អ្នក ប៉ាង តាត[១១] គឺជាអ្នកនិពន្ធ ដែលសរសេរកំណាព្យ «ល្បើកអង្គរ» ជាបទព្រហ្មគីតិ បទកាកគតិ និងបទពំនោល ដែលអ្នកគ្រូ ពៅ សាវរស បានបកស្រាយតាមវិទ្យាសាស្ត្រនៃភាសាវិទ្យាថា សរសេរនៅឆ្នាំ១៦២០[១២]។ កំណាព្យនេះ ដែលសរសេរឡើងនៅពេលដែលប្រជាជនកម្ពុជាមានជំនឿលើព្រះពុទ្ធសាសនាថេរវាទ បានឆ្លុះបញ្ចាំងពីលទ្ធិសុខដុមនីយកម្មរវាងសាសនាព្រាហ្មណ៍ និងសាសនាព្រះពុទ្ធ[១៣]។

(២) ព្រះរាជសម្ភារ ដែលជារាជកវី ក្នុងស.វ.ទី១៧ (គ.ស.១៦០១-១៦៣១)។ ព្រះអង្គជាព្រះរាជបុត្រច្បងរបស់ព្រះបាទជ័យជេដ្ឋា និងអ្នកម្នាងសុន ដែលមានព្រះនាមថា ព្រះអង្គតូ ក្រោយមកជាព្រះស្រីធម្មរាជា។ ដោយមានវិបត្តិស្នេហាជាមួយព្រះនាងអង្គវតី ដែលជាមហេសីរបស់ស្ដេចមា ព្រះបាទឧទ័យ ព្រះអង្គបានភៀសព្រះកាយទៅខេត្តក្រចេះ ហើយត្រូវបានទ័ពព័ទ្ធយហ្គាល់បាញ់សុគត។ ស្នាព្រះហស្តរបស់ព្រះអង្គមាន ច្បាប់រាជនីតិ កំណាព្យ«ច្បាប់រាជសម្ភារ» (ឆ្នាំ១៦២២) លិខិតផ្ញើទៅថ្វាយព្រះម៉ែយួរវត្តី ពាក្យកាព្យសរសេរលើចុងត្នោត មុនពេលសុគតដោយទាហានព័ទ្ធយហ្គាល់បាញ់ កំណាព្យសរសើរហេមន្តមាស កំណាព្យ«កន្ទងមាសមង្គលថ្ងៃ» កំណាព្យ«ព្រលឹងមាសអើយ» ច្បាប់ក្រម និងច្បាប់ហៃសាធុជន ឬច្បាប់ត្រីនេត្រ[១៤]។

---

[១១] ម៉ុញ សារី (២០១១) វចនាធិប្បាយអក្សរសិល្ប៍ខ្មែរ(Encyclopedia of Khmer Literature) មជ្ឈមណ្ឌលស្រាវជ្រាវអាស៊ីនៃរាជបណ្ឌិត្យសភាកម្ពុជា ទំព័រ ១៦៦។

[១២] ល្បើកអង្គរវត្ត អារម្ភកថាដោយ ឃីង ហុកឌី (២០០៦) Editions Angkor ទំព័រ xi។

[១៣] Edwards, P. (2007), Cambodge: *The Cultivation of a Nation, 1860-1945,* University of Hawaii Press, Honolulu, p. 23.

[១៤] លាង ហាប់អាន (១៩៦៧) «ប្រវត្តិអក្សរសាស្ត្រខ្មែរ៖ សម័យនគរភ្នំដល់សម័យឧដុង្គ (ស.វ.ទី១ដល់១៨៥៩)» ទំព័រ ២១៩-២៣០។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

**ស.វ.ទី ១៨ ៖**

(៣) បណ្ឌិត ជ័យនន្ទ ជាកវី និងមន្ត្រីមួយរូប ដែលនិពន្ធកំណាព្យ (សិលាចារឹកទំនើបអង្គរវត្ត K-34, K-38 ចំនួនប្រមាណ៤០ផ្ទាំង) នៅឆ្នាំ ១៧០១ ចុងរាជ្យព្រះរាជសម្ភារ។ លោកបានតែងសិលាចារឹកមួយ ដែលប្រកបដោយសម្ផស្សជើងកាព្យ ដែលអាចយកជាគំរូមេកាព្យបាន និងដែលអធិប្បាយជីវប្រវត្តិ និងសកម្មភាពរបស់ឧត្តមមន្ត្រីនៃព្រះមហាក្សត្រព្រះបាទជ័យជេដ្ឋាទី៣[១៥]។

(៤) ឧកញ៉ាកោសាធិបតី កៅ ជាកវីឯកក្នុងរជ្ជកាលព្រះបាទអង្គចន្ទទី២។ លោកត្រូវបានតែងតាំងជាចៅហ្វាយឃ្លាំងមណីរតន៍ក្នុងព្រះបរមរាជវាំង និងជាទីប្រឹក្សាច្បាប់របស់ព្រះមហាក្សត្រ។ លោកបានសរសេររឿង «ក្រុងសុកមិត្រ» នៅឆ្នាំ១៧៩៨។

(៥) ឧកញ៉ាព្រះឃ្លាំង នង ជាប្អូនបង្កើតរបស់ព្រះមាតានៃព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម។ លោកបានបួសរៀន និងបានធ្វើជាចៅអធិការនៅវត្តចតុទិសនៃក្រុងឧដុង្គដោយបានទទួលសមណសក្តិជាមហាព្រហ្មមុនី។ ឧកញ៉ាព្រះឃ្លាំង នង ជាកវីឯកនៅក្នុងរាជ្យព្រះបាទអង្គអេង និងព្រះបាទអង្គចន្ទ។ លោកបានសរសេរស្នាដៃខាងអក្សរសាស្ត្រជាច្រើនរហូតដល់បានឡើងងារជាឧកញ៉ាព្រះឃ្លាំង ជាងារចាងហ្វាងក្រុមព្រះរាជបណ្ឌិត និងជាព្រះរាជនិពន្ធរបស់ព្រះរាជាទៀតផង។ ស្នាដៃរបស់លោកមាន ៖ ច្បាប់សុភាសិត(១៧៩០) លោកនយបករណ៍(១៧៩៤) បុញ្ញសារសិរសា (១៧៩៧) រឿង«ភោគកុលកុមារ»(១៨០៤) វរនុជវរនេត្រ(១៨០៦) ព្រះសមុទ្រ(១៨០៨) និងពង្សាវតារ(១៨១៨)។

នៅមានកវីបណ្ឌិតជាច្រើនទៀត ដែលបាននិពន្ធស្នាដៃនៅក្នុងស.វ.

---

[១៥] V. Pou, Saveros, « Inscriptions Modernes d'Angkor Vat », (IMA34-38), *BEFEO.*, t. LXII, Paris 1975:293...



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ទី១៨-១៩ តែមិនបានដាក់ឈ្មោះនៅលើស្នាដៃអក្សរសិល្ប៍របស់ខ្លួន ដូចជារឿងពុទ្ធិសែន ព្រះសុធន ទិព្វសង្វារ ហង្សយន្ត រាជកុល រតនាវង្ស សង្ខសិល្ប៍ជ័យ ជាដើម។

**ស.វ.ទី ១៩ ៖**

ក្នុងអំឡុងស.វ.ទី១៩ នៅពេលដែលមានជម្លោះរវាងពួកសៀម និងពួកវៀតណាម ក្នុងការកាន់កាប់ត្រួតត្រាកម្ពុជា វប្បធម៌ខ្មែរគឺសឹងផុតរលត់ក៏ព្រោះថាវត្តអារាមត្រូវបានកម្ទេច និងបំផ្លាញចោល[១៦]។ ប្រព័ន្ធអប់រំនៃប្រទេសខ្មែរនៅដើមស.វ.ទី១៩ ត្រូវបានបំផ្លាញដល់ឫសគល់។ កម្ពុជានៅពេលនោះខ្វះអ្នកប្រាជ្ញ និងឧត្តមមន្ត្រីដែលមានប្រាជ្ញា ថាមពល និងសមត្ថភាពដែលអាចជួយសង្គ្រោះប្រទេសជាតិឱ្យរួចចាកផុតពីគ្រោះមហន្តរាយបាន[១៧]។ តាមការពិត ប្រព័ន្ធអប់រំនៅកម្ពុជាមុនស.វ.ទី២០ ជាប្រព័ន្ធមួយ ដែលឈរលើមូលដ្ឋាននៃរចនាសម្ពន្ធសង្គម ដែលមិនមែនស្ថាប័នទេ តែគឺបុគ្គលជាអ្នកដើរតួនាទីឈានមុខនៅក្នុងរដ្ឋបាល។ ក្នុងប្រព័ន្ធអប់រំបែបប្រពៃណីនេះ ព្រះសង្ឃរាជ បព្វជិតព្រាហ្មណ៍ អ្នកប្រាជ្ញ កវីនិពន្ធ គឺជាសសរស្តម្ភនៃប្រព័ន្ធអប់រំតាមបែបប្រពៃណី[១៨]។ នៅពេលខ្វះ ចតុស្តម្ភនៃរដ្ឋបាលសាធារណៈ គឺឧកញ៉ាយមរាជ ឧកញ៉ាវាំង ឧកញ៉ាក្រឡាហោម និងឧកញ៉ាចក្រី ក៏អាចជាអ្នកប្រាជ្ញបានដែរ។ ជានិច្ចកាល ព្រះមហាក្សត្រតែងតែជ្រើសរើសមន្ត្រី និងឧត្តមមន្ត្រី ក្នុងចំណោមអ្នកចេះដឹង និងកវីនិពន្ធ។ ឧត្តមមន្ត្រីគឺជាប្រភព និងជាសសរស្តម្ភនៃអំណាច និងភាពស្មោះត្រង់ ហើយ

---

១៦ រឿង បណ្តាំតាមាស (១៩០៨) ទំព័រ ៤០ បោះពុម្ពឡើងវិញដោយបណ្ណាគារអង្គរ។

១៧ ឃីង ហុក ឌី (២០០៣) «មាលីបទ អក្សរសិល្ប៍ខ្មែរស.វ.ទី១៩» ទំព័រ៧។

១៨ Mak Phoeun (1980), « L'Introduction de la Chronique Royale du Cambodge du lettré Nong », *BEFEO*, 67 (1980) : 144 ; Edwards, P. (2007), Cambodge: *The Cultivation of a Nation*, 1860-1945, University of Hawaii Press, Honolulu, p. 70.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កិច្ចដំណើរការរបស់រដ្ឋត្រូវប្រព្រឹត្តទៅតាមរយៈទំនាក់ទំនងជាបុគ្គល[១៩]។ នៅពេលដែលធនធានមនុស្សទាំងនោះបាត់បង់ទៅ ប្រព័ន្ធអប់រំក៏ដួលរលំដែរ។ ព្រះបាទ អង្គឌួង បានខិតខំប្រឹងប្រែងក្នុងការស្ដារ និងកសាងប្រព័ន្ធអប់រំខ្មែរឡើងវិញ នៅក្នុងរជ្ជកាលរបស់ទ្រង់ ដោយស្ដារឡើងវិញនូវព្រះពុទ្ធសាសនា និងសាលាវត្ត។

នៅដើមស.វ.ទី១៩ វិស័យអប់រំនៅកម្ពុជាស្ទើរតែធ្លាក់ដល់ចំណុចសូន្យ ដោយសារតែសង្គ្រាមជាមួយសៀម និងវៀតណាម ព្រមទាំងការបះបោរនៅក្នុងស្រុកជាច្រើនទសវត្សរ៍។ នាម៉ឺនខ្មែរធំៗ ព្រមព្រៀងគ្នាទៅយាងព្រះបាទអង្គឌួងពីប្រទេសសៀម ឱ្យស្ដេចយាងមកគ្រងរាជ្យស្រោចស្រង់ប្រទេសជាតិ។ ព្រះចៅសៀមទ្រង់យល់ព្រម និងបានចាត់ពញាបឌិន ដែលជាមេទ័ពឱ្យដង្ហែទ្រង់ត្រឡប់មកវិញនៅឆ្នាំ១៨៤១។ ប្រទេសសៀម និងវៀតណាមបានចុះសន្ធិសញ្ញានៅខែធ្នូ ឆ្នាំ១៨៤៥ ដើម្បីប្រគល់រាជបល្ល័ង្កខ្មែរមកព្រះអង្គឌួងវិញ។ ព្រះបាទសម្ដេចព្រះហរិរក្សរាមា អង្គឌួង[២០] បានឡើងគ្រងរាជសម្បត្តិនៅឆ្នាំ១៨៤៨ ដោយមានវត្តមានរបស់តំណាងមហាក្សត្រមកពីប្រទេសសៀម និងវៀតណាម។ ចាប់តាំងពីពេលនោះមក ប្រទេសខ្មែរបានស្គាល់នូវសុខសន្តិភាពបរិបូណ៌ ជាហេតុឱ្យព្រះអង្គអាចដាក់ចេញនូវកំណែទម្រង់រដ្ឋ និងបានកសាងឡើងវិញនូវប្រព័ន្ធអប់រំ។

ការកសាងប្រទេសនៅក្នុងស.វ.ទី១៩ បានចាប់ផ្ដើមដំបូង ដោយលើកតម្កើងជាថ្មីនូវព្រះពុទ្ធសាសនា។ នេះក៏ព្រោះថាព្រះបាទ អង្គឌួង បានចាត់ទុកវិស័យព្រះពុទ្ធសាសនាជាផ្នែកមួយដ៏សំខាន់ក្នុងការធ្វើឱ្យមាន

---

១៩ Mabbet and Chandler, *The Khmer*, p. 161; Edwards, P. (2007), *Cambodge: The Cultivation of a Nation, 1860-1945,* University of Hawaii Press, Honolulu, p. 71.

២០ ព្រះបាទ អង្គឌួង បានរៀនសូត្រចេះដឹងនៅទីក្រុងបាងកក និងទំនុកបម្រុងដោយរាជវង្សថៃ (See Hansen, A. R. (2008) *How to Behave: Buddhism and Modernity in Colonial Cambodia, 1860-1930*. Silkworm Books. Chiang Mai. p. 49).



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

សន្តិភាព និងការរស់ឡើងវិញនៃកម្ពុជា[២១]។ ព្រះអង្គមានព្រះរាជបញ្ជាឱ្យប្រមូលនូវពុទ្ធវចនៈទាំងឡាយ មានគម្ពីរព្រះត្រៃបិដកជាដើម។ ការលើកតម្កើងជាថ្មីនៃវិស័យព្រះពុទ្ធសាសនានៅកម្ពុជា ក៏បានជួយក្នុងការបង្កើតលក្ខខណ្ឌចាំបាច់ ក្នុងការកសាងឡើងវិញនូវវិស័យអប់រំ។ ព្រះសង្ឃខ្មែរពីរអង្គ គឺសម្តេចព្រះមហាព្រហ្មមុនី និល ទៀង[២២] (១៨២៣-១៩១៣) ដែលជាសម្តេចព្រះសង្ឃរាជ សង្ឃនាយកគណៈមហានិកាយ និងសម្តេចព្រះវិមលធម្ម ប៉ាន[២៣] បញ្ញាសីលោ(១៨២៤-១៨៩៤) ដែលជាសម្តេចព្រះសុគន្ធាធិបតីសង្ឃនាយកគណៈធម្មយុត្តិ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្រេចបាននូវមហិច្ឆតារបស់ព្រះបាទ អង្គឌួង ក្នុងការកសាងព្រះពុទ្ធសាសនាឡើងវិញ។ សម្តេចសង្ឃទាំងពីរព្រះអង្គបានទទួលនូវការគោរពជាខ្លាំង ហើយទ្រង់ក៏មានការអប់រំបែបពុទ្ធ ចក្របានយ៉ាងជ្រៅជ្រះ។ ព្រះបាទអង្គឌួង ទ្រង់និមន្តសម្តេចទាំងពីរព្រះអង្គឱ្យបង្រៀនព្រះត្រៃបិដកដល់សិស្សានុសិស្ស។ ព្រះតេជគុណ និល ទៀង បានរៀបចំឡើងវិញផ្នែករដ្ឋបាលសង្ឃ[២៤]។ ព្រះបាទ អង្គឌួង កាលនោះ ក៏បានជួសជុល និងកសាងព្រះ

២១ Hansen. Ibid. p. 50; See also Leclère (1914), Adhémard. *Histoire du Cambodge*. Paris: Librairie Paul Geuthner. pp. 434-440; Chandler, David (1996). *Facing the Cambodian Past.* Chiang Mai: Silkworm Books. pp. 104-105, 108).1.

២២ ព្រះភិក្ខុ និល ទៀង បួសជាសាមណេរនៅក្នុងឆ្នាំ១៨៣៤ ក្នុងវ័យ ១១ វស្សា បន្ទាប់មកត្រូវបានព្រះចៅណាំក្លាវនៃក្រុងសៀម រាជានុញ្ញាតឱ្យបំពេញឧបសម្បទាជាភិក្ខុក្នុងវ័យ២២វស្សា នៅវត្តព្រះកែវមរកតនៅទីក្រុងបាងកក។ ព្រះអង្គជាអ្នកប្រាជ្ញមានចំណេះវិជ្ជាខ្ពង់ខ្ពស់ ចេះភាសាបាលី សំស្ក្រឹត និងសៀមយ៉ាងច្បាស់លាស់។ នៅឆ្នាំ១៨៤៩ ព្រះអង្គបានត្រឡប់ពីប្រទេសសៀមមករស់នៅក្រុងឧដុង្គវិញ តាមការនិមន្តរបស់ព្រះបាទ អង្គឌួង។ ព្រះអង្គត្រូវបានតែងតាំងជាសម្តេចព្រះមហាសង្ឃរាជគណៈមហានិកាយក្នុងវ័យ ៣៥ ព្រះវស្សា ( លី សុវីរ ដំណើរប្រវត្តិ ( ២០០៨) «ស្តីពីសាលាបាលីជាន់ខ្ពស់ ព្រះរាជបណ្ណាល័យ និងក្រុមជំនុំ៣» ទំព័រ ៨ និង លាង ហាប់អាន ( ១៩៦៥) «អ្នកនិពន្ធខ្មែរ» ទំព័រ ៣៧)។

២៣ ព្រះភិក្ខុ ប៉ាន ត្រឡប់ពីប្រទេសសៀម ទៅកាន់ក្រុងឧដុង្គវិញនៅឆ្នាំ១៨៥៤។ ព្រះអង្គត្រូវបានតែងតាំងជាសម្តេចព្រះសុគន្ធាធិបតី គណៈធម្មយុត្តិកនិកាយ ក្រោយការចូលទិវង្គតរបស់សម្តេចព្រះសុគន្ធាធិបតី ( លី សុវីរ ( ២០០៨) «ដំណើរប្រវត្តិស្តីពីសាលាបាលីជាន់ខ្ពស់ ព្រះរាជបណ្ណាល័យ និង ក្រុមជំនុំ៣» ទំព័រ៨ និងលាង ហាប់អាន ( ១៩៦៥) «អ្នកនិពន្ធខ្មែរ» ទំព័រ៣៧។

២៤ Hansen. (2008) Ibid. p. 86.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

វិហារនានា។ ព្រះបាទ អង្គឌួង បាននាំគណៈធម្មយុត្តិកនិកាយពីសៀមមកដែរ ដោយបានសាងសង់វត្តធម្មយុត្តិកនិកាយនៅឧដុង្គ គឺវត្តសាលាគូ ឬវត្តអំពិលបី ហើយនៅពេលដែលព្រះបាទ នរោត្តម ចាកចោល ក្រុងឧដុង្គមានជ័យមកភ្នំពេញ សម្តេចព្រះមហាសុគន្ធាធិបតី ប៉ាន ដែលជាសម្តេចព្រះសង្ឃរាជគណៈធម្មយុត្តិកនិកាយ ក៏បាននិមន្តពីវត្តអំពិលបី មកគង់នៅវត្តវត្តបុទុមវតីរាជវរារាម[២៥]។

ក្នុងរជ្ជកាលព្រះបាទ អង្គឌួង ព្រះពុទ្ធសាសនាថេរវាទ ឬហីនយាន សិល្បៈខ្មែរ អក្សរសាស្ត្រ និងវប្បធម៌បានរស់រានមានជីវិតឡើងវិញ។

## III. អត្ថន័យនៃអក្សរសិល្ប៍ពុទ្ធនិយមខ្មែរ

ន័យសេចក្តីដ៏សំខាន់បំផុតនៃអក្សរសិល្ប៍បែបពុទ្ធនិយម គឺបង្ហាញពីជំនឿ និងជីវិតរបស់ព្រះពោធិសត្វ។ ក្នុងអក្សរសិល្ប៍ពុទ្ធនិយមក្លាយ រឿង និងទំនាស់ផ្ទុះបញ្ចាំងពីរឿងព្រេងនិទានក្នុងគម្ពីរបញ្ញាសជាតក ដែលមានលក្ខណៈមនុស្ស លក្ខណៈសង្គម និងលក្ខណៈប្រជាជន ជាងអក្សរសិល្ប៍ពុទ្ធនិយមពិត ដែលមានលក្ខណៈទេវៈយ៉ាងខ្លាំងក្លា។ ក្នុងការដោះស្រាយបញ្ហាទៀតសោត អក្សរសិល្ប៍ពុទ្ធនិយមក្លាយ តួអង្គពឹងផ្អែកលើសមត្ថភាពផ្ទាល់ខ្លួន តែនៅក្នុងអក្សរសិល្ប៍ពុទ្ធនិយមពិត គេតែងឃើញមានអន្តរាគមន៍របស់ព្រះឥន្ទ។ ឧត្តមគតិនៃអក្សរសិល្ប៍ពុទ្ធនិយមខ្មែរផ្តោតលើការអប់រំឱ្យស្គាល់បុណ្យនិងបាប កម្មនិងផល អំពើល្អនិងអំពើអាក្រក់ ឱ្យខំប្រឹងតស៊ូ និងជឿជាក់លើខ្លួនឯង ដោយផ្ទុះបញ្ចាំងទស្សនៈក្នុងព្រះពុទ្ធសាសនា។

ទស្សនវិជ្ជាពុទ្ធសាសនាមានគោលដៅស្វែងយល់រកហេតុផលនៃសេចក្តីសុខ និងសេចក្តីទុក្ខ។ អរិយសច្ចៈបួនយ៉ាងគឺ ទុក្ខ ហេតុនៃទុក្ខ ការរលត់ទុក្ខ ផ្លូវនៃការរលត់ទុក្ខ( ទុក្ខសច្ចៈ សមុទយសច្ចៈ និរោធសច្ចៈ

[២៥] ស៊ិន សុវណ្ណនិ ( ២០១២) «ឯកសារស្រាវជ្រាវក្រុមជំនុំប្រែគម្ពីរ ព្រះត្រៃបិដកនៃប្រទេសកម្ពុជា» គ្រឹះស្ថានបោះពុម្ពផ្សាយ អង្គរ ទំព័រ ៦៥។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មគ្គសច្ចៈ)។

ទស្សនវិជ្ជាពុទ្ធនិយមក្នុងអក្សរសិល្ប៍ពុទ្ធនិយមខ្មែរផ្ដោតលើចំណុចសំខាន់ៗដូចតទៅ ៖

**១ ទ្រឹស្ដីពុទ្ធនិយម** គឺជាទ្រឹស្ដីសន្តិភាព មិនបៀតបៀនគ្នា មិនយីយាគ្នា មនុស្សជឿលើបុណ្យ និងបាប។

អ្នកនិពន្ធខ្មែរសម័យក្រោយអង្គរ ដែលយើងនិយមហៅថាអក្សរសិល្ប៍សម័យកណ្ដាលបានបង្កើតស្នាដៃជាអក្សរសិល្ប៍ពុទ្ធនិយម ដោយសារអ្នកនិពន្ធជ្រើសរើសយករឿងក្នុងជាតកបែបបាលិ(មានបញ្ញាសជាតក ឬជាតកក្នុងអដ្ឋកថានៃព្រះត្រៃបិដក) មកច្នៃតែងតាមចិត្តរបស់ខ្លួន ដើម្បីសម្រេចទៅតាមទស្សនសម័យនោះ គឺបញ្ហាល្អ អាក្រក់ បុណ្យ បាប ក្នុងកម្មផល និងអត្ថន័យនៃរឿងរ៉ាវជាច្រើននៅសម័យឧដុង្គ[២៦]។ ប្រជាពលរដ្ឋខ្មែរយកវត្តអារាមជាទីសក្ការៈផង ជាកន្លែងដែលជួបជុំគ្នាផង និងជាកន្លែងបណ្ដុះបណ្ដាលធនធានមនុស្សផង។ នៅពេលជួបការលំបាក ប្រជាជនខ្មែរតែងតែនាំគ្នាបន់ស្រន់សុំសេចក្ដីសុខ សុំឱ្យគុណបុណ្យព្រះរតនត្រ័យជួយគេឱ្យរួចចាកពីទុក្ខផងទាំងពួង។ ការលំបាកដែលកើតឡើង គឺជាកម្មផល នៅពេលអស់កម្ម យើងនឹងលែងលំបាកទៀតហើយ។ ដូច្នេះ ការលំបាកនេះគឺមានតែមួយរយៈទេ។ ត្រូវតស៊ូឡើងដើម្បីឆ្លងឱ្យផុតវាលបី។

**ក្នុងរឿងក្រុងសុភមិត្រ** ៖ «ស្ដេចលោមព្រះប្អូន ហឫទ័យសោះសូន្យ ថាឱប្អូនអើយ វេរាពៀរព្រេង កម្មឯងដល់ហើយ ព្រលឹងអូនអើយ កុំសោយសោកា។»

**ក្នុងរឿងសព្វសិទ្ធិ** ៖ «ហេតុបុណ្យបារមីពង្សពោធិបានសាងអំពីអតីតដល់ថ្ងៃនេះឯងជាអស្ចារ្យ សារិកាក្សិណក្ស័យ ប្រល័យជន្ម។»

នៅពេលដែលប្រជាជនត្រូវរត់លូនឆ្លងកាត់សង្គ្រាមយ៉ាងលំបាក

[២៦] លាង ហាប់អាន (១៩៦៧) «សិក្សាប្រវត្តិអក្សរសាស្ត្រខ្មែរ ៖ សម័យនគរភ្នំដល់សម័យឧដុង្គ (ស.វ.ទី១ ដល់ ១៨៥៩)»ទំព័រ ២១២-២១៣។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

វេទនា ព្រះពុទ្ធសាសនា និងអក្សរសិល្ប៍ពុទ្ធនិយមបានផ្ដល់ឱ្យប្រជាជនខ្មែរនូវសេចក្ដីសង្ឃឹមថា ដោយសារតែអំពើល្អរបស់ពួកគេ នោះថ្ងៃណាមួយគេនឹងមានសេចក្ដីសុខសប្បាយជាមិនខាន ដូចពាក្យស្លោកមួយបានពោលថា «ពូជព្រះជិនវង្សមិនស្លាប់ទេ គ្រាន់តែលំបាកមួយគ្រាតែប៉ុណ្ណោះ»។ ប្រការនេះ គឺជាមូលហេតុសំខាន់នៃការរីកពលដាលនៃអក្សរសិល្ប៍ពុទ្ធនិយមនៅក្នុងសម័យឧដុង្គ ដែលជាសម័យមួយដែលខ្មែរត្រូវឆ្លងកាត់នូវសង្គ្រាមក្នុងស្រុកយ៉ាងរ៉ាំរ៉ៃ។

**២ តួអង្គក្នុងរឿងសុទ្ធសឹងតែជាមនុស្សពិតប្រាកដ មាននៅក្នុងសង្គមមនុស្ស។ ព្រះពុទ្ធជាមនុស្សពិតប្រាកដ ៖** ពុទ្ធសាសនាជាបដិបទាផ្លូវប្រតិបត្តិជាកម្មនិយម ឬជាវិធីបំបាត់អវិជ្ជា តណ្ហា ឧបាទានកម្ម។ មនុស្សគ្រប់រូបអាចប្រើសក្ដានុភាពខ្លួន ជាមនុស្សឱ្យបានសម្រេចភាពជាព្រះពុទ្ធបាន បើមានបំណងមាំ និងមានវិរិយភាពធំ។ មនុស្សជាម្ចាស់ខ្លួនឯង ឥតមានអំណាចអ្វីមួយប្រសើរជាងវាសនាខ្លួនជាមនុស្សនេះទេ។

**៣ ខន្តីធម៌ និង មេត្តាប្រោសប្រណី ៖** ព្រះសម្ពុទ្ធទ្រង់មានព្រះហឫទ័យទូលាយ និងប្រកបដោយខន្តីធម៌ មេត្តាប្រោសប្រណី សន្ដោសសាវក និងប្រទានការយោគយល់ទៅវិញទៅមកទៀតផង។ ទ្រង់ត្រាស់ទូន្មានឱ្យពិចារណាហ្មត់ចត់ ទើបសម្រេចចិត្ត ជាការប្រសើរបំផុត។ អ្នកគ្រប់គ្នាមិនត្រូវលើកតម្កើងសរសើរតែលទ្ធិសាសនារបស់ខ្លួន ហើយប្រទូស្តលទ្ធិសាសនាដទៃទេ។

**៤ សច្ចធម៌ ៖** អ្នកស្វែងរកសច្ចធម៌មិនមានប្រយោជន៍អ្វីនឹងដឹងថាសច្ចធម៌នេះកើតមកពីណាទេ។ កិច្ចការជាសារវន្ត គឺការរកឃើញធម៌ពិតហើយបានលុះធម៌នោះដោយប្រពៃ។ ជំនឿក្នុងព្រះពុទ្ធសាសនា ជាជំនឿប្រកបដោយហេតុផល (Cause et effet) ជាជំនឿប្រកបដោយវិចារណញ្ញាណ (Raisonnement) ពោលគឺសទ្ធា ដែលជាជំនឿប្រកបដោយបញ្ញា (Confiance=confidence et sagesse)។ ជំនឿពុទ្ធសាសនាសំដៅយក ការ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ឃើញច្បាស់ ការដឹងច្បាស់ និងការយល់ច្បាស់។

**៥ អរិយសច្ចធម៌** ៖ អរិយសច្ចធម៌ បួនប្រការនោះគឺ ៖

ទីមួយ ទុក្ខជាសេចក្តីពិត មានជីវិត គឺមានទុក្ខ

ទីពីរ ហេតុដែលនាំឱ្យកើតទុក្ខ ព្រោះអវិជ្ជានិងតណ្ហា

ទីបី ការរលត់ទុក្ខជាសេចក្តីពិត ដោយបំបាត់អវិជ្ជា និងតណ្ហាដែលជាប្រភពដើមនៃទុក្ខ

ទីបួន មាគ៌ាដែលនាំទៅកាន់រលត់ទុក្ខជាសេចក្តីពិត។ មាគ៌ាដែលនាំទៅកាន់រលត់ទុក្ខ គឺជាមជ្ឈិមា បដិបទា «ផ្លូវកណ្តាល» ដែលប្រកបដោយអង្គ៨ប្រការដ៏ប្រសើរគឺ ៖ (១)សម្មាទិដ្ឋិ(ការយល់ត្រូវ) (២)សម្មាសង្កប្ប(ការត្រិះរិះត្រូវ) (៣)សម្មាវាចា(វាចាត្រូវ) (៤)សម្មាកម្មន្ត(ការងារត្រូវ) (៥)សម្មាអាជីវ(ការចិញ្ចឹមជីវិតត្រូវ) (៦)សម្មាវាយាម(ការព្យាយាមត្រូវ) (៧)សម្មាសតិ(ការរលឹកត្រូវ) (៨)សម្មាសមាធិ(ការតម្កល់ចិត្តត្រូវ)។

## IV. អត្ថរសនៃអក្សរសិល្ប៍ពុទ្ធនិយមខ្មែរ

តម្លៃនៃស្នាដៃអក្សរសិល្ប៍ពុទ្ធនិយមស្តែងចេញនូវទស្សនៈរបស់ព្រះពុទ្ធ គឺធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ និងការអប់រំសីលធម៌ព្រះពុទ្ធសាសនា។ អត្ថរសនៃអត្ថបទអក្សរសិល្ប៍ពុទ្ធនិយមអាចចែកចេញជា ៖

ទីមួយ **បច្ចេករស** ដោយប្រើប្រាស់ពាក្យកាព្យ និងរៀបចំជាដំណើររឿងឱ្យមានភាពអណ្តែតអណ្តូងឱ្យអ្នកអានរំភើបតាមដំណើររឿង។

ទីពីរ **វិសេសរស** ដោយបង្ហាញពីតម្លៃល្អ តម្លៃអាក្រក់ សកម្មភាពអស្ចារ្យ វីរភាពរបស់តួអង្គ សកម្មភាពតស៊ូរបស់តួអង្គ សោកនាដកម្ម និងសកម្មភាពរស់រវើក និងកំប្លែង ដើម្បីឱ្យអ្នកអានរីករាយ។

ទីបី **សព្វរស** ដោយឆ្លុះបញ្ចាំងពីតថភាពក្នុងសង្គម ជីវភាពប្រចាំថ្ងៃ លក្ខណៈអច្ឆរិយៈ និងកុសលរសដែលជាតម្លៃនៃការទូន្មានប្រៀនប្រដៅ។

ដោយសារតែអក្សរសិល្ប៍ពុទ្ធនិយមក្លាយភាគច្រើនសរសេរជាកំណាព្យ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ខ្ញុំសូមលើកយកអក្សរសិល្ប៍កំណាព្យខ្មែរយកមកបកស្រាយដូចតទៅ ៖

### ៤.១ ទិដ្ឋភាពអក្សរសាស្ត្រនៃការវិវត្តអក្សរសិល្ប៍កំណាព្យខ្មែរ

ខ្មែរចាប់សរសេរកំណាព្យជាយូរលង់ណាស់មកហើយ។ គេឃើញមានសិលាចារឹកតែងជាកំណាព្យជាភាសាខ្មែរបុរាណនិងជាភាសាសំស្ក្រឹតចាប់តាំងពីស.វ.ទី៥មកម៉្លេះ។

ចាប់តាំងពីស.វ.ទី១៤ នៅពេលដែលពុទ្ធសាសនាថេរវាទត្រូវបាននាំចូលកម្ពុជា ជំនួសព្រហ្មញ្ញសាសនា ភាសាបាលីចាប់ផ្តើមប្រើប្រាស់ជាភាសាយាន។ កវីនិពន្ធខ្មែរក៏ចាប់ប្រើប្រាស់ភាសាបាលី ក្នុងការនិពន្ធធម៌និងតែងកំណាព្យ។

វណ្ណកម្មអក្សរសិល្ប៍សម័យក្រោយអង្គរ ឬសម័យកណ្តាល គឺស្ទើរតែ១០០ភាគរយជាអក្សរសិល្ប៍ពាក្យកាព្យ ហើយមានតែពីរបីប៉ុណ្ណោះជាពាក្យរាយ។

**មូលហេតុអ្វីបានជាស្នាដៃអក្សរសិល្ប៍ភាគច្រើនសុទ្ធសឹងតែជាកំណាព្យ?**

ប្រជាជននៅជំនាន់នោះភាគច្រើនលើសលប់មិនចេះអក្សរ។ ពេលនោះមិនទាន់មានយុទ្ធនាការរំដោះគ្រោះមិនចេះអក្សរនៅឡើយ។ ដូច្នេះអ្នកចេះដឹងមានតិចតួច។ កវីនិពន្ធក៏ត្រូវសម្របខ្លួនតាមតម្រូវការសង្គម ដោយផ្តោតយកការនិទានតៗគ្នា ជាវិធីសាស្ត្រផ្សព្វផ្សាយស្នាដៃអក្សរសិល្ប៍។ ការសរសេរកំណាព្យមានសោភ័ណជាច្រើន ធ្វើឱ្យមានភាពទាក់ទាញ ងាយស្រួលចងចាំ និងទន្ទេញចាំមាត់។

ដើម្បីឱ្យមានភាពទាក់ទាញអ្នកនិពន្ធបានរៀបចំអក្សរសិល្ប៍ពុទ្ធនិយមនេះជាកំណាព្យ ដែលជាកម្រងពាក្យសម្តី មានន័យចាប់ចុងជួន ណែងណងមានចង្វាក់ សូរសៀង សំនៀងពីរោះរណ្តំ។ កំណាព្យខ្មែរមានសោភ័ណផ្សេងៗដូចតទៅ៖

***ទីមួយ សោភ័ណខាងសូរស័ព្ទ*** ៖ កវីនិពន្ធខ្មែរបានបង្កើតបទជាច្រើន



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដូចជា ៖

នៅចុងស.វ.ទី៦ សម័យចេនឡា គេឃើញមានកំណាព្យជាបទ បថ្យាវត្ត ៖

ត្រងោលបោលបាញ់លាបខ្លាញ់គីង្គក់
ត្រងោលដេកលក់គីង្គក់លោតថើប។

នៅសម័យក្រោយអង្គរ ចាប់ពីស.វ.ទី១៥មក គេឃើញមានកំណាព្យតែងជា៥បទ។ រឿងរាមកេរ្តិ៍ ពីខ្សែ១ដល់១០ និងរឿងល្បើកអង្គរវត្ត របស់អ្នក ប៉ាង តាត តែងជា៥បទ គឺ ៖

**១ បទពំនោល** ៖ សេចក្តីពោល គឺជាសេចក្តីបើកបទ ក្នុងការសម្តែងល្ខោន។

**២ បទព្រហ្មគីតិ** ៖ ចម្រៀងព្រះព្រហ្ម ដែលលន្លង់លន្លោច ដើម្បីសម្តែងទុក្ខសោក ការនិរាសព្រាត់ប្រាស។

**៣ បទកាកគតិ** ៖ ដំណើរក្អែក ប្រើក្នុងការសន្ទនា និងក្នុងសេចក្តីផ្តើមរឿង។

**៤ បទភុជង្គលីលា** ៖ ដំណើរនាគ ដែលមានលក្ខណៈទន់ភ្លន់ អែនអនផ្អែមល្ហែម ប្រើប្រាស់ក្នុងការរៀបរាប់ពិពណ៌នា និងការស្ញើចសរសើរ។

**ច្បាប់ស្រី ៖**

| | | |
|---|---|---|
| នេះបទកំណត់ចងជា | ភុជង្គលីលា | ចងជាច្បាប់ស្រី។ |
| កាលនាងឥន្ទ្រទេវី | ចរចាកតាមប្តី | បណ្ឌកយក្សា។ |
| នាងវិមលាជាមាតា | បើកបន្ទូលថា | ហៃកូនពិសី។ |
| នាងនឹងត្រាច់ត្រង់តាមប្តី | ចេញចាកអំពី | ពិភពនាគនេះ។ |

**៥ បទបន្ទោលកាក** ៖ ដំណើរកង្កែប លោតឈប់ៗ ប្រើជាត្លុកកំប្លែងក្រមាច់ក្រមើម។

នៅសម័យក្រោយៗចាប់ពីស.វ.ទី១៩ និង២០ កវីនិពន្ធខ្មែរតែងកំណាព្យជាបទថ្មីៗ ដូចជាបទពាក្យ៧ ពាក្យ៨ ពាក្យ៩ ពាក្យ១០ ពាក្យ១១ ដែល



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

កើតឡើងនៅចុងសម័យកណ្ដាល ហើយដែលកវីនិពន្ធប្រើបទនេះក្នុងចម្រៀងផ្សេងៗផងដែរ។

រឿងសព្វសិទ្ធិតែងដោយ ហ្នឹនកក្ដីអក្សរ តន់ រៀបរៀងជាបទពាក្យ៧។

រឿងនិរាសនគរវត្តតែងដោយ ឧកញ៉ាសុត្តន្តប្រីជា ឥន្ទ រៀបរៀងជាបទពាក្យ៨។

ក្រោយមកទៀតមានបទបំភ្លៃច្រើនទៀត ដូចជា បទកង្កែបលោតលើគោក បទកង្កែបលោតកណ្ដាលស្រះ បទអក្សរលូន បទសត្វកាងស្ទាបបទអើយរ៉ា។ល។

ខាងក្រោមនេះ គឺ **បទគោព័ទ្ធស្ទឹង** ៖

ប្រាសាទអង្គរគ្រឹះជាតិខ្មែរ ខ្មែរយើងត្រូវតែថែឱ្យគង់

គង់កេរ្តិ៍ដំណែលតដៅពង្ស ពង្សយើងជាវង្សសាងប្រាង្គប្រា។

**ទីពីរ សោភ័ណខាងវោហារសាស្ត្រ** ៖ ក្នុងអក្សរសិល្ប៍កំណាព្យ កវីនិពន្ធខ្មែរអាចរៀបរាប់ដោយលេងពាក្យ ឱ្យណែងណង ឱ្យមានសំឡេងរណ្ដំដូចភ្លេងវនាត។

**ទីបី សោភ័ណខាងទស្សនវិជ្ជាខ្មែរ** ៖ អត្ថបទអក្សរសិល្ប៍ គឺជានិក្ខេបបទខាងផ្នែកទស្សនវិជ្ជាពុទ្ធនិយម ដែលអ្នកនិពន្ធត្រូវលើកយកប្រធានបទនៃពុទ្ធនិយមពុទ្ធសាសនាមកបកស្រាយ ក្នុងគោលដៅទូន្មាន បង្ហាញពីការប្រយុទ្ធគ្នារវាងអំពើល្អនិងអំពើអាក្រក់ យុត្តិធម៌និងអយុត្តិធម៌ និងជួយដោះស្រាយបញ្ហា ដែលបង្ហាញលក្ខណៈសង្គមនៃអក្សរសិល្ប៍ពុទ្ធនិយម ហើយមិនមែនតែផ្ដោតលើសាសនាប៉ុណ្ណោះទេ។

ប្រការដូចបានរៀបរាប់ខាងលើ បានធ្វើឱ្យអក្សរសិល្ប៍ពុទ្ធនិយមសម័យក្រោយអង្គរបានក្លាយជាវណ្ណកម្មឯកគ្មានពីររបស់ខ្មែរ។

ទំព័រប្រវត្តិសាស្ត្រខ្មែរដ៏ឈឺចាប់បានបណ្ដុះកវីនិពន្ធជាច្រើនជំនាន់ដើម្បីធ្វើការតស៊ូតាមរយៈកំណាព្យ ដើម្បីឱ្យវប្បធម៌ជាតិបានរស់។ ម៉្យាងវិញទៀត កវីនិពន្ធជំនាន់នោះមានការជួយទំនុកបម្រុង និងឧបត្ថម្ភដោយ



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

មជ្ឈដ្ឋានផ្លូវការ ហើយព្រះមហាក្សត្រក៏ព្រះអង្គតែងតែយកព្រះទ័យទុកដាក់លើកវីនិពន្ធណាស់ ដោយផ្ដល់គោរមងារ និងតែងតាំងកវីនិពន្ធឱ្យកាន់ការធំក្នុងរាជការទៀតផង។

ខ្ញុំសូមរៀបរាប់ដូចតទៅ ៖

១- **ល្បើកអង្គរ** ដោយអ្នកប៉ាង តាត ឆ្នាំ ១៦២០។

២- **កាព្យនិរាស** ច្បាប់ព្រះរាជសម្ភារ ដោយព្រះរាជសម្ភារ ឆ្នាំ១៦៣៤។

៣- **សិលាចារឹកអង្គរវត្ត** ដោយបណ្ឌិត ជ័យ នន្ទ ឆ្នាំ១៧០១។

៤- **រឿងខ្យងស័ង្ខ** ចុងស.វ.ទី១៧។

៥- **រឿងក្រុងសុភមិត្រ** ដោយឧកញ៉ាកោសាធិបតី កៅ ចុងស.វ.ទី១៨។

៦- **ច្បាប់សុភាសិត** លោកនយបករណ៍ កោគកុលកុមារ រឿងវរនេត្រ វរនុជ រឿងព្រះសមុទ្រ ដោយព្រះឃ្លាំង នង ចុងស.វ.ទី១៧ និងដើមស.វ.ទី១៨។

៧- **រឿងដាវរឿង** ដោយឧកញ៉ាចក្រី កែវ ឆ្នាំ ១៧៤១។

៨- **រឿងនាងកាកី** ជាស្នាព្រះហស្ដព្រះបាទ អង្គឌួង ឆ្នាំ ១៨១៥ ( ពស ២៣៥៨ )។

៩- **រឿងល្បើកជេតពន** ដោយឧកញ៉ាសោទសខែក ឆ្នាំ ១៨១៥។

១០- **រឿងចម្ប៉ាថោង** ឆ្នាំ១៨១០។

១១- **រឿងរបាក្សត្រ** ដោយព្រះបទុមបារមី ពេជ្រ ឆ្នាំ ១៨១៨។

១២- **រឿងមុច្ចលិន្ទ** ដោយបណ្ឌិត សំអាត ឆ្នាំ ១៨៣៣។

១៣- **រឿងព្រះជិនវង្ស** ដោយអរិយគាមុនី ឆ្នាំ ១៨៥៦។

១៤- **រឿងពេជ្ជតា** ដោយធម្មបញ្ញា ម៉ែន ឆ្នាំ ១៨៥៧។

១៥- **រឿងវិមានចន្ទ** ដោយឧកញ៉ាធិបតី យ៉ែម ឆ្នាំ ១៨៥៩។

១៦- **ល្បើកស្រីវិជ័យ** ដោយពញាវិជិត្រស្រី ឆ្នាំ ១៨៥៨។

១៧- **រឿងទេវន្ទ ល្បើកចចក** ដោយឧកញ៉ាសន្ធរម៉ុក ឆ្នាំ ១៨៥៩។

១៨- **រឿងទុំទាវ** ដោយព្រះបទុមថេរសោម ឆ្នាំ១៩១៥។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ក្រៅពីនេះនៅមានរឿងស្រដៀងគ្នាផ្សេងៗទៀតដែលមិនបានបញ្ជាក់ពីអ្នកនិពន្ធ ហើយដែលខ្ញុំមិនបានលើកឡើងដោយសារតែមិនមានពេលគ្រប់គ្រាន់។

ចំណែកឯស្នាដៃអក្សរសិល្ប៍ប្រភេទពាក្យរាយមាន ៖ សិលាចារឹកអង្គរវត្តពីស.វ.ទី១៦ និងរឿងមហាវេស្សន្តរជាតក ដែលកែសម្រួលដោយលោក ញ៉ុក ថែម។

ខ្ញុំសូមអនុញ្ញាតវិភាគប្រៀបធៀបវណ្ណកម្មអក្សរសិល្ប៍កំណាព្យនៃស.វ.ទី១៧ ជាមួយអក្សរសិល្ប៍ពុទ្ធនិយមក្នុងស.វ.ទី១៨ និង១៩ ដូចតទៅ ៖

កំណាព្យ«ល្បើកអង្គរវត្ត» ដែលជាវណ្ណកម្មរបស់កវី ប៉ាង តាត តែងនៅក្នុងឆ្នាំ១៦២០ ត្រូវបានតែងដោយប្រើពាក្យខ្មែរកណ្តាល។ កំណាព្យ«ល្បើកអង្គរវត្ត» សរសេរដោយប្រើបទព្រហ្មគីតិ បទពំនោល និង បទកាកគតិ។

ខ្ញុំសូមដកស្រង់នូវអត្ថបទខ្លះដូចខាងក្រោម ៖

## បទព្រហ្មគីតិ

១. ប្រាសាទនេះឯងណា ព្រះឥន្ទ្រាទិព្វទេពថ្លៃ ប្រើព្រះពិស្ណុការនៃ<br>ចុះមកសាងថ្វាយក្សត្រា។

២. កាល្មោះអស្សារ្យក្រៃ មានក្សត្រិយ៍ថ្លៃសោយរាជា ស្តេចទ្រង់ព្រះនាមា<br>ហៅព្រះបាទវង្សអស្សារ្យ។

៣. ស្តេចមានព្រះអំណាច សេពសោយរាជ្យនូវធម្មា គ្រប់គ្រងអស់រាស្ត្រណា<br>សឹងក្សេមដោយព្រះបារមី។

៤. ស្តេចមានវរជាយា ទ្រង់នាមាទៃវតី ឆោមឆាយស្រស់សោភី<br>ជាច្បងច្បាស់អស់ស្នំផង។

៥. អនេកនូវបរិពារ ស្រីស្រីង្គាឥតឯផ្គង ស្រីស្រស់ទន់ទងវង<br>រៀបរាយរៀងបំរើនិត្យ។

៦. ព្រះមហាក្សត្រិយ៍ត្រកូល ជាឥស្សូរអង្គឯកក្សត្រិយ៍ សឹងមកប្រណិប័តន៍<br>ថ្វាយបង្គំឥតឯផ្គង។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## បទពំនោល

៧. ប្រាសាទទាំងបួនមានទ្វារ គ្រប់សព្វនូវប្រការ បន្ទាប់ទ្រាប់ត្រួតលើគ្នា។
៨. ផ្ទះផ្ទាំងជញ្ជាំងប្រាង្គប្រា- សាទសួគ៌សោភា ចម្លាក់ចំម្លៅរស់ក្តី។
៩. រូបទ្រង់បញ្ចង់សោភា ឈរឈមរៀងគ្នា លេងលើប្រាសាទសោតហោង។
១០. ខ្លួនមូលសសួលឥតហ្មង ទន់ភ្លន់មុខឈ្នង ប្រកបនូវលក្ខណ៍បានខ្នាត។
១១. ជួតចារភ្នីញោរស្អាងស្អាត ខ្លះបួងខ្លះកាត់ កែមកាលកេសាសោតសម។
១២. ចង្កេះរៀវឆ្លៀវមូលក្ញុំ ដោះសោតសឹងក្បុំ ក៏ដូចក្រពុំបទុមា។
១៣. ស្រឡះសជ្រះអង្គា សឹងពាក់មាលា គន្ធារភមរាកាឡី។
១៤. ចងនូវចំណងកេសី ពេនព័ន្ធទងភ្នី សក្តិសមបន្លាយល្អក្រៃ។
១៥. ខ្លះដោតខ្លះក្រងដ៏ប្រពៃ ខ្លះទើបយកដៃ សិកសៀតកាន់ក្រងឆ្វាត់ឆ្វាយ។
១៦. ខ្លះសោតសិតសក់បន្លាយ ខ្លះសោតកាន់ជាយ សំពត់ក៏ទាក់ឡើងផង។
១៧. ខ្លះកាន់ភ្នីសួគ៌ទាំងទង ខ្លះកាន់នៅកម្រង ភ្នីទេសទាំងទងលតា។
១៨. ខ្លះផ្អៀងឈ្ងងឈ្ងៀងមើលគ្នា ខ្លះចូលប្រវារ កាន់ស្មាដណ្តើមទងភ្នី។
១៩. ខ្លះសើចញញឹមប្រិមប្រិយ ហាក់នឹងស្រដី សំណេះសំណាលរួមរក្ស។

*កំណាព្យទីពីរមានចំណងជើងថា «សិលាចារឹកទំនើបអង្គរ»ជាវណ្ណកម្មរបស់ឧកញ៉ាយោមរាជជ័យ នន្ទ តែងនៅក្នុងឆ្នាំ១៧០១ ដែលនិពន្ធកំណាព្យជាភាសាខ្មែរកណ្តាលនៅក្នុងរាជ្យព្រះបាទជ័យចេស្តា ឬចុងរាជ្យព្រះរាជសម្ភារ។ ត្រូវបានតែងជាភាសាខ្មែរកណ្តាល។ ចំពោះការសរសេរវិញ អត្ថបទអក្សរសិល្ប៍សម័យកណ្តាលនៅក្នុងស.វ.ទី១៧ ខុសផ្ទែកពីសំណេរជាភាសាខ្មែរសម័យទំនើបឆ្ងាយ ពោលគឺស្រដៀងនឹងភាសាខ្មែរបុរាណ ជាងភាសាខ្មែរសម័យទំនើប[២៧]។ លោកបានតែងសិលាចារឹកចំនួន ៤០ផ្ទាំង (សិលាចារឹកទំនើបអង្គរវត្ត K-34, K-38 ចំនួនប្រមាណ៤០ផ្ទាំង)*

[២៧] Lewitz, Saveros. VI. Textes en khmer moyen. Inscriptions Modernes d'Angkor 2 et 3. In *BEFEO*. Tome 57, Paris 1970. pp. 99-126.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

ដែលប្រកបដោយសម្ផស្សដើងកាព្យ ដែលអាចយកជាគំរូមេកាព្យបាន។ នៅពេលដែលលោករៀបចំធ្វើពិធីបុណ្យនៅអង្គរវត្ត លោករៀបចំធ្វើសិលាចារឹកជាច្រើនផ្ទាំងដែលរៀបរាប់ពីខ្លួនលោក និងភរិយាដែលមានរូបឆោមប្រិមប្រិយ៍ ឈ្មោះដើមនាងប៉ែន សន ហើយបន្ទាប់មកបានឡើងយសជាជំទាវសុពណ៌។ ស្នាដៃនេះ គឺជាការបួងសួងរបស់លោក ប្រសិនបើមានជាតិក្រោយមែន សូមឱ្យជួបគ្នាទៀត។ អ្នកនិពន្ធបានកត់ត្រាទុកពីគ្រឿងបូជាផ្កាយព្រះ ឬការកសាងព្រះពុទ្ធរូប ដើម្បីសន្សំកុសលផលបុណ្យ ការត្រាប្រណីដោះលែងទាសាទាសីឱ្យជាអ្នកជាមានសេរីភាព និងរៀបរាប់ពីសមណស័ក្តិ និងគោរមងាររបស់ព្រះសង្ឃ ដូចជាតំណែងមហាសង្ឃរាជ ៩អង្គ និងតំណែងរាជាគណៈជាដើម។

ក៏ប៉ុន្តែ ចាប់ពីពាក់កណ្តាលទីពីរនៃស.វ.ទី១៨មក នៅពេលដែលស្ថានភាពនយោបាយ និងសង្គមខ្មែរកាន់តែយ៉ាប់យឺនទៅ ដោយការត្រួតត្រាគាបសង្កត់ពីបរទេស និងដោយសារវិនាសកម្មនៃសង្គ្រាម ប្រជាជនខ្មែរកាន់តែមានជំនឿលើធម៌ព្រះពុទ្ធខ្លាំងឡើង។ តាមក្បួនចិត្តសាស្ត្រ នៅពេលដែលស្ថិតនៅក្នុងភាពលំបាកវេទនា មានតែជំនឿលើសាសនាទេដែលលួងលោមឱ្យខ្មែរបន្តរស់នៅតស៊ូ ដើម្បីស្វែងរកឥស្សរភាព។

ខ្ញុំសូមសម្រាំងជ្រើសរើសតែវណ្ណកម្មអក្សរសិល្ប៍ពុទ្ធនិយមក្លាយល្បីៗចំនួន៤ប៉ុណ្ណោះ យកមកពិភាក្សានៅពេលនេះ។ មូលហេតុអ្វីបានជាកវីនិពន្ធចូលចិត្តយករឿងពុទ្ធនិយមក្លាយ ជាប្រធានបទសម្រាប់ការតែងនិពន្ធ? ខ្ញុំយល់ថាពុទ្ធនិយមក្លាយមានលក្ខណៈសង្គម មានលក្ខណៈមនុស្សជាងពុទ្ធនិយមពិត។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ៤.២ ការប្រើប្រាស់សំនួនវោហារក្នុងអក្សរសិល្ប៍កំណាព្យខ្មែរ

**ចុងស.វ.ទី ១៨ ៖**

**ទីមួយ-រឿង «ក្រុងសុភមិត្រ»** *ឆ្នាំ១៧៩៨*

*សរសេរដោយ ឧកញ៉ាកោសាធិបតី កៅ ដែលជាកវីឯកក្នុងរជ្ជកាលព្រះបាទអង្គចន្ទទី២។ លោកត្រូវបានតែងតាំងជាចៅហ្វាយឃ្លាំងមណីរតន៍ក្នុងព្រះបរមរាជវាំង និងជាទីប្រឹក្សាច្បាប់របស់ព្រះមហាក្សត្រ។ លោកបានសរសេររឿង «ក្រុងសុភមិត្រ» នៅឆ្នាំ១៧៩៨។ រឿងនេះអ្នកនិពន្ធបានដកស្រង់ចេញពីរឿងក្នុងបញ្ញាសជាតក ត្រង់ជាតកទី៩ ដែលមានជាភាសាបាលី ដែលលោកយកមកតែងជាពាក្យកាព្យខ្មែរ ដែលមានសេចក្ដីសង្ខេបដូចតទៅ ៖ «ព្រះរាជាព្រះនាមក្រុងសុភមិត្រ មានព្រះអនុជព្រះនាមអសុភ-មិត្រ ដែលចង់ធ្វើឃាតព្រះអង្គ ដើម្បីដណ្ដើមរាជសម្បត្តិ។ ព្រះអង្គក៏នាំមហេសីនិងបុត្រភៀសព្រះអង្គ ដើម្បីកុំឱ្យប្រជាជនលំបាកវេទនា។ លុះទៅដល់ទន្លេធំមួយ ក៏ដាក់បុត្រទាំងពីរទុក ហើយនាំមហេសីហែលទៅត្រើយម្ខាង។ នៅពេលត្រលប់មកវិញរកបុត្រមិនឃើញ ដោយសារមានគេលើកដាក់ទូកបាត់ទៅ។ នៅពេលដែលហែលឆ្លងទៅរកមហេសីនៅត្រើយម្ខាងទៀត មហេសីក៏ត្រូវគេចាប់ដាក់សំពៅទៀត។ ព្រះអង្គក៏យាងកាត់ព្រៃរហូតដល់នគរមួយឈ្មោះនគរតក្កសីលា ដែលឥតមានព្រះមហាក្សត្រ ហើយស្វែងរកអ្នកមានបុណ្យដើម្បីឡើងគ្រងរាជ្យ ហើយបានសុំឱ្យព្រះអង្គឡើងគ្រងរាជ្យ។ ក្រោយមកព្រះអង្គក៏បានជួបជុំជាមួយបុត្រទាំងពីរ និងមហេសីព្រះនាមកេសនីវិញ។»*

### បទភុជង្គលីលា

១. មើលផ្កាបុប្ផាស្រស់ស្រេច	បូបុស្បរំលេច	រីករុះសាយសព្វ។
ចម្ប៉ាក្ដាំងងាឈ្មុយឈ្ងប់	ដោរដូចរន្ទកអប់	ទាំងព្រៃព្រឹក្សា។
កាកែសចេកទេសយុក្ថា	ម្លិះរួតម្លិះលា	ខ្សឹងខ្សំសូរភី។
មហាហិង្គុប្រយង្គុនួនស្រី	ស្រទ្បិតមាលតី	លាយលេចច្បាច្រាល។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

លន្តៃពុតផ្លេរន្ធាល    រំចេកដាសដាល    ដុះដោយទីទួល។
២. ព្រឹក្សាបុប្ផាដង្ហរ    ហាក់ដូចអ្នកព្យួរ    សំយុងយោនយាន។
កន្លង់ត្រាច់ត្រង់សព្វស៊ាន    សៀងសួររូហាន    ភ្លេងតូរ្យតន្ត្រី។
ត្រាច់ត្រីបជញ្ឈប់ក្លិនភ្វី    កេសរវីកថ្មី    ពិដោរសព្វសាយ។

## បទភុជង្គលីលា

១. ពណ៌នាព្រឹក្សាដោយថ្នល់    រុះរោយរាយជល    អនេកត្រៀបត្រា។
ព្រួសព្រីងបុស្សបេងទន្លា    ទន្លាប់កេកា    សំរោងសំរង។
ស្មែស្មាច់លាយលេចអង្គ្រង    ត្រៀបត្រាចភ្លូភ្លង    ច្រៃសជ្រួយក្រស្នា។
មង្ឃុតស្នុតសេដា    ស្រល់ស្រូលឆាំឆា    ត្រទ្បាត់ត្រទ្បក។
២. សម៉ពង្រៃនូវធ្លក    ត្រៀកត្រាចប៉ប្រែក    ខ្វាវខ្ទិតខ្នុរខ្នារ។
ស្វាតស្វាយក្រូចក្រាយរកា    ពពេលពពារ    កប្បាសក្របៅ។
ផ្តកផ្តៀតកង្រៀកតាក្រៅ    ចាកចេកព្នែលញ្ញោ    ង្ហិករាំងក្រកោះ។
គ្រើលគ្រង់លពង់លំពស់    រលួយរលោះ    រលាយរលា។
ផ្អាវផ្អុងផ្ចាធ្នង់ពុទ្រា    ត្រួយត្រល់ត្រៀលស្វា    ទម្ងងទម្ងួច។
៣. មង្ឃុតល្មុតពោនពួច    បុស្សបេងសង្ឃួច    សង្ស័រសង្ឃា។
ក្រទ្បាញ់អង្កាញ់ចន្ទន៍ចារ    សៀងព្រាសំព័រ    ស្ពឹស្ពង់ស្ពីស្ពៅ។
ពោធិ៍ពៃច្រៃសដៃជ្រៃត្រៀបត្រៅ    បុស្សបេងបង្គៅ    ក្រវាញក្រវាន់។
គរគុយររុយសណ្តាន់    លំពស់លំពាន់    ដកពដកពាយ។
អំពៅក្របៅលេចលាយ    លៀបលោតវល្លិវាយ    វល្លិវ៉ែកទាស់ទាល។
៤. សុក្រំរាំងភ្នំសត្បា    កោដ្ឋកែវក្រូចឆ្មារ    កន្ទោកន្ធៃ។
ក្រសាំងមានទាំងលាំងដៃ    ភ្លូភ្លងឃ្លេឃ្លៃ    រំដួញរំដេញ។
ក្រិន្ធាពុទ្រាផ្ចាធ្មេញ-    ត្រីត្រាចប្រជេញ    ខ្ទឹងក្ទុម្ពសុរភី។
ម៉ោងជាងមាក់ប្រាងកាកី    មាក់ដោកស្រទ្បី    បង្កៅបង្ការ។
ច្រៃសជ្រួយប្រមួយខ្ទិតខ្វាវ    ក្តាតក្តួចវល្លិ៍យាវ    វល្លិប្រែងឆ្នាល់មាន់។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

## ៤.៣ គំនិតនៅក្នុងអក្សរសិល្ប៍កំណាព្យខ្មែរ

**ស.វ.ទី១៩ ៖**

**ទីពីរ-រឿង «ភោគកុលកុមារ»** ឆ្នាំ១៨០៤

ឧកញ៉ាព្រះឃ្លាំង នង ជាប្អូនបង្កើតរបស់ព្រះមាតានៃព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម។ លោកបានបួសរៀនទិងបានធ្វើជាចៅអធិការនៅវត្តចតុទិសនៃក្រុងឧដុង្គដោយបានទទួលសមណសក្តិជាមហាព្រហ្មមុនី។ ឧកញ៉ាព្រះឃ្លាំង នង ជាកវីឯកនៅក្នុងរាជ្យព្រះបាទអង្គអេង និងព្រះបាទអង្គចន្ទ។ លោកបានសរសេរស្នាដៃខាងអក្សរសាស្ត្រជាច្រើន រហូតដល់បានឡើងងារជាឧកញ៉ាព្រះឃ្លាំង ជាងារចាងហ្វាងក្រុមព្រះរាជបណ្ឌិត និងជាព្រះរាជនិពន្ធរបស់ព្រះរាជាទៀតផង។ ស្នាដៃរបស់លោកមាន ៖ ច្បាប់សុភាសិត(១៧៩០) លោកនយបករណ៍(១៧៩៤) បុណ្ណសារសិរសា(១៧៩៧) រឿង «ភោគកុលកុមារ»(១៨០៤) វរនុជវរនេត្រ(១៨០៦) ព្រះសមុទ្រ(១៨០៨) និង ពង្សាវតារ(១៨១៨)។

រឿង«ភោគកុលកុមារ» មានសេចក្តីសង្ខេបដូចតទៅ ៖ «ភោគកុលកុមារជាក្មេងកំព្រា ប្រកបរបរធ្វើចម្ការ។ ឃើញដូច្នោះ ព្រះឥន្រ្ទបាននាំបុត្រីឱ្យមកធ្វើជាភរិយាភោគកុលកុមារ។ គូស្វាមីភរិយានេះស្រឡាញ់គ្នាណាស់ ហើយនាងជាភរិយាមានរូបឆោមល្អស្រស់អស់លើស្រី។ លុះបានដឹងដល់ព្រះបាទព្រហ្មទត្ត ក៏ប្រើរាជអាមាត្យឱ្យយកនាងទៅរាំងឱ្យបាន។ អាមាត្យបានចាប់ភោគកុលកុមារបង្ខាំងទុក ភរិយាដឹងក៏លួចរត់។ ភោគកុលកុមារបានដើររកភរិយា ហើយបានត្មាតនាំផ្លូវរហូតដល់សួនច្បាររបស់បិតាក្មេក។ ភោគកុលកុមារបានលួចទម្លាក់ចិញ្ចៀនចូលក្នុងក្អមរបស់កិលៀង នៅពេលស្រោចទឹកលើកាយរបស់ភរិយា ជញ្ចៀនក៏ធ្លាក់ចូលក្នុងម្រាមព្រះហស្ត។ គេក៏បានដង្ហែភោគកុលកុមារចូលនគរ ហើយក្រោយមកភោគកុលកុមារក៏បានដណ្តើមរាជ្យពីព្រះបាទព្រហ្មទត្ត។»

## បទភាកគតិ

ព្រះបាទសត្ថកុង ភាជាវិសុទ្ធ វិសេសត្រាស់ថា
ហៅកូនសំឡាញ់ ចង់ចេញឃ្លាតឃ្លា ទៅនគរា
ពារាណសី។

អាពុកបើកតាម ចិត្តពុំឃាត់ហាម កូនស្ងួនប្រិមប្រិយ
ចូរបាផ្គត់ផ្គង់ តម្រង់ស្មារតី គ្រប់គ្រងធរណី
នានាំរាស្ត្រផង។

តាមដោយទសពិធ រាជធម៌សុចរិត កុំឱ្យមានហ្មង
រដ្ឋរាស្ត្រសព្វឋាន ឥតមានភ័យផង តាមដោយគន្លង
ធម៌ព្រះទូន្មាន។

មួយគឺធម៌ថា ឱ្យសង់សាលា ជីកស្រះសង់ស្ពាន
ឧស្សាហ៍ខ្វល់ខ្វាយ ចែកចាយធនធាន ធ្វើបុណ្យឱ្យទាន
សព្វថ្ងៃប្រក្រតី។

គំរប់ពីរចាំ រក្សាសីលប្រាំ លុះថ្ងៃអដ្ឋមី
ថ្ងៃឧបោសថ ស្រគត់ឥន្ទ្រិយ សូមសីលប្រាំបី
កាន់កុំខាតខាន។

ជាគំរប់បី ចូរបាប្រណី ដាក់ព្រះរាជទាន
ចិញ្ចឹមយោធា សេនាទាហាន បរិពារគ្រប់ប្រាណ
ថែទាំរក្សា។

ជាគំរប់បួន ចូរចិញ្ចឹមខ្លួន តាមដោយសម្មា
សមានបរិភោគ អធ្យោគអធ្យា កុំគិតបំពារ
បំពានទ្រព្យគេ។

ជាគំរប់ប្រាំ ចូរចងចិត្តចាំ កុំកាន់វៀចវេ
គិតដោះទុក្ខរាស្ត្រ ទាំងផ្តាសឱ្យថែ ឱ្យធួនប្រើប្រែ
ព្រះទ័យឱ្យទន់។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

ជាប្រាំមួយមាន តបៈឱ្យបាន ឈ្នះចិត្តលោភលន់
លះលែងទោសា មោហាទុជ៌ន បានបរិបូណ៌បុណ្យ
បំបាត់បាបបង់។

ជាប្រាំពីរសោត កុំឱ្យក្រេវក្រោធ ឆុរឆាបឱ្យរង់
ឱ្យរិះរំពឹង ជញ្ជឹងគិតក្នុង ហឫទ័យឱ្យត្រង់
ឱ្យត្រូវធម្មា។

គំរប់ប្រាំបី កុំបៀតជីវី ជីវិតហិង្សា
មនុស្សសត្វឥតទោស សន្តោសមេត្តា អាសូរករុណា
ជួយជន្មជីវី។

ជាប្រាំបួនបទ ឱ្យមានអំណត់ អំណរខន្តី
សច្ចំបរមត្ថ កាន់កតវេទី គិតគុណជននី
ជនកប្រធាន។

គំរប់ដប់ដោយ ធម៌ផ្ដែផ្ដាំឱ្យ មហាក្សត្រក្សេមក្សាន្ត
ត្រែកទ្រង់សណ្ដាប់ តាមច្បាប់បុរាណ កុំឱ្យបំពាន
បំពារក្រៅក្រឹត្យ។

បើក្សត្រឯណា គិតកាន់សីលា តាមដោយទសពិធ
រាជធម៌ទូន្មាន នឹងបានសម្រិទ្ធិ សម្រេចដូចចិត្ត
ដូចក្ដីប្រាថ្នា។

ក្នុងលោកិយគាប់ កើតកេរ្ដិ៍គំនាប់ គំនិតថ្លៃថ្លា
បរលោកនឹងបាន ឋិតឋានសួគ៌ា ដល់តុសិតា
សោយសម្បត្តិបុណ្យ។

**៤.៤ សោភ័ណខាងផ្នែកប្រៀបធៀបក្នុងស្នាដៃអក្សរសិល្ប៍កំណាព្យ ទីបី-រឿង «កាកី» ឆ្នាំ១៨១៥**

*អក្ខរកម្មភាសាខ្មែរមានវិបុលភាពជាខ្លាំងក្នុងរជ្ជកាលព្រះបាទ អង្គឌួង*



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

*ហើយទ្រង់ព្រះអង្គឯងក៏ជាអ្នកនិពន្ធដ៏ល្បីល្បាញផងដែរ។ ស្នាព្រះហស្ត របស់ព្រះអង្គមាន ៖ រឿងចម្ប៉ាថោង(១៨១០) រឿងកាកី(១៨១៥-នៅពេល ទ្រង់មានព្រះជន្ម១៩វស្សានៅឡើយ) និងច្បាប់ស្រី(១៨៣៧)។*

*ខ្ញុំសូមដកស្រង់កំណាព្យស្ដីពីសម្រស់នាងកាកី ៖*

## បទកាកគតិ

ស្ដេចមានមហេសី　នាមកែវកាកី　ល្អល្អះឥតហ្មង<br>
ឥតមានស្រីណា　សោភាផ្ទឹមផង　សមសព្វកន្លង<br>
កន្លោងអស់ស្រី។

កាយកើតអស្ចារ្យ　អំពីផ្កាកា-　ណិកាសោភី<br>
ភក្ត្រាសោភ័ណ　ដូចចន្ទ្របូណ៌មី　សក់ដូចភមរី<br>
រលើបខ្មាញ់ខ្មៅ។

លលាដ៍ពិលាស　ដូចពពិលមាស　ទុំទែងផ្អិនផ្អៅ<br>
មើលមាត់ញញឹម　បបើមឥតសៅ　ខឹមខាត់កាន់នៅ<br>
សម្ដីសមសួរ។

ថ្ពាល់ទាំងសងខាង　ដូចផ្លែមាក់ប្រាង　បំព្រងជងជួរ<br>
នាសាសមសល់　ដូចកលគំនូរ　ជាងចេះគន់គួរ<br>
សមសួនសោភា។

ធ្មេញខ្មៅរលីក　រលង់ប៉ផ្លេក　ដូចនិលរតនា<br>
កាណ៌កបល្អលន់　គួរគន់ដូចនា　ត្របកបទុមា<br>
វាយរីកស្រស់ថ្មី។

ចិញ្ចើមខ្មាញ់ខ្មៅ　កោងកបកលកៅ-　ទ័ណ្ឌទន់ស្រស់ស្រី<br>
នេត្រនាងថ្លាជ្រះ　ស្រឡះរាគី　ដូចកលរស្មី<br>
កញ្ចក់ជ្រះថ្លា។

កកបមូលក្ដុំ　ផ្នត់បីជាន់សម　ស្នាសោតសោភា<br>
កាងគួសមទ្រង់　គន់ត្រង់ហត្ថា　ដូចដៃព្ធរា-<br>
វ័ណវិសេសសម។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

អម្រាមទន់តូច រាងរៀវឆ្មារដូច បន្លាក្លៀវក្ដុំ
ក្រចកជ្រដះច្រាង សស្រាងហាក់ស- ម្បុរកែវអ្នកខំ
ខាត់ខិមយល់យង់។

ដោះក្បុំត្រចើល ត្រចះគួរមើល ដូចផ្កាសត្តប-
ង្ក័ជកបក្រពុំ មូលក្លុំជួរជង់ រាងទៅរៀវច-
ង្អេះកបពិសី។

ជើងសោតសស្ងួល ដូចចេកមាសមូល សមសព្វឥតបី
អ្នកណាមួយមាន ដូចប្រាណកាកី ល្អអស់ឥន្ទ្រីយ៍
ឥតឯមានទាស់។

សមសួនទាំងគ្រប់ ស្ងួចស្រីស្រស់សព្វ សម្បុរលឿងច្បាស់
ដូចមាសនព្វគុណ ល្អលន់ពេកណាស់ មើលមិនមានទាស់
ក្រភ្នែកស្រួលស្រេច។

កបកាយក្រអូប ទោះទាំងរាងរូប ប្រហើរពុំបាច់
រកផ្កាគ្រឿងអប់ ឈ្ងុយឈ្ងប់សព្វសាច់ ពិដោរបណ្ដាច់
បណ្ដូលអស់ស្រី។

បើនរនៃអ្នក ណានិងមិត្រភក្ដិ ចូលចងបេតី
រួមរសស្នេហ៍ស្និទ្ធ ក្លិនជិតឥន្ទ្រីយ៍ ប្រាំពីររាត្រី
ទើបបាត់គន្ធា។

ព្រះបាទព្រហ្មទត្ត ស្ដេចរួមប្រតិព័ទ្ធ និងព្រះជាយា
សព្វព្រះហឫទ័យ មូលមៃត្រីស្នេហា ដូចដួងនេត្រា
ព្រះអង្គជាម្ដង។

សេពសុខភិរម្យ រួមឯកបន្ទំ ទន្ទឹមស្នេហ៍ស្នង
សព្វទិនរាត្រី បេតីឥតហ្មង ស្ដេចទុកជាច្បង
ឯកអគ្គមហេសី។



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

**ទីបួន-រឿង «សព្វសិទ្ធិ» ឆ្នាំ១៨៩៩**

*រឿង «សព្វសិទ្ធិ» និពន្ធដោយអ្នកនិពន្ធ ហ៊ឹនភក្តីអក្សរ តន់ នៅក្នុងរជ្ជកាលព្រះបាទសម្តេចព្រះនរោត្តម ក្នុងឆ្នាំ ១៨៩៩។ ប្រភពរឿងនេះត្រូវបានដកស្រង់ចេញពីគម្ពីរបញ្ញាសជាតកបាលី យកមកច្នៃជារឿងល្បែងក្នុងរចនាបទកំណាព្យពាក្យ៧។*

*ដំណើររឿងនេះមានដូចតទៅ ៖ «កាលពីព្រះពុទ្ធនៅជាពោធិសត្វនៅឡើយ ទ្រង់បានកើតជាសត្វជៀបកប្បាស។ សត្វឈ្មោលធ្វើសំបុកឱ្យកូននៅជាមួយជៀបកប្បាសញីក្នុងព្រៃ។ ថ្ងៃមួយជៀបកប្បាសឈ្មោលទៅរកចំណី ក៏ចុះត្រេបលំអងផ្កាឈូកធំមួយ។ ត្រូវកំដៅផ្កាឈូកក៏ក្តោបជៀបកប្បាសឈ្មោលដល់យប់ជ្រៅ។ ចៃដន្យថ្ងៃនោះមានភ្លើងឆេះព្រៃ ជៀបកប្បាសញីមិនអាចយកកូនចេញពីសម្បុកបាន ក៏យំបោកខ្លួនម្នាក់ឯង។ លុះជៀបកប្បាសឈ្មោលមកដល់ ជាប់ក្លិនផ្កាឈូកផង ជៀបកប្បាសញីយល់ច្រឡំស្មានថាមានស្រី ក៏ហើរចូលភ្លើងស្លាប់មួយរំពេច។ ជៀបកប្បាសឈ្មោលក៏ហើរចូលភ្លើងដែរ។*

*ជៀបកប្បាសឈ្មោលបានទៅកើតជាកូនសេដ្ឋី មានឈ្មោះថា សព្វសិទ្ធិ។ ជៀបកប្បាសញីកើតជាព្រះរាជធីតា មានឈ្មោះថា សុវណ្ណកេសរ។ សុវណ្ណកេសរមិនព្រមនិយាយជាមួយបុរសណាទាំងអស់។ ព្រះបាទព្រហ្មទត្តក៏ប្រកាសថា បើប្រុសណាអាចធ្វើឱ្យ សុវណ្ណកេសរនិយាយរកនឹងផ្សំផ្គុំឱ្យ។ ដោយសព្វសិទ្ធិអាចធ្វើឱ្យព្រះនាងនិយាយបាន ទ្រង់ក៏រៀបអភិសេកព្រះរាជធីតាជាមួយសព្វសិទ្ធិ។» រឿងនេះពាក់ព័ន្ធនឹងជំនឿថាមានជាតិក្រោយ។*

*ខ្ញុំសូមលើកឡើងពីសម្រស់នាងសុវណ្ណកេសរដូចតទៅ ៖*

## បទពាក្យ៧

| | |
|---|---|
| សម្តេចបិតុរង្គអង្គមាតុរេត | ឱ្យនាមតាមភេទភាពអង្គប្រាណ |
| ឈ្មោះនាងសុវណ្ណកេសរសាន្ត | ស្មោះស្មានស្មើស្ម័គ្រវ័ក្សប្រិតា។ |



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

លុះនាងចម្រើនព្រះជន្មគ្រប់ បានប្រាំដណ្ដប់ព្រះវស្សា
រិតល្អអស់អង្គទ្រង់រូបា ដូចទេពកញ្ញានាសួគ៌ស្រី។
ព្រះភក្ត្រភុំភ្លងដួងបុប្ផា ដូចកលព្រះចន្ទថ្ងៃងរស្មី
ព្រះអង្គទ្រង់ដូចកិន្នរី ឆវីលឿងខ្ចីស៊ីន្ទូនក្លាយ។
សុដន់ដោះតូចដូចទន្លាប់- មាសជ្ឆាប់ជាប់នឹងព្រះកាយ
ក្រពុំក្បោះក្បុំសមឆោមឆាយ ល្អចប់សព្វសាយកាយសព៌ាង្គ។
ទាំងរូបទាំងឫកក៏រម្យទម មិនតូចមិនធំសមរូបរាង
ដំណើរវិលាសនិងយាសយាង ហាក់ដូចជានាងស្រីសុជាតា។
ធម្មតាជាស្រីក្នុងដីដែន ភពជែនត្បូងភ្នំសុមេរា
នឹងជ្រើសរើសរកស្រីឯណា ផ្ទៀងផ្ទឹមរូបាក៏ពុំបាន។

## V. សេចក្ដីសន្និដ្ឋាន

*អក្សរសិល្ប៍ពុទ្ធនិយម គឺជាប្រភេទអក្សរសិល្ប៍ដែលតែងជាពាក្យកាព្យ តាមលំនាំសាច់រឿងនៃ ទសជាតក និងបញ្ញាសជាតក នៅក្នុងអំឡុងស.វ.ទី១៨-១៩។*

*អក្សរសិល្ប៍កំណាព្យខ្មែរ ជាពិសេសអក្សរសិល្ប៍ពុទ្ធនិយមសម័យក្រោយអង្គរ ពិតជាកំណប់វិជ្ជាមហាសាលរបស់ខ្មែរពិតមែន។ ការវិវត្តនៃអក្សរសិល្ប៍កំណាព្យខ្មែរឆ្លុះបញ្ចាំងពីការវិវត្តនៃអក្សរសាស្ត្រខ្មែរជារួមពីការសរសេរជាភាសាបាលី សំស្ក្រឹត និងខ្មែរបុរាណ និងខ្មែរកណ្ដាល មកសរសេរជាភាសាខ្មែរក្នុងចុងស.វ.ទី១៩ និងដើមស.វ.ទី២០ ទាំងការវិវត្តខាងផ្នែកក្បួនវេយ្យាករណ៍ ការសរសេរពាក្យដ៏សម្បូណ៌បែប ដែលអាចចាត់ទុកជាបេតិកភ័ណ្ឌអរូបីនៃជាតិខ្មែរយើង ការតែងកំណាព្យជាបទដ៏ច្រើនសន្ធឹកសន្ធាប់ ដែលឆ្លុះបញ្ចាំងពីភាពរស់រវើក និងការចេះច្នៃប្រឌិតរបស់កវីនិពន្ធខ្មែរ។*

*គោលដៅនៃបាឋកថានេះ គឺចង់គាស់កំណប់មហាសាលមិនអាច*

*កាត់ថ្លៃបាន ដែលកប់ចោលយ៉ាងយូរ ដើម្បីឱ្យកូនខ្មែរជំនាន់ក្រោយបាន យល់ដឹង និងចេះឱ្យតម្លៃលើទ្រព្យសម្បត្តិដ៏សម្បូណ៌បែបនេះ ហើយចេះ អភិរក្សរក្សាទុកដល់ជនានុជនជំនាន់ក្រោយ ជាទ្រព្យជាប់អាត្មា។*

**ឧកញ៉ាសុត្តន្តប្រីជា ឥន្ទ**

*ខ្ញុំបានចាប់ផ្ដើមពីការសិក្សាអត្ថបទកំណាព្យ ល្បើកអង្គរវត្ត រៀបរៀង ដោយ អ្នកប៉ាងតាត និងសូមអនុញ្ញាតបញ្ចប់បាឋកថានេះ ដោយកំណាព្យ និរាសនគរវត្ត ឬដំណើរទៅកាន់អង្គរ តែងនៅឆ្នាំ១៩០៥ ដោយកវីដើម ស.វ.ទី២០ គឺឧកញ៉ាសុត្តន្តប្រីជា ឥន្ទ (១៨៥៩-១៩២៤) ដែលបានសិក្សា យ៉ាងជ្រៅជ្រះខាងផ្នែកព្រះពុទ្ធសាសនា ភាសាបាលី និងភាសាខ្មែរយ៉ាង ស្ទាត់ជំនាញៗ លោកបានទៅសិក្សានៅទីក្រុងបាងកក ដែលនៅស.វ.ទី១៩ គឺជាកន្លែងដែលព្រះសង្ឃខ្មែរទៅរៀនបន្តខាងផ្នែកភាសាបាលី។ ដូច្នេះ ហើយទើបបារាំងបានបង្កើតសាលាបាលីឡើងនៅឆ្នាំ១៩០៩ នៅសៀមរាប ដើម្បីកាត់បន្ថយអ្នកដែលទៅរៀននៅប្រទេសថៃ។ ខ្ញុំសូមជូនអត្ថបទកំណាព្យ ដកស្រង់ដូចតទៅ ៖*

## បទពាក្យ៨

អនិច្ចាតោថ្មលោកកសាង | មើលថាចាងយ៉ាងរស់ស្មុះប្រែប្រាយ
ឥឡូវមកធ្លាយធ្លាក់បាក់ខ្ទាត់ខ្ទាយ | ស្ដាយអើយស្ដាយមិនគួរមកពិការ។
មានអ្នកព្រៃចង្រៃឥតគំនិត | មកសំលៀងកាំបិតគ្រឿងប្រហារ
ឱ្យខូងខូចខាតសាច់បង់អាសារ | មិនស្ដាយការស្នាដៃបូរាណសោះ។
ឱតោអើយតោឈរមិនមើលមៀង | មកឱ្យគេសំលៀងខ្នងតោចុះ
ម្ដេចមិនខឹងខាំវាសំលៀងនោះ | ឱ្យវាលុះក្ដីមរណ៍យក៏វាទៅ។
អាណាអើយបំផ្លាញរូបតោលោក | គ្មានប្រយោគឱ្យយល់ការភាក់ជ្រៅ
គួរឬលោកខំសាងតាំងទុកនៅ | មកសត្រូវបំផ្លាញរបស់លោក។



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

*ជាទីបញ្ចប់ ខ្ញុំសូមឧទ្ទិសកំណាព្យរបស់លោក ឱម ណាត្រី សាស្ត្រាចារ្យភាសាខ្មែរ ជូនចំពោះបុគ្គលិកអប់រំទាំងអស់ ៖*

| | | |
|---|---|---|
| កាលនៅរស់ | ត្រូវធ្វើការ | ណានីមួយ |
| ទុកជំនួយ | ជួយចំណែក | ចែកដល់ជាតិ |
| កុំកើតឡើង | ស្លាប់ទៅវិញ | ទទេស្អាត |
| ទុកតែធាតុ | មួយកញ្ចប់ | ប៉ុណ្ណោះឡើយ។ |



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

# ឯកសារពិគ្រោះ

**ភាសាខ្មែរ**


ពុទ្ធសាសនបណ្ឌិត្យ (1959). ***រឿងរាមកេរ្តិ៍*** *ខ្សែ ១-១០ និង ខ្សែ ៧៥-៨០, បោះផ្សាយលើកទី៣ (ព.ស ២៥៣៩) បោះពុម្ពឡើងវិញដោយគណៈកម្មាធិការជប៉ុននៃក្រុមប្រឹក្សាពិភពលោកនៃសាសនា និងសន្តិភាព (WCRP) និងគណៈកម្មាធិការជំនួយសូត្តូស៊ូជប៉ុន (JSRC) ភ្នំពេញ*

*ឃីង ហុកឌី (2003) «**ទិដ្ឋភាពទូទៅនៃអក្សរសាស្ត្រខ្មែរ**» មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ*

*ឃីង ហុក ឌី (2003) «**មាលីបទ អក្សរសិល្ប៍ខ្មែរស.វ.ទី១៩**»*

*ឃីង ហុកឌី (2006)* ***ល្បើកអង្គរវត្ត*** *អារម្ភកថាដោយ Editions Angkor*

*ឃួន សុខម្ហ (1963)* ***ការសិក្សារឿងរាមកេរ្តិ៍*** *(អត្ថបទវាយអង្គុលីលេខ) ភ្នំពេញ*

*ម៉ុញ សារី (2011).* ***វចនាធិប្បាយអក្សរសិល្ប៍ខ្មែរ*** *(Encyclopedia of Khmer Literature)* **មជ្ឈមណ្ឌលស្រាវជ្រាវអាស៊ីនៃរាជបណ្ឌិត្យសភាកម្ពុជា**

*លាង ហាប់អាន (1967) «**សិក្សាប្រវត្តិអក្សរសាស្ត្រខ្មែរ ៖ សម័យនគរភ្នំដល់សម័យឧដុង្គ( ស.វ.ទី១ ដល់១៨៥៩)**»។*

*លី សុវីរ (2008). «**ដំណើរប្រវត្តិស្តីពីសាលាបាលីជាន់ខ្ពស់ ព្រះរាជបណ្ណាល័យ និង ក្រុមជំនុំ៣**»*

*សរ សារុន (គ្មានកាលបរិច្ឆេទ)* ***សង្ខេបរឿងរាមកេរ្តិ៍*** *(ស្របតាមកម្មវិធីសិក្សា) ភ្នំពេញ*

*វ៉ាន់ឌី កាអុន (1973) អាល់ប៊ែរត៍ កាមុស ៖* ***ទស្សនវិទូនៃការឥតន័យ*** *ភ្នំពេញ ការផ្សាយរបស់នគរធំ*

*វ៉ាន់ឌី កាអុន (1973)* ***បញ្ហាវប្បធម៌និងអារ្យធម៌*** *ភ្នំពេញ ការផ្សាយរបស់អ្នកនិពន្ធ*





fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

វ៉ាន់ ឌី កាអុន (1973) **ក្បួនចិត្តសាស្ត្រ** ភ្នំពេញ ការផ្សាយរបស់អ្នកនិពន្ធ
វ៉ាន់ ឌី កាអុន (1973) **វិភាគទាននៃការសិក្សា ៖ ប្រាកដនិយមនិងអណ្តែតអណ្តូងនិយម** ភ្នំពេញ
វ៉ាន់ ឌី កាអុន (1973) **វិភាគទាននៃការសិក្សាអក្សរសិល្ប៍ខ្មែរ ៖ ចលនាអក្សរសិល្ប៍** ភ្នំពេញ
វ៉ាន់ ឌី កាអុន (1974) **សោកនាដកម្មនៃការអផ្សុករបស់អ្នកស្រីបូវ៉ារី ៖ វិភាគប្រលោមលោក** ភ្នំពេញ ការផ្សាយរបស់អ្នកនិពន្ធ
វ៉ាន់ ឌី កាអុន (1974) **ស្នេហាចុកឈាមរបស់កម្លោះវែរទែរ ៖ វិភាគប្រលោមលោក** ភ្នំពេញ ការផ្សាយរបស់អ្នកនិពន្ធ
វ៉ាន់ ឌី កាអុន (2008) **ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា ៖ ពីសម័យអាណានិគមបារាំងមកដល់បច្ចុប្បន្នកាល.** ភាគទី១ ភាគទី២ និង ភាគទី៣
វ៉ាន់ ឌី កាអុន (2012) **សុបិន និង ការពិត** ភាគទី១ និង ភាគទី២
ស៊ិន សុវណ្ណនិ (2012) «**ឯកសារស្រាវជ្រាវក្រុមជំនុំប្រែគម្ពីរ ព្រះត្រៃបិដកនៃប្រទេសកម្ពុជា**» គ្រឹះស្ថានបោះពុម្ពផ្សាយអង្គរ
**រឿង បណ្តាំតាមាស** (1908) បោះពុម្ពឡើងវិញដោយបណ្ណាគារអង្គរ

### ភាសាបរទេស

Chandler, David (1996). *Facing the Cambodian Past.* Chiang Mai: Silkworm.

Edwards, P. (2007), *Cambodge: The Cultivation of a Nation, 1860-1945,* University of Hawaii Press, Honolulu.

Hansen, A. R. (2008) *How to Behave: Buddhism and Modernity in Colonial Cambodia, 1860-1930*. Silkworm Books. Chiang Mai.

Khin Sok (1991). *Le Cambodge entre le Siam et le Vietnam (de 1775 à 1869)*, EFEO, Paris.



fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

Leclère (1914). *Adhémard. Histoire du Cambodge*. Paris: Librairie Paul Geuthner.

Lewitz, Saveros (1970). VI. Textes en khmer moyen. Inscriptions Modernes d'Angkor 2 et 3, *BEFEO*, Tome 57, Paris.

Lewitz, Saveros (1972), «Les inscriptions modernes d'Angkor Wat» *Journal Asiatique* no. 260 (1972) : 1-2, 107-129.

Mak Phoeun (1980), « L'Introduction de la Chronique Royale du Cambodge du lettré Nong », *BEFEO*, 67 (1980).

Pou, S. (1975). « Inscriptions Modernes d'Angkor Vat », (IMA34-38), *BEFEO*., t. LXII, Paris 1975:293...

Pou, S. (1977). *Etude sur le Ramakerti (XVIe-XVIIe siècles)*, Paris, Pub. EFEO.

Pou, S. (1979). *Ramakerti (XVIè-XVIIè siècles), Texte khmer publié*, Paris, EFEO, vol. CXVII, 1979.

-------- (1982). *Ramakerti II (Deuxième version du Ramayana khmer)*, Texte khmer, traduction et annotations, Paris, EFEO, vol. CXXXII, 1982.



fb.com/krou.moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

# បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** បច្ចុប្បន្នជារដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងជាអនុប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ(SNEC) ក្នុងនីតិកាលទី៥នៃរាជរដ្ឋាភិបាលកម្ពុជា។

លោកទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់នៅឆ្នាំ១៩៨៨ និងបណ្ឌិតនៅឆ្នាំ១៩៩១ ផ្នែកសេដ្ឋកិច្ចអន្តរជាតិពីវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិក្រុងម៉ូស្គូ ព្រមទាំងសញ្ញាបត្រជាន់ខ្ពស់ផ្នែកជានារ៉ាប់រងពីវិទ្យាស្ថានជានារ៉ាប់រង(CII) ប្រទេសអង់គ្លេស និងវិទ្យាស្ថានជានារ៉ាប់រងម៉ាឡេស៊ី (MII)។ នៅឆ្នាំ២០១២ លោកបណ្ឌិតទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកនីតិសាស្ត្រអន្តរជាតិពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅកម្ពុជា និងពីសាកលវិទ្យាល័យLyon II នៃសាធារណរដ្ឋបារាំង ព្រមទាំងទទួលបានវិញ្ញាបនបត្រផ្នែកនីតិសមុទ្រពីបណ្ឌិត្យសភា Rhodes ផ្នែកនីតិសាស្ត្រ និងគោលនយោបាយសមុទ្រ។ នៅឆ្នាំ២០១៨ លោកបណ្ឌិតទទួលបានសញ្ញាបត្របណ្ឌិតផ្នែកអប់រំពីសាកលវិទ្យាល័យចូឡាឡុងកន។

លោកបណ្ឌិតធ្លាប់បានបម្រើការងារក្នុងបេសកកម្មការទូត និងក្នុងវិទ្យាស្ថានស្រាវជ្រាវ ជាអ្នកវិភាគនយោបាយ និងសេដ្ឋកិច្ច។ ចាប់តាំងពីឆ្នាំ១៩៩៩មក លោកបណ្ឌិតបានចូលបម្រើការងារក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងទទួលបន្ទុកការងារសំខាន់ៗរួមមាន អ្នកសម្របសម្រួលការងារស្រាវជ្រាវនៃក្រុមប្រឹក្សាសេដ្ឋកិច្ច និងជាអនុប្រធានទី១នៃនាយកដ្ឋានថវិកា និងហិរញ្ញវត្ថុ។ បន្ទាប់មក ក្នុងឆ្នាំ២០០១ លោកបណ្ឌិតបានត្រូវតែងតាំងជាអគ្គលេខាធិការរងទទួលបន្ទុកគោលនយោបាយរួមមាន គោលនយោបាយ

សេដ្ឋកិច្ច សារពើពន្ធ ហិរញ្ញវត្ថុ កិច្ចការអាស៊ាន ឧស្សាហកម្មហិរញ្ញវត្ថុ ការវិភាគសេដ្ឋកិច្ច និងទទួលបន្ទុកក្នុងការសម្របសម្រួលជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ(IMF) និងធនាគារពិភពលោក(World Bank)។

ពីឆ្នាំ២០០៤ដល់ឆ្នាំ២០១០ លោកបណ្ឌិតត្រូវបានតែងតាំងជាអគ្គ-លេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ លោកបណ្ឌិតធ្លាប់ចូលរួមកិច្ចប្រជុំអនុរដ្ឋមន្ត្រីហិរញ្ញវត្ថុ និងទេសាភិបាលធនាគារកណ្ដាលអាស៊ានបូកបី ពីឆ្នាំ២០០០ដល់២០១០។ ពីឆ្នាំ២០១០ដល់ឆ្នាំ២០១៣ លោកត្រូវបានតែងតាំងជារដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក្នុងតួនាទីនេះ លោកធ្លាប់ធ្វើជាតំណាងប្រទេសកម្ពុជា ក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុនិងទេសាភិបាលធនាគារកណ្ដាល G20 ក្នុងឋានៈដែលប្រទេសកម្ពុជាជាប្រធានអាស៊ាន នៅឆ្នាំ២០១២។ លោកបណ្ឌិតក៏បម្រើការងារជាអ្នកសម្របសម្រួលកិច្ចពិភាក្សាគោលនយោបាយរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាមួយធនាអភិវឌ្ឍន៍អាស៊ី(ADB) មូលនិធិរូបិយវត្ថុអន្តរជាតិ(IMF) និងធនាគារពិភពលោក(World Bank)។

ក្នុងតំណែងជាអនុប្រធានប្រចាំការនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ(SNEC) ដែលជាស្ថាប័នខាងផ្នែកគោលនយោបាយសេដ្ឋកិច្ចនៃរាជរដ្ឋា-ភិបាលកម្ពុជា លោកបណ្ឌិតបានសរសេរឯកសារគោលនយោបាយជាច្រើន និងបានអមដំណើរ **សម្ដេចអគ្គមហាសេនាបតីតេជោហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចូលរួមក្នុងសន្និសិទអន្តរជាតិ ដូចជាមហាសន្និបាតអង្គការសហប្រជាជាតិ ចលនាមិនចូលបក្សសម្ព័ន្ធ កិច្ចប្រជុំកំពូលអាស៊ាន កិច្ចប្រជុំកំពូលអាស៊ីបូព៌ា និងវេទិកាអន្តរជាតិជាច្រើនទៀត។

លោកបណ្ឌិតបាននិពន្ធសៀវភៅជាច្រើនក្បាល ជាភាសាខ្មែរ អង់គ្លេស និងបារាំង ស្ដីអំពីការអភិវឌ្ឍសេដ្ឋកិច្ចនៅកម្ពុជា និងហិរញ្ញវត្ថុសាធារណៈ ហើយស្នាដៃចុងក្រោយ ក្រោមចំណងជើងថា «Cambodian Economy:

*Charting the Course for a Bright Future»* ត្រូវបានជ្រើសរើសបោះពុម្ពផ្សាយ ដោយវិទ្យាស្ថានសិក្សាអាស៊ីអាគ្នេយ៍(ISEAS) នៃប្រទេសសិង្ហបុរី។ ស្នាដៃចុងក្រោយរបស់លោក គឺ «Education Reform in Cambodia»។

# ស្នាដៃរបស់អ្នកនិពន្ធ

១- *L'Économie du Cambodge : La lutte pour le développement, 2005*

២- *Essais économiques, 2007*

៣- *Les finances publiques du Cambodge, 2007*

៤- *Cambodia: Recent Macroeconomic and Financial Sector Development, 2008*

៥- *Three Essays on Macroeconomic Management of Cambodia, 2008*

៦- *Introduction to Insurance, 2008*

៧- ម៉ាក្រូសេដ្ឋកិច្ច - ឆ្នាំ២០០៩

៨- *Public Finance in Cambodia, 2009*

៩- ហិរញ្ញវត្ថុសាធារណៈ - ឆ្នាំ២០០៩

១០- ប្រាសាទព្រះវិហារ - ឆ្នាំ២០០៩

១១- *Cambodian Economy: Chartering the Course of a Brighter Future. A Survey of Progress, Problems and Prospects, 2009*

១២- *L'économie du Cambodge: Nouvelles frontières du développement socio-économique, 2010*

១៣- *Regards sur le différend maritime khméro-thaïlandais à la lumière de la jurisprudence internationale, 2012*

១៤- ទស្សនាទានស្ដីពីវិវាទព្រំដែនសមុទ្ររវាងកម្ពុជា និងថៃឡង់ដ៍ ក្នុងបរិបទនៃយុត្តិការអន្តរជាតិ - ឆ្នាំ២០១៣

១៥- សេដ្ឋកិច្ចកម្ពុជា ៖ មាគ៌ាឆ្ពោះទៅរកអនាគតដ៏ភ្លឺស្វាង ៖ វឌ្ឍនភាព បញ្ហាប្រឈម និងទស្សនវិស័យទៅអនាគត - ឆ្នាំ២០១៥

fb.com/krou.moeys.gov.kh www.moeys.gov.kh YouTube youtube.com/moeyscambodia

១៦- កំណែទម្រង់វិស័យអប់រំនៅក្នុងប្រទេសកម្ពុជា ៖
មាគ៌ាឆ្ពោះទៅរកសង្គមពុទ្ធិ និងវិបុលភាព - ឆ្នាំ២០១៦

១៧- គោលនយោបាយទំនាក់ទំនងសេដ្ឋកិច្ចក្រៅប្រទេសនៃប្រទេសកម្ពុជា
នាសម័យទំនើបនៅសម័យសាធារណរដ្ឋប្រ ជាមានិតកម្ពុជា( ទសវត្សរ៍
ឆ្នាំ១៩៨០) - ឆ្នាំ២០១៧

១៨- នីតិអន្តរជាតិសេដ្ឋកិច្ច - ឆ្នាំ២០១៧

១៩- *Series of Lectures in Public International Law, 2018*

២០- សិក្ខាសង្ខេបស្តីពីទស្សនវិជ្ជា - ឆ្នាំ២០១៨

២១- *Droit International Économique, 2018*

២២- *Education Reform in Cambodia, 2018*